សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University Of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយសំណង់បណ្ដោះអាសន្ន លើដីរដ្ឋនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ពេជ្រ សៀ**

លោក **សឿន លីមហេង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាង ផល្លី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្ដីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីររូបឈ្មោះ **ពេជ្រ សៀ** និង **សឿន លីមហេង** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២២ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ ២០១៨-២០២២។

**ខ្ញុំបាទទាំងពីររូបសូមសម្ដែងគារវកិច្ច និងកតញ្ញូតាធម៌ជូនចំពោះ**

**លោកឪពុក អ៊ុំ ពេជ្រ** **លោកឪពុក សេង សុផារិទ្ធ**

**អ្នកម្ដាយ ហេង គឹមអេង** **អ្នកម្ដាយ គីម យ៉េកស៊ាង**

ដែលជាអ្នកមានគុណយ៉ាងធំធេងចំពោះកូន ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងដល់រូបកូនទាំងកម្លាំងកាយ កម្លាំងចិត្ត និងថវិកា តាំងពីតូចរហូតដល់ធំដឹងក្ដីប្រកបដោយព្រហ្មវិហារធម៌ទាំងបួនគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ក៏ដូចជាបានផ្ដល់ឱកាសឱ្យកូនបានសិក្សាចូលរៀនពីតាំងថ្នាក់មត្តេយ្យរហូតបានបន្តការសិក្សាដល់ថ្នាក់បរិញ្ញាបត្រដូចបច្ចុប្បន្ននេះ។ បើសិនជាគ្មានការលើកទឹកចិត្ត និងការយកចិត្តទុកដាក់ពីសំណាក់អ្នកមានគុណទេ ម្ល៉េះសមពេលនេះ រូបកូនមិនអាចក្លាយខ្លួនជា កូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គមបានឡើយ។ ទាំងអស់នេះហើយជាគុណូបការៈដ៏វិសេសវិសាល និងមិនអាចកាត់ថ្លៃបានចំពោះកូន។ ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លៃអំណរគុណចំពោះ **ឯកឧត្ដមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** និង **លោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលខិតខិតបំពេញភារកិច្ចក្នុងការគ្រប់គ្រង ដឹកនាំ និងជួយតម្រង់ទិសដល់រូបយើងខ្ញុំ ដើម្បីចូលរួមចំណែកក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់ប្រទេសជាតិ ប្រកបដោយគុណភាព និងសមត្ថភាពពិតប្រាកដ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្ដមបណ្ឌិតសាស្ត្រាចារ្យ **ហាប់ ផល្លី** ជាសាស្ត្រាចារ្យណែនាំ ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការផ្ដល់យោបល់កែតម្រូវនូវកិច្ចការសរសេរសារណារហូតទទួលបានជោគជ័យ។

ជាចុងបញ្ចប់នេះ យើងខ្ញុំទាំងពីររូប សូមសម្ដែងនូវការដឹងគុណអស់ពីដួងចិត្ត និងសូមគោរពជូនពរអ្នកមានគុណ ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងមិត្តអ្នកអានទាំងអស់ឱ្យជួបតែនឹងសេចក្ដីសុខ សេចក្ដីចម្រើននៅក្នុងជីវិត ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាយើងខ្ញុំបានតាក់តែងឡើងមកនេះ គឺជាអ្វីដែលយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងជាទីបំផុត នៅពេលសិក្សាក្នុងថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្ររយៈពេលបួនឆ្នាំងកន្លងមកនេះ។ ដោយសង្កេតឃើញពីបញ្ហាជាច្រើនដែលបានកើតមានឡើងនៅក្នុងសង្គម រវាងសហគមន៍ ឬក្រុមគ្រួសារជាច្រើន ជាមួយនឹងអាជ្ញាធររដ្ឋដែលទាក់ទងទៅនឹងទំនាស់ដីធ្លីផ្សេងៗ រួមមានការទន្ទ្រានកាន់កាប់ដីរដ្ឋ ការឈូសឆាយដីព្រៃ ការសាងសង់សំណង់យ៉ាងអនាធិបតេយ្យ នៅលើដីរដ្ឋដោយខុសច្បាប់ជាអាទិ៍។ កត្តាទាំងអស់នេះទាមទារឱ្យរដ្ឋដាក់ចេញនូវយន្តការផ្នែកច្បាប់ផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងបញ្ហាចំពោះមុខដែលបាននឹងកំពុងកើតមានឡើង។ ក្នុងបញ្ហាទាំងអស់ខាងលើ យើងខ្ញុំមានការចាប់អារម្មណ៍ចំពោះបញ្ហាដែលទាក់ទងទៅនឹងការសាងសង់សំណង់បណ្តោះអាសន្ននៅលើដីរដ្ឋ ដែលយើងខ្ញុំចង់សិក្សាស្រាវជ្រាវ និងចងក្រងជាអត្ថបទមួយដែលផ្តោតសំខាន់ទៅលើ ការដោះស្រាយចំពោះបញ្ហាទាំងអស់នេះ ថាតើរដ្ឋបានដាក់ចេញនូវវិធានការអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងការសាងសាង់សំណង់ដោយខុសច្បាប់ទាំងអស់នោះ ហើយដំណោះស្រាយរបស់ភាគីរដ្ឋ មានភាពសមរម្យ និងត្រឹមត្រូវស្របតាមគោលការណ៍សិទ្ធិមនុស្សដែលបានកំណត់នៅក្នុងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិដែរឬទេ?

គោលបំណងចម្បងនៃការស្រាវជ្រាវចំពោះប្រធានបទ “ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋនៅកម្ពុជា” នេះគឺចង់ផ្តល់ជូនអត្ថបទស្រាវជ្រាវផ្នែកច្បាប់ដែលសិក្សាពាក់ព័ន្ធនឹងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងយន្តការនៃការដោះស្រាយចំពោះការតាំងទីលំនៅដោយខុសច្បាប់ដែលធ្វើឡើងនៅលើដីរដ្ឋ និងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ក៏ដូចជាគោលនយោបាយ និងយន្តការផ្សេងៗចំពោះសហគមន៍ និងក្រុមគ្រួសារដែលបានសាងសង់សំណង់នៅលើដីរដ្ឋដោយខុសច្បាប់នោះ។ មួយវិញទៀតយើងខ្ញុំចង់រំលេចចេញនូវសញ្ញាណផ្សេងៗ នៃដីរដ្ឋដើម្បីជាប្រយោជន៍ក្នុងការកំណត់បាននូវប្រភេទកម្មសិទ្ធិនៃដីឱ្យបានច្បាស់លាស់។

យ៉ាងណាមិញបើទោះបីជា ការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានសរសេរឡើងយ៉ាងសម្រិតសម្រាំង និងយកចិត្តទុកដាក់យ៉ាងណាក្តី ក៏គង់តែនៅមានចំណុចខ្វះខាតលើខ្លឹមសារ និងពាក្យពេចន៍ ដែលកើតមានឡើងដោយអចេតនា ដោយហេតុសមត្ថភាពនៃការចងក្រង និងការប្រមូលផ្តុំនូវឯកសាររបស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ អាស្រ័យហេតុនេះ យើងខ្ញុំសូមការអធ្យាស្រ័យទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងឡាយ ប្រសិនបើមានកំហុសឆ្គងកើតមានត្រង់កន្លែងណាមួយក្នុងខ្លឹមសារទាំងស្រុងនៃស្នាដៃសារណានេះ។ យើងខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ក្នុងការទទួលយកនូវមតិរិះគន់ក្នុងន័យកែលម្អ ដើម្បីជាប្រយោជន៍ដល់រូបយើងខ្ញុំក្នុងការអភិវឌ្ឍសមត្ថភាពលើការស្រាវជ្រាវ និងតាក់តែងអត្ថបទបន្ថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណនៃសំណង់បណ្តោះអាសន្នលើដីរដ្ឋ

**១.១. សញ្ញាណគតិយុត្តនៃដីរដ្ឋ** ........ ៥

**១.១.១. ប្រភពនៃដីរដ្ឋ** ........ ៦

**១.១.២. ចំណាត់ថ្នាក់នៃដីរដ្ឋ** ........ ៧

១.១.២.១. ដីសាធារណៈរបស់រដ្ឋ ........ ៧

១.១.២.២. ដីឯកជនរបស់រដ្ឋ ........ ៨

**១.១.៣. ការផ្លាស់ប្តូរស្ថានភាពគតិយុត្តនៃដីរដ្ឋ** ........ ៩

១.១.៣.១. អនុប្បយោគ ........ ៩

១.១.៣.២. អធិប្បយោគ ........ ៩

**១.២. ទស្សនទាននៃសំណង់** ........ ៩

**១.២.១. ប្រភេទនៃសំណង់** ........ ១០

១.២.១.១. សំណង់ស្របច្បាប់ ........ ១០

១.២.១.២. សំណង់មិនស្របច្បាប់ ........ ១១

**១.២.២. សញ្ញាណនៃសំណង់បណ្តោះអាសន្ន** ........ ១១

**១.៣. មូលហេតុនៃការតាំងទីលំនៅលើដីរដ្ឋ** ........ ១២

**១.៣.១. កត្តាសេដ្ឋកិច្ច** ........ ១២

**១.៣.២. ការទទួលបានព័ត៌មានមិនគ្រប់គ្រាន់** ........ ១៣

**១.៣.៣. កត្តាកំណើនប្រជាជន** ........ ១៤

## ជំពូកទី២

## ការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរដ្ឋ

២.១. វិធានការចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ............................... ១៥

២.១.១. ដីសម្បទានសង្គមកិច្ច.............................................................................................១៥

២.១.១.១. គោលបំណងដីសម្បទានសង្គមកិច្ច.........................................................................១៥

២.១.១.២. សិទ្ធិលើដីសម្បទានសង្គមកិច្ច........................................................................... ១៦

២.១.១.៣. ទំហំនៃផ្ដល់ដីសម្បទាន ..................................................................................... ១៧

២.១.១.៤. សម្បទានដីសង្គមកិច្ច និងសហគមន៍ក្រីក្រ.......................................................... ១៨

២.១.២. ការបណ្ដេញចេញ និងកាតព្វកិច្ចរបស់រដ្ឋចំពោះការបណ្ដេញចេញ ........................................២០

២.១.២.១. ការបណ្ដេញចេញ..................................................................................................២០

២.១.២.២. កាតព្វកិច្ចរបស់រដ្ឋចំពោះការបណ្ដេញចេញ ..........................................................២០

២.១.២.៣. ការបណ្ដេញចេញក្នុងអំឡុងពេលជំងឺកូវីដ-១៩ ..................................................... ២២

២.១.៣. ការអភិវឌ្ឍនៅនឹងកន្លែង...........................................................................................២៣

២.១.៤. ការចោទប្រកាន់តាមផ្លូវតុលាការ ...............................................................................២៤

២.១.៥. គោលនយោបាយរាជរដ្ឋាភិបាលចំពោះសំណង់បណ្ដោះអាសន្នដែលខុសច្បាប់ ...................២៥

២.១.៥.១. យុទ្ធសាស្ត្រចតុកោណ........................................................................................២៥

២.១.៥.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី.......................................................... ២៦

២.១.៥.៣. គោលនយោបាយដីធ្លី ......................................................................................... ២៧

២.២. លក្ខខណ្ឌនៃលំនៅឋានសមរម្យ ........................................................................ ៣១

២.២.១. សញ្ញាណនៃលំនៅឋាន .............................................................................................៣២

២.២.២. សញ្ញាណនៃលំនៅឋានសមរម្យ ...................................................................................៣២

២.២.២.១. អត្ថិភាពនៃសិទ្ធិមានលំនៅឋានសមរម្យក្នុងច្បាប់ជាតិ...............................................៣៣

២.២.២.២. អត្ថិភាពនៃសិទ្ធិមានលំនៅឋានសមរម្យក្នុងច្បាប់អន្តរជាតិ និងតំបន់....................... ៣៦

២.២.៣. ធាតុផ្សំនៃលំនៅឋានសមរម្យ .....................................................................................៤០

២.២.៣.១. សុវត្ថិភាពក្នុងការកាន់កាប់ .................................................................... ៤០
២.២.៣.២. ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អគារ ឬកន្លែងផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធ.. ៤៣
២.២.៣.៣. ភាពអាចលៃលកបាន.................................................................... ៤៤
២.២.៣.៤. ភាពអាចរស់នៅបាន .................................................................... ៤៥
២.២.៣.៥. ភាពអាចប្រើប្រាស់បាន .................................................................... ៤៥
២.២.៣.៦. ទីតាំង .................................................................... ៤៥
២.២.៣.៧. ភាពសមរម្យផ្នែកវប្បធម៌ និងប្រពៃណី .................................................................... ៤៥
**សេចក្តីសន្និដ្ឋាន** .................................................................... ៤៧
**អនុសាសន៍** .................................................................... ៤៨
**គន្ថនិទ្ទេស**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជាជាប្រទេស ដែលបានហែលឆ្លងកាត់សង្គ្រាមជិតបីទសវត្ស ប្រជាជនរស់នៅជាមួយទឹកភ្នែក និងក្តីទុក្ខលំបាក ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានបំផ្លិចបំផ្លាញនូវធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធគ្មានសល់ ចំណែកឯបណ្តាលិខិតបទដ្ឋានគតិយុត្តនានា ក៏ត្រូវបានបាត់បង់ស្ទើរតែទាំងស្រុង។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ កម្ពុជាបានងើបចេញពីភ្លើងសង្គ្រាមហើយចាប់ផ្តើមអភិវឌ្ឍខ្លួនបន្តិចម្តងៗ លើគ្រប់វិស័យ។ ក្នុងនោះផងដែរកម្ពុជាក៏ចាប់ផ្តើមការងារយ៉ាងសកម្មលើការស្តារប្រព័ន្ធច្បាប់សារជាថ្មី បន្ទាប់ពីមានការបាត់បង់ក្នុងកំឡុងពេលសង្គ្រាម ជាពិសេសការតាក់តែងក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការរៀបចំដែនដីនគរូបនីយកម្ម ដែលមានភាពចាំបាច់ ក្នុងការចូលរួមចំណែកក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិឡើងវិញ។ លុះមកដល់ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីត្រូវបានអនុម័តដោយសភាធម្មនុញ្ញ ដែលកើតចេញពីការបោះឆ្នោត រៀបចំដោយអង្គការសហប្រជាជាតិ ហើយត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញថ្មីនេះបានទទួលស្គាល់ពេញលេញនូវកម្មសិទ្ធិឯកជន ដែលបានផ្តល់ដល់ប្រជាពលរដ្ឋកម្ពុជាទទួលបាននូវភាពជាម្ចាស់លើកម្មសិទ្ធិឯកជនចំពោះអចលនវត្ថុ។

បើទោះបីជាមានការបែងចែកកម្មសិទ្ធិនៃដី ជាដីឯកជន និងដីរដ្ឋយ៉ាងច្បាស់លាស់ក៏ដោយ ក៏នៅតែមានស្ថានភាពមួយចំនួនដែលទាក់ទងទៅនឹងការរំលោភលើដីរដ្ឋ តាមរយៈការតាំងទីលំនៅដូចជាការសាងសង់សំណង់ផ្សេងៗដែលវាទទីនៅលើដីរដ្ឋ ក្រោមរូបភាពជាសំណង់អនាធិបតេយ្យ ឬសំណង់មិនរៀបរយជាអាទិ៍។ ក្រៅពីនេះក៏មានការទាមទារពីសំណាក់សហគមន៍ និងប្រជាពលរដ្ឋដែលទទួលរងបណ្តឹងពីតុលាការចំពោះការកាន់កាប់លើដីរដ្ឋដោយខុសច្បាប់ ដោយបានអះអាងថារដ្ឋបានរំលោភលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ត្បិតខ្លួនបានកាន់កាប់លើដីនោះអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ស្របពេលជាមួយគ្នានឹងការអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញនូវអចលនវត្ថុ ពីសំណាក់ភាគីរដ្ឋ យន្តការផ្សេងៗត្រូវបានអនុវត្តដើម្បី សម្របសម្រួលចំពោះជនដែលបានសាងសង់សំណង់នៅលើដីរដ្ឋដោយខុសច្បាប់នោះ។ ដូចជាការផ្តល់ជូននូវសំណងដោយសមរម្យការផ្តល់ជូននូវលំនៅឋានដែលស្ថិតនៅលើទីតាំងថ្មីជាដើម ដែលស្តែងឡើងតាមរយៈគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងយន្តការនៃការដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋ ដែលស្របតាមក្របខណ្ឌច្បាប់អន្តរជាតិរួមមានសិទ្ធិទទួលបានលំនៅឋានសមរម្យដែលមានចែងនៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

## ២. ចំណោទបញ្ហា

បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញ ការគិតគូរលើការងារតាក់តែង និងការធ្វើបច្ចុប្បន្នភាពនៃច្បាប់ពិតជាមានសារៈសំខាន់។ ក្នុងនោះក្របខណ្ឌច្បាប់ដែលទាក់ទងទៅវិស័យដីធ្លី ពិតជាមានភាពចាំបាច់ដែលទាមទារឱ្យរដ្ឋធ្វើការរៀបចំនូវវិធានមួយច្បាស់លាស់ ដែលកំណត់ និងគ្រប់គ្រងលើស្ថានភាពគតិយុត្តពាក់ព័ន្ធនឹងដីធ្លី។ បន្ទាប់ពីច្បាប់ភូមិបាលថ្មីបានប្រកាសឱ្យប្រើ មូលដ្ឋានច្បាប់សម្រាប់ការងារគ្រប់គ្រងដីធ្លីគឺត្រូវបានបំពេញ។ ក៏ប៉ុន្តែច្បាប់នេះ មិនបានធ្វើការកំណត់អំពីការដោះស្រាយទៅលើបញ្ហាដ៏រ៉ាំរ៉ៃចំពោះការសាងសង់សំណង់បណ្ដោះអាសន្នលើដីរដ្ឋនោះទេ ដែលជាកត្តាធ្វើឱ្យប៉ះពាល់ដល់ការរៀបចំទីក្រុង ក៏ដូចជាបង្កឱ្យមានភាពអសន្តិសុខ និងភាពអនាធិបតេយ្យនៅក្នុងសង្គម។ ដូចនេះហើយរាជរដ្ឋាភិបាលកម្ពុជាបានខិតខំរៀបចំ និងដាក់ចេញនូវវិធានការផ្សេងៗ ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយ ដែលស្តែងឡើងតាមរយៈគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសារាចររបស់រាជរដ្ឋាភិបាលជាដើម។ ជាក់ស្តែងសារាចរលេខ ០៣.សរ ស្តីពីការដោះស្រាយ សំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាម រាជធានី ទីក្រុង និងទីប្រជុំជន បូករួមជាមួយនឹងគោលនយោបាយផ្សេងៗជាអាទិ៍គោលនយោបាយស្តីពីការគ្រប់គ្រងដីរដ្ឋ និងគោលនយោបាយជាតិស្តីពីលំនៅឋានជាដើម ដែលបានផ្តល់ដល់អ្នកស្នាក់នៅដែលជាម្ចាស់សំណង់ បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការរុះរើ និងផ្លាស់ប្តូរទៅទីតាំងថ្មីដោយសន្តិវិធី ឬអាចទទួលបានការអភិវឌ្ឍនៅនឹងកន្លែង។ ផ្ទុយទៅវិញ ការដោះស្រាយតាមរយៈយន្តការខាងលើនេះ មិនអាចអនុវត្តបានគ្រប់ស្ថានភាព និងបានដោយជោគជ័យមួយរយភាគរយចំពោះគ្រប់វិវាទទាំងអស់នោះទេ។ ដូចនេះហើយ ទើបបានជានៅតែមានភាពចម្រូងចម្រាស់ដែលកើតឡើងរវាងប្រជាជន និងរដ្ឋលើវិស័យដីធ្លីនេះជាបន្តបន្ទាប់។ ដោយមើលឃើញថាការដោះស្រាយ ចំពោះប្រជាជនដែលរស់នៅក្នុងទីតាំងសំណង់បណ្ដោះអាសន្ន មានភាពចាំបាច់ដែលមិនអាចខ្វះបាន ទើបយើងខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់។ ដែលនេះគឺជាហេតុធ្វើឱ្យយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ ការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរដ្ឋនៅកម្ពុជា ធ្វើជាសារណាបញ្ចប់ការសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ទាក់ទងជាមួយនឹងប្រធានបទខាងលើ សំណួរគតិយុត្តមួយចំនួនត្រូវបានលើកឡើងជាអាទិ៍រួមមាន តើក្នុងប្រព័ន្ធច្បាប់កម្ពុជាសំណង់ប្រភេទណា ដែលចាត់ទុកជាសំណង់បណ្ដោះអាសន្នលើដីរដ្ឋដោយខុសច្បាប់? តើមានយន្តការនៃការដោះស្រាយអ្វីខ្លះ ដើម្បីឆ្លើយតបទៅនឹងសំណង់ដែលខុសច្បាប់ទាំងអស់នោះ? ហើយការដោះស្រាយនោះទទួលបានបានលទ្ធផលយ៉ាងដូចម្តេចដែរ? ដែលសំណួរទាំងនេះនឹងក្លាយជាចំណោទបញ្ហានៅក្នុងការស្រាវជ្រាវលើប្រធានបទនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវលើប្រធានបទនេះ គឺមានគោលដៅសំខាន់ក្នុងការបង្ហាញពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងដីធ្លីកន្លងមក។ ជាពិសេសសារាចរណែនាំរបស់រាជរដ្ឋាភិបាលរួមមានជាអាទិ៍ សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន និងសារាចរស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងស្នាដៃសារណាបញ្ចប់ការសិក្សានេះ ធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងវិស័យភូមិបាល និងគោលនយោបាយរបស់រាជរដ្ឋាភិបាល រួមមានច្បាប់ភូមិបាលឆ្នាំ ២០០១ គោលនយោបាយស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៤ គោលនយោបាយជាតិស្តីពីលំនៅឋានឆ្នាំ២០១៤ និងគោលនយោបាលដីធ្លីឆ្នាំ២០១៥ ជាដើម។ បន្ថែមពីលើនេះយើងក៏បានធ្វើការសិក្សាទាក់ទងជាមួយនឹងសារាចរផ្សេងៗដែលបានកំណត់អំពីការដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋ រួមមានសារាចរលេខ ០២ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ឆ្នាំ២០០៧ សារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជនឆ្នាំ ២០១០ និងសារាចរលេខ០៦ ស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការឆ្នាំ២០១៩។ នៅក្នុងសារណានេះនឹងត្រូវបានបង្ហាញអំពីយន្តការនៃការដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើរបស់រដ្ឋដោយខុសច្បាប់នៅកម្ពុជា និងក្របខណ្ឌច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ញត្តិអំពីសញ្ញាណផ្សេងៗនៃដីរដ្ឋ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទនេះ គឺផ្តល់ជាពុទ្ធិចំណេះដឹង ជូនមិត្តនិស្សិត និងអ្នកអានទាំងឡាយក្នុងការត្រិះរិះពិចារណា លើបញ្ហានៃការដោះស្រាយចំពោះសំណង់បណ្តោះអាសន្ននៅលើដីរបស់រដ្ឋ។ ម្យ៉ាងវិញទៀតប្រធានបទនេះក៏បានជួយជាគំនិត និងភាពងាយស្រួលសម្រាប់ការសិក្សាស្រាវជ្រាវ លើក្របខណ្ឌច្បាប់ដែលទាក់ទងនឹងការដោះស្រាយបញ្ហាដីធ្លីនៅកម្ពុជា។ ក្នុងនោះផងដែលស្នាដៃសារណានេះគឺបានឆ្លើយតបទៅនឹងតម្រូវការ នៃឯកសារពិគ្រោះដែលទាក់ទងទៅនឹងវិវាទដីធ្លី ដោយហេតុពុំសូវមានអត្ថបទ ដែលសរសេរទាក់ទងនឹងការដោះស្រាយចំពោះបញ្ហា ទាំងអស់ខាងលើនេះទេ។ ក្រៅពីនេះការស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីចូលរួមចំណែកក្នុងការពង្រីកការយល់ដឹងដែលទាក់ទងនឹងវិស័យសាធារណៈ ជាពិសេសសិទ្ធិភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានរៀបរៀងឡើងដោយលើកយកបទដ្ឋានគតិយុត្ត និងគោលនយោបាយនានាមកធ្វើបកស្រាយពិពណ៌នាដោយវិភាគទៅលើទិដ្ឋភាពទូទៅ និងការអនុវត្តជាក់ស្តែង។ បន្ថែមពីលើនេះសារណានេះក៏បានរួមបញ្ចូលនូវព័ត៌មាន និងទិន្នន័យដែលបានមកពីប្រភពផ្សេងរួមមាន ច្បាប់អន្តរជាតិសកល និងក្នុងតំបន់ របាយការណ៍របស់សាលារាជធានី អង្គការសង្គមស៊ីវិល សៀវភៅ និង ជើនណល (Journal) ឯកសារបង្រៀន និក្ខេបបទ របាយការណ៍ សាលាកប័ត្រព័ត៌មាន ឯកសារបង្រៀនរបស់សាស្ត្រាចារ្យផ្សេងៗ និងគេហទំព័រផ្សេងៗ ដែលជាកត្តាមួយធ្វើឱ្យការស្រាវជ្រាវលើប្រធានបទនេះមានភាពត្រឹមត្រូវ និងច្បាស់លាស់ស្របតាមគោលការណ៍គតិយុត្ត។ ក្នុងនោះក៏មានការសម្ភាសន៍ផ្ទាល់ជាមួយអ្នករងផលប៉ះពាល់ដោយសារគ្មានលំនៅឋានពិតប្រាកដផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងជំពូកទី១ នៃការស្រាវជ្រាវនេះគឺធ្វើការសិក្សាទៅលើសញ្ញាណនៃសំណង់បណ្តោះអាសន្ន ដែលពុំមានបញ្ជាក់ច្បាស់នៅក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្តណាមួយឡើយ។ តែជាការសង្កេត សំណង់បណ្តោះអាសន្នវាជាសំណង់ដែលបានសង់លើដីរដ្ឋដែលអាចជាដី សារធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ។ ហើយជំពូកទី២ គឺបង្ហាញពីបញ្ហាសង្គ្រាម សេដ្ឋកិច្ច និងកំណើនប្រជាជន ជាមូលហេតុដែលបណ្តាលឱ្យមានការសំណង់បណ្តោះអាសន្នទាំងនេះឡើង។ ត្បិតតែប្រជាពលរដ្ឋបានមករស់នៅលើដីរដ្ឋដោយខុសច្បាប់យ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលមានការយកចិត្តទុកដាក់បានបង្កើតនូវគោលនយោបាយជាច្រើនក្នុងការដោះស្រាយបញ្ហានៃការសង់សំណង់បណ្តោះអាសន្នលើដីរដ្ឋនេះ។

# ជំពូកទី១៖
# សញ្ញាណនៃសំណាក់បណ្តោះអាសន្នលើដីរដ្ឋ

# ជំពូកទី១

# សញ្ញាណនៃសំណង់បណ្តោះអាសន្នលើដីរដ្ឋ

សំណង់ត្រូវបានបែងចែកចេញជាច្រើនភេទ ទៅតាមស្ថានភាពគតិយុត្តផ្សេងៗពីគ្នា ក្នុងនោះ សំណង់បណ្តោះអាសន្នលើដីរដ្ឋ ស្តែងឡើងជាសំណង់អាណាធិបតេយ្យ ឬសំណង់មិនរៀបរយ។ ភាគច្រើននៃសំណង់ប្រភេទនេះគឺតាំងទីនៅលើដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ហើយជាទូទៅសំណង់ទាំងនេះច្រើនសង់នៅតាមប្រឡាយទឹក និងនៅតាមផ្លូវសាធារណៈជាដើម។ ដើម្បីអាចធ្វើការកំណត់បាននូវសំណង់ប្រភេទណាដែលជាសំណង់ដែលសាងសង់នៅលើដីរដ្ឋនោះ គឺចាំបាច់ត្រូវតែពិនិត្យមើលទៅលើលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធជាមុនសិន។

## ១.១. សញ្ញាណគតិយុត្តនៃដីរដ្ឋ

ដោយសារឥទ្ធិពលនៃសង្គ្រាម បានធ្វើឱ្យលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងដីធ្លីត្រូវបានបំផ្លិចបំផ្លាញចោល។ ហើយរបបនៃការគ្រប់គ្រងដីរដ្ឋក៏មានភាពខុសប្លែកពីគ្នាទៅតាមរបបនីមួយៗ។ ជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានលុបបំបាត់ចោលទាំងស្រុង ដោយទ្រព្យសម្បត្តិទាំងអស់ជាកម្មសិទ្ធិរួម ឬជារបស់អង្គការ។[1] ក្រោយមកនៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ របបកម្មសិទ្ធិលើដីធ្លី ពុំទាន់ត្រូវបានទទួលស្គាល់ពេញលេញនោះទេ។ ដីធ្លីទាំងអស់ជារបស់រដ្ឋ ចំណែកឯប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែប្រើប្រាស់ និងសិទ្ធិតំណមរតកលើដីធ្លីដែលរដ្ឋបានប្រគល់ឱ្យគ្រួសារនីមួយៗ សម្រាប់សង់លំនៅឋាន និងធ្វើសួនច្បារ ឬបន្លែប៉ុណ្ណោះ។[2] លុះដល់ឆ្នាំ ១៩៨៩ ក្នុងរបបរដ្ឋកម្ពុជា របបកម្មសិទ្ធិឯកជនលើដីធ្លី ក៏ពុំទាន់ត្រូវបានទទួលស្គាល់ភ្លាមដែរ ដោយរដ្ឋនៅតែជាម្ចាស់កម្មសិទ្ធិលើដីធ្លីទាំងអស់ដដែល។[3] នៅឆ្នាំ ១៩៩២ ច្បាប់ភូមិបាលត្រូវបានបង្កើតឡើងជាលើកដំបូង ដោយក្រឹត្យលេខ ១០០ ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ដោយក្នុងច្បាប់នេះកម្មសិទ្ធិត្រូវបានទទួលស្គាល់ចំពោះតែដីសម្រាប់សាងសង់លំនៅឋានតែប៉ុណ្ណោះ ចំណែកឯដីប្រភេទផ្សេងក្រៅពីលំនៅឋានដូចជាដីផលិតកម្ម ស្រែ ចម្ការ កសិដ្ឋាន ជាអាទិ៍ គឺមានតែសិទ្ធិភោគៈ ឬសិទ្ធិកាន់កាប់បណ្តោះអាសន្នតែប៉ុណ្ណោះ។ សិទ្ធិលើដីលំនៅឋាននេះនឹងត្រូវផុតរលត់ទៅវិញ ក្នុងករណីម្ចាស់កម្មសិទ្ធិខកខានមិនបានបង់ពន្ធ ឬអាករលើដីធ្លីជូនរដ្ឋ ក្នុងរយៈពេល៥ ឆ្នាំ ជាប់ៗគ្នា ហើយដីនោះនឹងក្លាយមកជាសម្បត្តិឯកជននៃ

[1] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៧៥, មាត្រា៤។

[2] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១, មាត្រា១៥។

[3] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១, មាត្រា១៧។

រដ្ឋ។[4] ក្រោយមកបន្ទាប់ពីបានប្រែក្លាយរបបរដ្ឋកម្ពុជា មកជាព្រះរាជាណាចក្រកម្ពុជា តាមរយៈរដ្ឋធម្មនុញ្ញដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានប្រកាសទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លី ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ទោះជាបុគ្គលក្តី ជាសមូហភាពក្តីគឺមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។[5]

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្នបានធ្វើការបែងចែកដីជាពីរប្រភេទ គឺដីឯកជន និងដីរដ្ឋ។ ក្នុងនោះដីរដ្ឋគឺសំដៅដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គលដើម្បីកាន់កាប់។[6] ជាគោលការណ៍អ្នកដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងដីរដ្ឋ គឺរដ្ឋដែលជាម្ចាស់នៃដីទាំងអស់ដែលមិនឋិតនៅក្រោមការកាន់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូលហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។[7] ការកំណត់មូលដ្ឋានគតិយុត្តនៃដីរដ្ឋមានលក្ខណៈស្មុគស្មាញ ដែលចាំបាច់ត្រូវពិចារណាលើប្រភពនៃដីនោះ ដើម្បីមានភាពងាយស្រួលក្នុងការកំណត់បាននូវស្ថានភាពគតិយុត្តនៃដីរដ្ឋ។

### ១.១.១. ប្រភពនៃដីរដ្ឋ

ការកំណត់អំពីប្រភពនៃដី គឺមានលក្ខណៈសំខាន់សម្រាប់ការធ្វើអត្តសញ្ញាណកម្មនៃដី ដើម្បីមានភាពងាយស្រួលក្នុងការបែងចែកនូវស្ថានភាពគតិយុត្តនៃដីតាមប្រភេទនីមួយៗ។ ដីរដ្ឋមានប្រភពមកពីដីដែលកើតឡើងតាមធម្មជាតិ ឬបង្កើតឡើងដោយមនុស្សជាតិ ហើយដែលមិនមែនជាកម្មសិទ្ធិឯកជន។[8] ក្រៅពីនេះដីរដ្ឋក៏អាចមានប្រភពមកពីការធ្វើលទ្ធកម្មនៃកម្មសិទ្ធិ មកជាដីរដ្ឋដោយប្រើប្រាស់ ឬមិនប្រើប្រាស់ថវិការដ្ឋ ដូចជាការទិញ អស្សាមិករណ៍ ប្រទានកម្ម[9] អច្ច័យទាន ទ្រព្យនិទាយាទ ទ្រព្យគ្មានម្ចាស់គ្រប់គ្រង ការរឹបអូសដោយសេចក្តីសម្រេចស្ថាពររបស់តុលាការព្រមទាំងដីដែលរដ្ឋទទួលបានដោយមធ្យោបាយស្របច្បាប់ផ្សេងទៀត។[10] ការ

---

[4] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២, មាត្រា១៨ ។

[5] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤៤។

[6] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ៧ តុលា ២០០៥, មាត្រា២ (ចាប់ពីពេលនេះទៅហៅថាអនុក្រឹត្យលេខ១១៨អនក្រ/បក)។

[7] អនុក្រឹត្យ លេខ១១៨អនក្រ/បក, មាត្រា៣។

[8] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, លេខ នស/រកម/១១២០/០៣០, ១៤ វិច្ឆិកា ២០២០, មាត្រា៤ (ពីពេលនេះតទៅហៅថាច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ)។

[9] សទ្ទានុក្រមពាក្យច្បាប់ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, លេខរៀង៩៩ "ប្រទានកម្ម គឺជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យទៅភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។"

[10] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, មាត្រា៦ (ខ)។

អនុវត្តការគ្រប់គ្រងដីរដ្ឋ ត្រូវប្រព្រឹត្តទៅក្រោមក្របខណ្ឌច្បាប់ជាធរមាន ដែលការគ្រប់គ្រងលើដីរដ្ឋនេះ ក៏មានលក្ខណៈខុសប្លែកគ្នាផងដែរ ដោយអាស្រ័យទៅលើចំណាត់ថ្នាក់នៃដីរដ្ឋ ដែលច្បាប់កម្ពុជាបានធ្វើការកំណត់ទុក។

### **១.១.២. ចំណាត់ថ្នាក់នៃដីរដ្ឋ**

ការធ្វើចំណាត់ថ្នាក់នៃដី គឺជាដំណើរការនៃការធ្វើសេចក្តីសម្រេចផ្នែករដ្ឋបាលលើក្បាលដីរដ្ឋ។ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋអាចធ្វើឡើងក្នុងដំណើរការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ឬអាចធ្វើឡើងនៅពេលមានតម្រូវការដីឯកជនរបស់រដ្ឋ សម្រាប់បែងចែកតាមរយៈគម្រោងសម្បទានដីសេដ្ឋកិច្ច គម្រោងដីសម្បទានសង្គមកិច្ច លក់ ដោះដូរ ឬជួលដីរដ្ឋ។ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋត្រូវចាត់ទុកថាបានសម្រេចតាមផ្លូវច្បាប់ ក្រោយពេលដែលក្បាលដីនោះត្រូវបានចុះក្នុងបញ្ជីថាជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ។[11]

ដីរដ្ឋអាចត្រូវបានធ្វើចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋតាមរយៈការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ អនុលោមតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំអនុលោមតាមអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីដាច់ដោយដុំ។[12] ឋានៈជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនឹងត្រូវបានបង្ហាញតាមរយៈការចុះបញ្ជី។ ប្រសិនបើការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋត្រូវបានធ្វើចប់មុនការចុះបញ្ជី ដោយគ្មានការអះអាងណាមួយរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមិនស្របគ្នា ឬទោះបីមិនទាន់មានការធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋក្តី ប៉ុន្តែមានព័ត៌មានដែលអាចឱ្យធ្វើការសន្និដ្ឋានបានអំពីឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ ហើយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងឡាយក៏មានការឯកភាពមតិគ្នាលើឋានៈនៃដីនោះថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។[13]

#### **១.១.២.១. ដីសាធារណៈរបស់រដ្ឋ**

ដីសាធារណៈរបស់រដ្ឋសំដៅដល់ដីទាំងឡាយណា ដែលបម្រើឱ្យផលប្រយោជន៍សាធារណៈរួមបញ្ចូលទាំងដីដែលមានប្រភពពីធម្មជាតិដូចជា ទន្លេ បឹងបួរ និងភ្នំ។ ក្រៅពីនេះ ក៏ត្រូវបានចាត់ទុកជាដីសាធារណៈរបស់រដ្ឋផងដែរ ចំពោះអចលនវត្ថុដែលត្រូវបានអភិវឌ្ឍន៍ជាពិសេសសម្រាប់ប្រើប្រាស់ទូទៅដូចជា កំពង់ផែ ផ្លូវដែក និងព្រលានយន្តហោះ អចលនវត្ថុសម្រាប់ប្រើប្រាស់ជាសាធារណៈរួមមាន ផ្លូវថ្នល់ ផ្លូវលំ និងសួនច្បារសាធារណៈ អចលនវត្ថុដែលត្រូវបានបែងចែកដើម្បីផ្តល់សេវាសាធារណៈ (សាលារៀន មន្ទីរពេទ្យ និងអគាររដ្ឋបាល) តំបន់

---

[11] ប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៤២ដនស/ប្រក, ១០ មីនា ២០០៦, ប្រការ២៧។

[12] អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា៨។

[13] អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា៩។

ការពារ តំបន់បេតិកភណ្ឌ ប្រវត្តិសាស្ត្រ និងទ្រព្យសម្បត្តិផ្លូវការរបស់ខ្សែព្រះរាជវង្ស។[14] ដីសាធារណៈរបស់រដ្ឋមិនអាចជាកម្មវត្ថុ នៃការធ្វើលទ្ធកម្មកម្មសិទ្ធិបានឡើយទោះបីក្នុងករណីណាក៏ដោយ ហើយអ្នកកាន់កាប់លើដីរបស់រដ្ឋនៅតែមិនទៀងទាត់ និងខុសច្បាប់ដដែលប្រសិនជាស្ថានភាពមិនចេញពីការអនុញ្ញាតតាមបែបផែនដែលកំណត់ក្នុងច្បាប់ភូមិបាលទេនោះ។[15] ប៉ុន្តែដីសាធារណៈរបស់រដ្ឋអាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្ន ហើយអាចដកហូតវិញបាន បើមិនបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ។[16] ក្រៅពីនេះនឹងត្រូវចាត់ទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ចំពោះការកាន់កាប់ដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬជារបស់នីតិបុគ្គលសាធារណៈ និងរាល់បំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះកើតមាននៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក ឬការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់ភូមិបាលចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម និងរាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន។[17]

### ១.១.២.២. ដីឯកជនរបស់រដ្ឋ

ដីឯកជនរបស់រដ្ឋ គឺសំដៅរាល់អចលនវត្ថុទាំងឡាយដែលជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែមិនបម្រើឱ្យផលប្រយោជន៍សាធារណៈ ពោលគឺដីដែលមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។ ក្នុងនោះផងដែរដីឯកជនរបស់រដ្ឋមានរួមបញ្ចូលទាំងទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។[18] ដីឯកជនរបស់រដ្ឋអាចជាកម្មវត្ថុ នៃការលក់ដូរ ការផ្ទេរ និងការជួល ដូចជាការជួលរយៈពេលវែង និងសម្បទានដី។[19] ប្រសិនបើដីសាធារណៈរបស់រដ្ឋបាត់បង់តម្លៃខាងប្រើប្រាស់ដល់ផលប្រយោជន៍សាធារណៈ វាអាចនឹងត្រូវបានចាត់ថ្នាក់ឡើងវិញជាដីឯកជនរបស់រដ្ឋ ដូចនេះអាចយកមកជួល ធ្វើសម្បទាន ដោះដូរ ឬលក់បាន។

---

[14] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៥ (ពីពេលនេះតទៅហៅថាច្បាប់ភូមិបាល) និងអនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា៥។

[15] ច្បាប់ភូមិបាល, មាត្រា៤៣។

[16] ច្បាប់ភូមិបាល, មាត្រា១៦។

[17] ច្បាប់ភូមិបាល, មាត្រា១៨។

[18] អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា១៥។

[19] អនុក្រឹត្យលេខ១១៨អនក្រ/បក, មាត្រា១៧។

យ៉ាងណាមិញការកំណត់អំពីចំណាត់ថ្នាក់នៃដី ដែលជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ដូចដែលបានរៀបរាប់ខាងលើនេះ អាចត្រូវបានធ្វើចំណាត់ឡើងវិញតាមរយៈការធ្វើអនុប្បយោគ និងអធិប្បយោគ។

### ១.១.៣. ការផ្លាស់ប្តូរស្ថានភាពគតិយុត្តនៃដីរដ្ឋ

#### ១.១.៣.១. អនុប្បយោគ

អនុប្បយោគ គឺជាការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋចំពោះ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលនៅទំនេរលែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬការផ្តល់សេវាសាធារណៈ និងបាត់បង់លក្ខណៈសម្បត្តិក្នុងការបម្រើប្រយោជន៍សាធារណៈ លែងជាការប្រើប្រាស់ដោយផ្ទាល់ដោយសាធារណៈជន។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០២២ ផ្ទៃដីបឹងតាមោកយ៉ាងហោចណាស់ជិត ៧០០ ហិចតាត្រូវបានកាត់ឱ្យស្ថាប័នរដ្ឋ និងឯកជន ដែលការកាត់នេះធ្វើឡើងតាមការធ្វើអនុប្បយោគ ដោយហេតុបឹងនេះបានបាត់បង់ប្រយោជន៍ជាសាធារណៈទៅហើយ។ ការធ្វើអនុប្បយោគនេះត្រូវកំណត់ដោយច្បាប់ ចំណែកឯនីតិវិធីនៃការធ្វើអនុប្បយោគ ត្រូវកំណត់ដោយអនុក្រឹត្យ[20] ហើយការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិទាំងឡាយណាដែលបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋរួចហើយ[21]។

#### ១.១.៣.២. អធិប្បយោគ

អធិប្បយោគ សំដៅដល់ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ មកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ចំពោះទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលមានតម្រូវការ នៃការបម្រើផលប្រយោជន៍សាធារណៈ ឬការផ្តល់សេវាសាធារណៈ។ ក្រោយការធ្វើអធិប្បយោគ ទ្រព្យសម្បត្តិទាំងនោះមិនអាចជាកម្មវត្ថុនៃការលក់ដូរ សម្បទាន ការផ្ទេរកម្មសិទ្ធិ និងការជួលបានទៀតនោះទេ។ វិធាននៃការធ្វើអធិប្បយោគត្រូវកំណត់ដោយច្បាប់ ហើយនីតិវិធីលម្អិតនៃការធ្វើអធិប្បយោគត្រូវកំណត់ដោយអនុក្រឹត្យ។[22]

## ១.២. ទស្សនទាននៃសំណង់

ស្របជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃសេដ្ឋកិច្ចកម្ពុជា បូករួមជាមួយនឹងការកើនឡើងនៃកំណើនប្រជាជន ដែលហេតុធ្វើឱ្យមានតម្រូវការនៃលំនៅឋានដែលស្តែងឡើងតាមរយៈការសាងសង់សំណង់ផ្សេងៗជាអាទិ៍កាន់តែមានភាពចាំបាច់។ យ៉ាងណាមិញទោះក្នុងរូបភាពណាក៏ដោយ សំណង់

---

[20] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, មាត្រា២៧។
[21] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, មាត្រា២៨។
[22] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, មាត្រា២៩។

ទាំងអស់នោះត្រូវស្របទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាជាចម្បង។ ជាក់ស្ដែងដើម្បីអាចរក្សាបាននូវស្តង់ដាជាក់លាក់មួយនៃសំណង់ ព្រះរាជាណាចក្រកម្ពុជាបានកំណត់គោលការណ៍ចំនួនប្រាំ នៃសំណង់សម្រាប់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាម ក្នុងនោះរួមមាន៖

- ការពារផលប្រយោជន៍សាធារណៈ និងសិទ្ធិបុគ្គល
- ប្រសិទ្ធិភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដី និងនគរូបនីយកម្ម
- អភិវឌ្ឍន៍បៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សា និងលើកកម្ពស់អត្តសញ្ញាណជាតិ។

គោលការណ៍ដែលបានរៀបរាប់ខាងលើនេះ គឺចាំបាច់ត្រូវតែអនុវត្តតាមជាដាច់ខាតទើបអាចទទួលបានការអនុញ្ញាតឱ្យសាងសាង់ពីអាជ្ញាធរមានសមត្ថកិច្ច។ ក្រោយពីធានាបានថាសំណង់ដែលបានសាងសង់ត្រូវបានគោរពតាមគោលការណ៍ទាំងប្រាំខាងនេះហើយ ជំហានបន្ទាប់គេត្រូវដឹងអំពីប្រភេទនៃសំណង់នោះថាតើសំណង់ដែលបានសាងសង់នោះមានលក្ខណៈជាសំណង់ដែលស្របច្បាប់ ឬជាសំណង់ដែលខុសច្បាប់ ដោយពិចារណាទៅលើលក្ខខណ្ឌនានាដែលបានកំណត់ដោយច្បាប់។

### ១.២.១. ប្រភេទនៃសំណង់

សំណង់ត្រូវបានបែងចែកចេញច្រើនទម្រង់ អាស្រ័យទៅតាមគោលបំណងនៃការសាងសង់ដែលស្របនឹងផលប្រយោជន៍របស់អ្នកសាងសង់ ហើយជាទូទៅសំណង់សំដៅដល់ អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់ទៅនឹងដីទោះមាន ឬគ្មានជញ្ជាំង ឬដំបូលក៏ដោយ។ ឧទាហរណ៍៖ សណ្ឋាគារ អាផាតមែន ខុនដូការិយាល័យ រោងចក្រ ឃ្លាំង ផ្សារទំនើប សំណង់អគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ចំណតរថយន្ត។[23] ដោយពិនិត្យទៅលើទិដ្ឋភាពច្បាប់របស់កម្ពុជា គេអាចកំណត់បានថា សំណង់ត្រូវបានបែងចែកចេញជាពីរប្រភេទ គឺសំណង់ស្របច្បាប់ និងសំណង់មិនស្របច្បាប់។

#### ១.២.១.១. សំណង់ស្របច្បាប់

ដើម្បីអាចកំណត់បានថា សំណង់ណាមួយជាសំណង់ដែលស្របច្បាប់នោះ ការពិចារណាទៅលើលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងដីធ្លីគឺពិតជាមានសារៈសំខាន់។ ជាគោលការណ៍រាល់ការសាងសង់សំណង់នានាត្រូវគោរពទៅតាមលក្ខខណ្ឌផ្សេងៗ ដែលមានកំណត់នៅក្នុងច្បាប់ដែលពាក់ព័ន្ធនឹងសំណង់របស់កម្ពុជារួមមានច្បាប់ស្ដីពីសំណង់ជាអាទិ៍។ ការសាងសង់សំណង់ផ្សេងៗ ជាទូទៅត្រូវមានការអនុញ្ញាតជាមុនដោយ

[23] ប្រកាសស្ដីពីការប្រមូលពន្ធលើអចលនទ្រព្យ, លេខ៤៩៣សហវ/ប្រក, ១៨ កក្កដា ២០១០, ប្រការ៣ (១.គ)។

អាជ្ញាធរមានសមត្ថកិច្ច[24] ប៉ុន្តែមិនតម្រូវឱ្យមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចទេ ចំពោះសំណង់ដែលមានទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬលំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើ ឬថ្មនៅទីជនបទ ឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ និងចំពោះសំណង់ដែលបម្រើដល់សន្តិសុខ និងការពារជាតិ។[25] ដើម្បីធានាបានថាសំណង់ស្របទៅតាមលក្ខណៈច្បាប់ និងមានលក្ខណៈស្តង់ដារសុវត្ថិភាព សំណង់ត្រូវគោរពតាមលក្ខខណ្ឌផ្សេងៗជាអាទិ៍រួមមាន ការសាងសង់ត្រូវអនុវត្តតាមគម្រោងប្លង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិជាធរមានដទៃទៀត។ ចំពោះការងារសាងសង់ទាំងឡាយដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។[26] មួយវិញទៀត សំណង់ទាំងឡាយដែលជាប់នឹងដី គឺត្រូវសាងសង់នៅលើដីដោយផ្អែកលើមូលដ្ឋានគតិយុត្តផ្សេងៗ ពោលគឺមិនធ្វើឡើងនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋនោះទេ។

#### ១.២.១.២. សំណង់មិនស្របច្បាប់

សំណង់ដែលមិនស្របច្បាប់ គឺសំណង់ដែលបានសាងសង់ឡើងដោយមិនគោរពទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ហើយវាស្តែងឡើងតាមរយៈសំណង់ផ្សេងៗដូចជាសំណង់អនាធិបតេយ្យ សំណង់មិនរៀបរយ សំណង់ក្នុងបរិវេណដីសាធារណៈ និងសំណង់បណ្តោះអាសន្នលើដីរដ្ឋជាដើម។ សំណង់ប្រភេទនេះ អាជ្ញាធរមានសមត្ថកិច្ចនឹងចាត់វិធានការកែសម្រួល ឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាត ឬសាងសង់ខុសពីខិតអនុញ្ញាតក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។[27]

### ១.២.២. សញ្ញាណនៃសំណង់បណ្តោះអាសន្ន

នៅក្នុងទិដ្ឋភាពទូទៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន អត្រាកំណើននៃការសាងសង់ដែលមានលក្ខណៈជាស្ថាបត្យការ្យមានច្រើនរូបភាពសម្បូរបែប ក្នុងនោះបទដ្ឋានគតិយុត្តកម្ពុជាបានធ្វើការកំណត់នូវស្ថានភាពសំណង់ទាំងអស់នោះ ឱ្យស្ថិតនៅក្នុងចង្កោមច្បាប់តែមួយ ដូចជាច្បាប់ស្តីពីសំណង់ជាអាទិ៍។

សំណង់ សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការ្យ ទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន ធ្វើឡើងដោយការប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬ

---

[24] ច្បាប់ស្តីពីសំណង់, មាត្រា២៧។

[25] ច្បាប់ស្តីពីសំណង់, មាត្រា២៨។

[26] ច្បាប់ស្តីពីសំណង់, មាត្រា៣៧។

[27] ច្បាប់ស្តីពីសំណង់, មាត្រា៥៦។

ផលិតផលសំណង់។[28] តាមខ្លឹមសារខាងលើនេះ សំណង់ត្រូវបានបែងចែកជាពីរ គឺសំណង់ដែលមានលក្ខណៈជាអចិន្ត្រៃយ៍ និងសំណង់ដែលមានលក្ខណៈជាបណ្តោះអាសន្ន ដែលសំណង់ទាំងអស់នោះត្រូវបានបង្កើតឡើងក្នុងគោលដៅផលប្រយោជន៍ផ្សេងៗគ្នា។ សំណង់បណ្តោះអាសន្នលើរដ្ឋ បើធ្វើការពិនិត្យទៅលើទិដ្ឋភាពទូទៅ គឺចង់សំដៅដល់ស្ថានភាពមួយដែលពាក់ព័ន្ធនឹងការសាងសង់សំណង់ផ្សេងៗ ក្នុងគោលដៅរយៈពេលខ្លី ហើយការសាងសង់នោះបានធ្វើឡើងលើដីរដ្ឋដែលអាចជាដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ជាទូទៅសំណង់ប្រភេទនេះច្រើន តែជាសំណង់ដែលមានលក្ខណៈខុសច្បាប់ ដោយពិចារណាទៅលើទិដ្ឋភាពច្បាប់កម្ពុជា រាល់ការងារសាងសង់ ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។[29] ក្នុងន័យនេះលិខិតអនុញ្ញាតសាងសង់ មិនត្រូវបានចេញដោយដោយអាជ្ញាធរមានសមត្ថកិច្ចនោះទេ ព្រោះសំណង់ប្រភេទនេះគឺបានសាងសង់នៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋ។

## ១.៣. មូលហេតុនៃការតាំងទីលំនៅលើដីរដ្ឋ

ការកំណត់ទីកន្លែងសម្រាប់ការតាំងទីលំនៅអាចធ្វើទៅ បានដោយសេរីស្របតាមស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ[30] ការតាំងទីលំនៅនោះអាចស្តែងឡើងក្រោមរូបភាពស្របច្បាប់ដូចជាការសាងសង់លើដីដែលជាកម្មសិទ្ធិរបស់ម្ចាស់សំណង់ ឬការសាងសង់ដោយផ្អែកតាមកិច្ចសន្យា ឬសកម្មភាពឯកតោភាគីផ្សេងៗ។ ចំណែកលំនៅឋានដែលមិនស្របច្បាប់នោះ គេអាចសង្កេតបានតាមរយៈទិដ្ឋភាពច្បាប់ផ្សេងៗ ដូចជាការសាងសង់សំណង់នៅលើដីរដ្ឋជាអាទិ៍។ ដើម្បីអាចធ្វើការដោះស្រាយបញ្ហាទាក់ទងនឹងការតាំងទីលំនៅលើដីរដ្ឋប្រកបដោយប្រសិទ្ធិភាពនោះ គេត្រូវសិក្សាទៅលើមូលហេតុនៃការកាន់កាប់របស់ប្រជាពលរដ្ឋដែលបណ្តាលមកពីកត្តាផ្សេងៗរួមផ្សំ។

### ១.៣.១. កត្តាសេដ្ឋកិច្ច

នៅក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ បើទោះបីជាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការកើនឡើងជាមធ្យមក្នុងរង្វង់ ៧% ទៅ៨%[31] ក៏ដោយ ក៏នៅតែមានប្រជាជនមួយចំនួនតូចដែលរស់ក្នុងដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ដែលក្នុងនោះគ្រួសារខ្លះមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញដី និងសាងសង់លំនៅឋានសមរម្យមួយសម្រាប់ជីវភាពរស់នៅបានទេ។ ផ្អែកលើមូលដ្ឋាននៃខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ខ្សែបន្ទាត់ភាពក្រីក្រតាមតំបន់ មានដូចខាងក្រោម៖

---

[28] សទ្ទានុក្រមច្បាប់ស្តីពីសំណង់, លេខរៀង២៧។

[29] ច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ០២ វិច្ឆិកា ២០១៩, មាត្រា២៦ (ចាប់ពីពេលនេះទៅហៅថាច្បាប់ស្តីពីសំណង់)។

[30] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤០។

[31] រាជរដ្ឋាភិបាល, *ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០*, ២០១៨, ៨។

- ១០,៩៥១រៀល ក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ នៅរាជធានីភ្នំពេញ
- ៩,៥៧១រៀល ក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ នៅតំបន់ទីប្រជុំជនផ្សេងទៀត និង
- ៨, ៩០៨រៀល ក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ នៅតំបន់ជនបទ

ប្រជាជនប្រមាណ១៧,៨% នៃប្រជាជនសរុបបានរស់នៅក្រោមខ្សែបន្ទាត់នេះ ក្នុងឆ្នាំ២០១៩-២០២០ ក្នុងនោះអត្រាភាពក្រីក្រនៅ៖

- រាជធានីភ្នំពេញ ៤,២%
- តំបន់ទីប្រជុំជនផ្សេងទៀត ១២,៦%
- តំបន់ជនបទ ២២,៨%។”[32]

ដោយពិនិត្យទៅតាមទិន្នន័យខាងលើនេះ ប្រជាជនមួយចំនួនជាពិសេសនៅតាមទីជនបទ និងទីប្រជុំជន នៅតែមានកង្វះខាតខាងសេដ្ឋកិច្ច ដែលជាកត្តាធ្វើឱ្យគាត់មិនអាចមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលបាននូវលំនៅឋានដែលជាកម្មសិទ្ធិរបស់ខ្លួនផ្ទាល់ និងជាហេតុធ្វើឱ្យមានការសាងសង់សំណង់ផ្សេងៗដែលនៅលើដីរដ្ឋខុសច្បាប់។ អស់រយៈពេលជាច្រើនទសវត្សមកហើយ ដែលប្រជាជនកម្ពុជាបានតាំងទៅលំនៅតាមទីប្រជុំជន នៅក្នុង និងនៅក្រៅរាជធានីដោយពុំមានច្បាប់ទម្លាប់ត្រឹមត្រូវ។ ការតាំងទីលំនៅនេះ គេឃើញមានសំណង់ភាគច្រើនបានសាងសង់ឡើងនៅតាមដីចំណីផ្លូវ ដីចំណីទន្លេ ឬបឹង ប្រព័ន្ធលូទឹក ផ្លូវរថភ្លើង ដីសាលារៀន មន្ទីរពេទ្យ សួនសាធារណៈ តំបន់ងាយរងគ្រោះ ដីតំបន់ហាមឃាត់ លើទីតាំងហេដ្ឋារចនាសម្ព័ន្ធនានា ដែលទាំងអស់នោះសុទ្ធតែជាដីសាធារណៈដែលជាកម្មសិទ្ធិរបស់រដ្ឋ។[33]

### ១.៣.២. ការទទួលបានព័ត៌មានមិនគ្រប់គ្រាន់

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យអប់រំបានច្រើនគួរឱ្យកត់សម្គាល់។ ហើយក្នុងនោះផងដែរប្រជាពលរដ្ឋកម្ពុជាក៏ទទួលបានការបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងរបបគតិយុត្ត ទាក់ទងនឹងសំណង់ និងដីធ្លីជាអាទិ៍ តាមរយៈយន្តការណ៍នៃការផ្សព្វផ្សាយច្បាប់ និងគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងនេះក៏ដោយពលរដ្ឋកម្ពុជាមួយចំនួនតូចនៅតែមិនទាន់យល់ដឹងពីរបបកម្មសិទ្ធិលើដីធ្លីច្បាស់លាស់នោះទេ ដោយហេតុមិនទាន់យល់ដឹងពីចំណេះដឹងផ្នែកច្បាប់ និងមិនទទួលបានព័ត៌មានគ្រប់គ្រាន់។[34] កត្តាទាំងអស់នេះ បានបង្កឱ្យមានសកម្មភាព

---

[32] សេចក្ដីប្រកាសព័ត៌មានស្ដីពីខ្សែបន្ទាត់ភាពក្រីក្រ និងអត្រាភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០១៩-២០២០, លេខ០៩០៩ផក។

[33] រាជរដ្ឋាភិបាល, *គោលនយោបាយជាតិស្ដីពីលំនៅឋាន*, ២០១៤, ១១។

[34] Hor Peng, Kong Phallack និងJörg Menzel (Eds.) "Introduction to Cambodian Law" [សេចក្ដីផ្ដើមនីតិកម្ពុជា], (Konrad-Adenauer-Stiftung: Cambodia, 2012), ៤០០។

អសណ្តាប់ធ្នាប់សង្គម ដូចជាការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ការសង់រោង សង់ខ្ទម សង់ផ្ទះ ជាពិសេសនៅតាមបណ្តោយផ្លូវជាតិសំខាន់ៗ នៅតាមផ្លូវរថភ្លើង និងការសាងសាង់សំណង់យ៉ាង អនាធិបតេយ្យ។ មូលហេតុនេះហើយដែលធ្វើឱ្យប្រជាពលរដ្ឋ ងាយនឹងទទួលយកនូវព័ត៌មានដែលមិនច្បាស់លាស់ តាមរយៈការបំផុសបំផុលជំរុញឱ្យប្រជាពលរដ្ឋ ទៅចាប់ដីសាធារណៈរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។ សកម្មភាពទាំងអស់នេះនឹងបង្កជាឧបសគ្គ និងឥទ្ធិពលអាក្រក់រាំងស្ទះដល់ផែនការអភិវឌ្ឍន៍លើគ្រប់វិស័យនាពេលបច្ចុប្បន្នក៏ដូចជាពេលអនាគត។

### ១.៣.៣. កត្តាកំណើនប្រជាជន

អត្រាកំណើនប្រជាជនកម្ពុជាកើនឡើងជាបន្តបន្ទាប់ ដោយទម្រង់ប្រជាសាស្ត្រប្រទេសកម្ពុជាបានផ្លាស់ប្តូរទាំងស្រុង ខុសពីទិន្នន័យនៃប្រជាជនសរុបដែលបានធ្វើជំរឿនជាលើកដំបូង ដោយមូលហេតុសង្គ្រាម និងភាពចលាចល។ ឆ្លើយតបជាមួយការកើនឡើងនៃចំនួនប្រជាជនសរុបពីមួយឆ្នាំទៅមួយឆ្នាំ តម្រូវការនៃលំនៅឋានពិតជាមានសារៈសំខាន់ក្នុងជីវរស់នៅ។ តួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ បានបង្ហាញថាមានចំនួន ១៥,២៨៨,៤៨៩ នាក់ ដែលបានកើនឡើងពី ១៣,៣៩៥,៦៨២ នាក់ នៅជំរឿនឆ្នាំ២០០៨។ ចំនួនប្រជាជនសរុបបានកើនឡើង ១,៨៩២,៨០៧ នាក់ត្រូវនឹង ១៤.១% រយៈពេល ១១ ឆ្នាំ រវាងឆ្នាំ ២០០៨ និងឆ្នាំ ២០១៩។[35]

យោងតាមជំរឿនទូទៅ របស់ប្រទេសកម្ពុជាឆ្នាំ២០០៨ បានបង្ហាញផងដែរនូវនិន្នាការនៃការថយចុះទំហំគ្រួសារ ដែលអាចប៉ាន់ប្រមាណថារហូតដល់ឆ្នាំ ២០៣០ កម្ពុជាអាចត្រូវការលំនៅឋានថ្មីប្រមាណជាង ១,១ លានបន្ថែមទៀតដោយមិនរាប់បញ្ចូលកង្វះលំនៅឋាននាពេលបច្ចុប្បន្ន។ កត្តានេះហើយដែលធ្វើឱ្យសេចក្តីត្រូវការដីធ្លី និងលំនៅឋានកាន់តែកើនឡើង និងអាចបង្កឱ្យមានការតាំងលំនៅបណ្តោះអាសន្នថ្មីកើតឡើងថែមទៀត ប្រសិនបើមិនបានធ្វើផែនការរៀបចំដែនដី គោលនយោបាយលំនៅឋាន និងវិធានការចាំបាច់នានា ដើម្បីធានាសិទ្ធិទទួលបានលំនៅឋានសមរម្យសម្រាប់អ្នកមានប្រាក់ចំណូលមធ្យម និងអ្នកមានប្រាក់ចំណូលទាប។[36]

---

[35] ក្រសួងផែនការ, *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩*, ២០១៩, ៩។

[36] រាជរដ្ឋាភិបាល, *គោលនយោបាយជាតិស្តីពីលំនៅឋាន*, ២០១៤, ១។

# ជំពូកទី២៖
# ការដោះស្រាយសំណាក់បណ្ដោះអាសន្នលើដីរដ្ឋ

# ជំពូកទី២
# ការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរដ្ឋ

បើទោះបីជាប្រជាពលរដ្ឋមួយចំនួនបានមកសង់ សំណង់បណ្ដោះអាសន្នលើដីរដ្ឋដោយខុសច្បាប់ក៏ពិតមែន ក៏រដ្ឋាភិបាលកម្ពុជាមានការយកចិត្តទុកដាក់ ដោយបានបង្កើតនូវគោលនយោបាយ គោលការណ៍ណែនាំ និងយន្តការមួយចំនួនដើម្បីដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរដ្ឋនេះផងដែរ។ ក្នុងឯកសារបឋមស្ដីពីក្របខ័ណ្ឌយុត្តិសាស្ត្រគោលនយោបាយដីធ្លី បានលើកឡើងអំពីសិទ្ធិកាន់កាប់ដីធ្លីបណ្ដោះអាសន្ន និងមានរយៈពេលកំណត់ចំពោះអ្នកតាំងទីលំនៅខុសច្បាប់ និងសំណង់អនាធិបតេយ្យដែលបានកើតជាបន្តនៅរាជធានី ទីរួមខេត្ត និងទីប្រជុំជនមួយចំនួន។[37] រដ្ឋអាចប្រើប្រាស់វិធានការចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ផ្សេងៗ និងផ្ដល់នូវលក្ខខណ្ឌនៃលំនៅឋានសមរម្យចំពោះប្រជាពលរដ្ឋដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ក្រោយការតាំងទីលំនៅថ្មី។

## ២.១. វិធានការចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

គោលបំណងនៃវិធានការទាំងនេះ គឺដើម្បីដោះស្រាយបញ្ហានៃការកាន់កាប់ដីរដ្ឋដោយខុសច្បាប់របស់ប្រជាពលរដ្ឋដែលមានកន្លងមក និងព្យាយាមបំបាត់នូវការចូលមកកាន់កាប់លើដីរដ្ឋ។ អត្ថិភាពនៃវិធានការចំពោះការកាប់ដីរដ្ឋដោយខុសច្បាប់ កើតឡើងបានតាមរយៈដីសម្បទានសង្គមកិច្ច ការបណ្ដេញចេញដោយបង្ខំ ការចោទប្រកាន់តាមផ្លូវតុលាការ និងគោលនយោបាយនានាដែលរាជរដ្ឋាភិបាលបានបង្កើតឡើងចំពោះសំណង់បណ្ដោះអាសន្នដែលខុសច្បាប់។

### ២.១.១. ដីសម្បទានសង្គមកិច្ច

#### ២.១.១.១. គោលបំណងដីសម្បទានសង្គមកិច្ច

សម្បទានដីសង្គមកិច្ច គឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។[38] ហើយគោលដៅនៃការផ្ដល់សម្បទាននេះដែរគឺមានកំណត់ក្នុងមាត្រា៣ នៃអនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច។ អ្នកទទួលបាននូវសម្បទាននេះ គឺត្រូវរៀបចំដីសង់លំនៅឋាន ឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីធានាការចិញ្ចឹមជីវិត។[39] ការប្រើប្រាស់ពាក្យ "ចិញ្ចឹមជីវិត" មានន័យថា សម្បទានដីសង្គមកិច្ច មិនអាចប្រើប្រាស់ដើម្បី

---

[37] សារាចរស្ដីពីការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន,លេខ០៣សរ, ៣១ ឧសភា ២០១០ (ចាប់ពីពេលនេះទៅហៅថាសារាចរលេខ០៣)។

[38] អនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ/បក, ១៩ មីនា ២០០៣, មាត្រា២ (ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ១៩ អនក្រ/បក)។

[39] ច្បាប់ភូមិបាល, មាត្រា៤៩។

ទទួលបានកម្រៃលើសពីសេចក្តីត្រូវការដើម្បីចិញ្ចឹមគ្រួសារបានឡើយ។ ទោះជាយ៉ាងណាក៏ដោយអនុក្រឹត្យនេះមិនប្រើពាក្យ "ចិញ្ចឹមជីវិត" ទេ ប៉ុន្តែប្រើពាក្យធ្វើកសិកម្មជាលក្ខណៈគ្រួសារ។[40] ការធ្វើកសិកម្មជាលក្ខណៈគ្រួសារសំដៅសកម្មភាពដាំដំណាំ ឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋាន។[41] ជារួមមក សម្បទានដីសង្គមកិច្ចត្រូវបានផ្តល់ឱ្យសម្រាប់គោលបំណង ពីរ យ៉ាងគឺ សង់លំនៅឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

**២.១.១.២. សិទ្ធិលើដីសម្បទានសង្គមកិច្ច**

ការកំណត់ស្ថានភាពគ្រួសារ គឺជាមូលហេតុដែលនាំកើតនូវសិទ្ធិលើដីសម្បទានសង្គមកិច្ច។ ចំពោះអ្នកដែលអាចទទួលបាននូវសម្បទានដីសង្គមកិច្ចមានដូចជា គ្រួសារក្រីក្រ គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅ បណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ការតាំងលំនៅឋានថ្មី គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ គ្រួសារមាតុភូមិនិវត្តន៍ យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការជាដើម។ ដើម្បីកំណត់ថាជាគ្រួសារមួយជាគ្រួសារក្រីក្រ គឺត្រូវបង្ហាញឡើងតាមរយៈការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលវាសំដៅដល់ការកំណត់គ្រួសារក្រីក្រ កម្រិតភាពកក្រីក្រ និងអត្រាភាពក្រីក្រតាមតំបន់។[42] ម្យ៉ាងទៀត លក្ខណៈសម្បត្តិដែលអ្នកសុំដីសម្បទានសង្គមកិច្ចត្រូវបំពេញ គឺមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ ក្នុងនោះដែរគ្មានជនណាម្នាក់ អាចបដិសេធសិទ្ធិចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច របស់មេគ្រួសារជាស្ត្រី ជាជនបាត់បង់សមត្ថភាព អតីតយុទ្ធជនដែលបាត់បង់សមត្ថភាព ជាយោធិនរំសាយបានឡើយ។[43] អ្នកដែលទទួលសម្បទានដីនេះ អាចទទួលបានប័ណ្ណកម្មសិទ្ធិ ហើយក្លាយជាកម្មសិទ្ធិករលើដីនៅពេលណាសម្បទានិកបានបំពេញនូវលក្ខខណ្ឌ ដែលបានកំណត់ក្នុងនោះមានលក្ខខណ្ឌកាន់កាប់ដី និងលក្ខខណ្ឌរយៈពេល។

**ក. លក្ខខណ្ឌកាន់កាប់ដី**

លក្ខខណ្ឌនៃការកាន់កាប់ដីតម្រូវឱ្យមានការសង់រចនាសម្ព័ន្ធលំនៅឋាននៅលើដី។ "ប្រសិនបើគ្មានរចនាសម្ព័ន្ធលំនៅឋាន លើដីលំនៅឋាននៃដីសម្បទានសង្គមកិច្ច មុខសញ្ញាអ្នកទទួលដីត្រូវសាងសង់យ៉ាងហោចណាស់នូវចំណែកណាមួយ នៃជម្រកស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរយៈពេល ៣ ខែ បន្ទាប់ពីទទួលបានដី ហើយសមាជិកនៃគ្រួសារនោះត្រូវរស់នៅពិតប្រាកដ និងជាអចិន្ត្រៃយ៍លើដីនោះឱ្យបានលើសពី ៦ ខែ ក្នុងមួយឆ្នាំ។

[40] East-West Management Institute, *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ* (ភ្នំពេញ, ២០០៥), ១៣៨។

[41] អនុក្រឹត្យលេខ១១៩អនក្រ/បក, មាត្រា២។

[42] អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, លេខ២៩១អនក្រ/បក, ២៧ ធ្នូ ២០១១, មាត្រា៤។

[43] អនុក្រឹត្យលេខ១១៩អនក្រ/បក, មាត្រា១០។

មុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ត្រូវធ្វើកសិកម្មជាក់ស្តែងលើដីនោះក្នុងរយៈពេល ១២ ខែបន្ទាប់ពីទទួលបានដីហើយបន្តប្រើប្រាស់ដីនេះស្របតាមលក្ខខណ្ឌចាំបាច់នៃកម្មវិធីសម្បទាន។”[44]

ក្នុងនោះដែរកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ត្រូវបានបង្កើតឡើងរវាងមុខសញ្ញាអ្នកទទួលបានដី និងអាជ្ញាធរមានសមត្ថកិច្ចផ្តល់ដីដែលបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី អនុលោមតាមកម្មវិធីសម្បទានដីសង្គមកិច្ចនេះ និងចែងពីករណីលើកលែង ដែលមានដូចជា ករណីប្រធានសក្តិ ឬមានជំងឺធ្ងន់ធ្ងរដែលរារាំងដល់ការបំពេញកាតព្វកិច្ចទទួលខុសត្រូវនោះ។ ចំពោះទម្រង់ និងបែបបទសម្រាប់កិច្ចសន្យាជាលាយលក្ខណ៍អក្សរនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។[45]

**ខ. លក្ខខណ្ឌរយៈពេល**

សម្បទានដីសង្គមកិច្ចមានលក្ខណៈខុសប្លែកពីសម្បទានផ្សេងទៀត ដោយសាររយៈពេលនៃការផ្តល់សម្បទាន។ សម្បទានិកអាចរស់នៅលើដីដែលបានផ្តល់ឱ្យនោះដោយមិនមានពេលកំណត់ និងអាចប្រែក្លាយជាកម្មសិទ្ធិករនៅលើដីដែលសម្បទានិកទទួលបាន។[46]

**២.១.១.៣. ទំហំនៃផ្តល់ដីសម្បទាន**

ក្នុងច្បាប់ បទដ្ឋានគតិយុត្តពុំបង្ហាញច្បាស់លាស់ពីទំហំអប្បបរិមានៃការផ្តល់ដីសម្បទានឡើយ។ ច្បាប់ភូមិបាលមិនបានកំណត់ឱ្យច្បាស់ថា តើដីសម្បទានត្រូវមានទំហំប៉ុណ្ណានោះទេ។ ប៉ុន្តែ បានកំណត់នូវគោលការណ៍ថា ដីសម្បទានមិនត្រូវមានទំហំធំពេក តែត្រូវមានទំហំល្មមនឹងសង់លំនៅឋាន និងអាចឱ្យគ្រួសារដែលរស់នៅទីនោះដាំដំណាំដើម្បីចិញ្ចឹមជីវិតបាន។ រីឯអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ក៏មិនមានចែងពីទំហំអប្បបរិមានេះដែរ។[47] អនុក្រឹត្យនេះគ្រាន់តែបានកំណត់ថា “ដីសម្បទានសង្គមកិច្ច ដែលត្រូវផ្តល់ឱ្យសម្រាប់សង់លំនៅឋានមានទំហំធំបំផុត ១,២០០ ម៉ែត្រការ៉េ។ ប៉ុន្តែ នៅតំបន់ជនបទដែលមានលទ្ធភាពដីទំនេរ ទំហំដីសម្បទានសង្គមកិច្ចអាចឡើងរហូតដល់ ៣,៦០០ ម៉ែត្រការ៉េ។ ក្នុងករណីសមស្រប ពិសេសនៅតំបន់ទីក្រុងសម្បទានដីសង្គមកិច្ចសម្រាប់សង់លំនៅឋានអាចផ្តល់ឱ្យតាមរូបភាពសហកម្មសិទ្ធិ។”[48] ក្នុងនោះដែរដីសម្បទានសង្គមកិច្ចដែលត្រូវផ្តល់ឱ្យសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំធំបំផុត ០២ ហិកតា។ ប៉ុន្តែនៅក្នុង

---

[44] អនុក្រឹត្យលេខ១៩អនក្រ/បក, មាត្រា១៨។

[45] អនុក្រឹត្យលេខ១៩អនក្រ/បក, មាត្រា១៨។

[46] ដូច៤០, ទំព័រ១៣៩។

[47] ដូច៤០, ទំព័រ១៤១។

[48] អនុក្រឹត្យលេខ១៩អនក្រ/បក, មាត្រា១៦។

តំបន់ខ្លះ ទំហំដីសម្បទានសង្គមកិច្ច អាចកើនឡើងរហូតដល់ ០៥ ហិកតា អាស្រ័យទៅតាមលក្ខណៈដីសក្តានុពល ឬប្រភេទដំណាំ និងកម្លាំងពលកម្មរបស់គ្រួសារអ្នកសុំដី។[49]

### ២.១.១.៤. សម្បទានដីសង្គមកិច្ច និងសហគមន៍ក្រីក្រ

សម្បទានដីនេះ ត្រូវបានគេប្រើប្រាស់ជាឧបករណ៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវតំបន់ដែលមានគ្រួសារក្រីក្រ និងលំនៅឋានពុំមានរបៀបរៀបរយនៅក្នុងតំបន់ទីក្រុង។ តែក៏នៅមានសហគមន៍ខ្លះដែលពុំបានទទួលផលពីសម្បទានដីនេះផងដែរ។ យោងតាមរបាយការណ៍របស់អង្គការសមាគមធាងត្នោត ស្តីពីការស្ទង់មតិក្នុងរាជធានីភ្នំពេញ ដែលសិក្សាពីទីតាំងលំនៅឋានក្រីក្រ បានរកឃើញថា យ៉ាងហោចណាស់ មានសហគមន៍ក្រីក្រប្រមាណ ២៧៧ ទីតាំងក្នុងខណ្ឌទាំង១២ នៃរាជធានីភ្នំពេញ។[50]

ករណីមួយចំពោះតំបន់ដីក្រហម ជាតំបន់ដែលកើតមានជម្លោះដីធ្លី។[51] យោងតាមអាជ្ញាធរមូលដ្ឋានដីក្រហម គឺជាសហគមន៍មានប្រាក់ចំណូលទាប ដែលមាន១៤៦៥ គ្រួសារ រស់នៅលើដី ៤,៧ ហិកតា ដែលតួលេខទាំងនេះមានការអះអាងផ្សេងៗគ្នាក្នុងចំណោមអ្នកស្រុក។[52] សហគមន៍នេះស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។[53] ចំពោះស្ថានភាពគតិយុត្តនៃតំបន់ដីក្រហម គឺជាដីឯកជនរបស់រដ្ឋ។[54] ដែលវាជាមូលហេតុអាចនាំឱ្យមានការធ្វើសម្បទានដីសង្គមកិច្ចជូនពលរដ្ឋដែលបានរស់នៅក្នុងតំបន់មួយនេះ។ នៅក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានជ្រើសរើសតំបន់នេះ ជាតំបន់សម្បទានដីសង្គមកិច្ច ដែលជាចំណែកនៃផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលក្នុងការចែករំលែកដីធ្លីសម្រាប់អ្នកក្រីក្រ។ ក៏ប៉ុន្តែចំណែកនៃដីមួយផ្នែកគឺដើម្បីផ្តល់ឱ្យទៅក្រុមហ៊ុនឯកជន និងដីមួយផ្នែកទៀតគឺត្រៀមទុកសម្រាប់ប្រជាពលរដ្ឋ។ ដែលនេះបង្ហាញពី ឆន្ទៈរបស់រាជរដ្ឋាភិបាលធ្វើការអភិវឌ្ឍនៅនឹងកន្លែង សម្រាប់សហគមន៍នេះ។[55] ក្នុងនោះមានទិដ្ឋភាពដែលមាន លក្ខណៈបញ្ហាជាច្រើនក្នុងរឿងសម្បទានដីសង្គមកិច្ចតំបន់ដីក្រហម។ ទិដ្ឋភាពមួយដ៏សំខាន់បំផុតគឺពាក់ព័ន្ធទៅនឹង ការអនុវត្តសម្បទានដីសង្គមកិច្ច នៅក្នុងតំបន់មួយដែលត្រូវបានកាន់កាប់រួចទៅហើយ និងជា

---

[49] អនុក្រឹត្យលេខ១៩អនក្រ/បក, មាត្រា១៧។

[50] អង្គការសមាគមធាងត្នោត, *ការស្ទង់មតិក្នុងរាជធានីភ្នំពេញ៖ ការសិក្សាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង រាជធានីភ្នំពេញ* (ភ្នំពេញ, ២០១៨), ៧។

[51] សូមមើលបន្ថែមនូវប្រវត្តិនៃសហគមន៍មួយនេះ៖ អង្គការលីកាដូ, *សេចក្តីពន្យល់ពីករណីដីធ្លីសហគមន៍ដីក្រហម* , ភ្នំពេញ, ២០០៨ 118kDeyKrahormCommunityLandCaseExplainedKhmer.pdf ។

[52] អង្គការទិន្នន័យអំពីការអភិវឌ្ឍ៖ *សម្បទានដីសង្គមកិច្ច* https://opendevelopmentcambodia.net/km/topics/social-land-concessions/ *(បានចូលមើលចុងក្រោយថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២)*។

[53] អង្គការលីកាដូ, *សេចក្តីពន្យល់ពីករណីដីធ្លីសហគមន៍ដីក្រហម* (ភ្នំពេញ, ២០០៨), ១។

[54] ដដែល, ទំព័រ១០។

[55] ដដែល, ទំព័រ៣។

កន្លែងដែលអ្នកស្រុកមានឯកសារគ្រប់គ្រាន់ ក្នុងការកាន់កាប់ស្របច្បាប់ដែលមានសៀវភៅគ្រួសារជាដើម ហើយដែលបញ្ជាក់ច្បាស់ពីសិទ្ធិភោគៈរបស់ខ្លួននៅលើដីនោះ។[56] ការជានាឱ្យមានសិទ្ធិលើអចលនទ្រព្យរបស់អ្នកដែលរស់នៅតំបន់នេះពុំកើតមានឡើយ ផ្ទុយទៅវិញសម្បទានដីសង្គមកិច្ចបានធ្វើការផ្ទេរដីរបស់ពួកគេទៅឱ្យក្រុមហ៊ុនឯកជន។[57] ដែលតាមរយៈនេះវាបានបង្កើតជាបញ្ហាក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចនេះឡើង។ សហគមន៍ដីក្រហមត្រូវបានបណ្តេញចេញ ដោយមានការប្រើអំពើហិង្សាទៅ លើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ថ្វីត្បិតតែមិនទាន់មានប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ គឺវាមានភាពមិនស្របច្បាប់ឡើយនេះបើពិនិត្យមើលលើខ្លឹមសារនៃមាត្រា២៥៣ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។[58]

បើទោះបីជាមានបញ្ហាខ្លះក្នុងការអនុវត្តសម្បទានដីសង្គមកិច្ចនេះក៏ដោយ ក៏សម្បទានដីនេះបានជួយដល់ប្រជាពលរដ្ឋក្រីក្រមួយចំនួនដែលបានទទួលនូវសម្បទាននេះ ជាពិសេសប្រជាពលរដ្ឋដែលគ្មានដីធ្លី។ ជាក់ស្តែងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលហៅថាគម្រោង LASED ជាគម្រោងដែលជួយកសិករខ្នាតតូច និងសហគមន៍ជនបទឱ្យមានលទ្ធភាពប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិតាមរបៀបមួយមានចីរភាព និងបិតថេរយូរអង្វែង គឺជាផ្នែកស្នូលមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលពង្រីកសិទ្ធិកាន់កាប់ដីធ្លីសម្រាប់ជនក្រីក្រគ្មានដីនៅតាមទីជនបទ។[59] គម្រោងនេះជួយដល់ការកសាងផ្លូវលំជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច សម្បទាផ្នែកផ្គត់ផ្គង់សេវាទឹកស្អាត និងអនាម័យ អគារសាលារៀន ផ្ទះគ្រូបង្រៀន ប៉ុស្តិ៍សុខភាព និងមណ្ឌលសហគមន៍។ អ្នកទទួលផលថ្មីពីកម្មវិធីដីសម្បទានសង្គមកិច្ច នឹងទទួលបានជំនួយជាគ្រាប់ពូជសម្រាប់ការដាំដុះឆ្នាំដំបូងរបស់ខ្លួន ហើយគម្រោងនេះក៏បានបង្កើតមូលនិធិសហគមន៍សម្រាប់ពង្រីកសកម្មភាពសេដ្ឋកិច្ចនៅក្នុងមូលដ្ឋានផងដែរ។[60]

---

[56] ដដែល, ទំព័រ១១។

[57] ដូច៥២។

[58] ទ្រី ហ៊ង, "វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩," (និក្ខេបបទបណ្ឌិតនីតិសាស្ត្រ, ឯកទេសនីតិឯកជន, រាជបណ្ឌិត្យសភាកម្ពុជា, ២០១២), ១៥២។

[59] ធនាគារពិភពលោក៖ *គម្រោង ៩៣ លានដុល្លារ ជួយបង្កើនសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីរបស់កសិករក្រីក្រ និងសហគមន៍ជនជាតិដើមភាគតិច* កម្ពុជា៖ គម្រោង ៩៣ លានដុល្លារ ជួយបង្កើនសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីរបស់កសិករក្រីក្រ និងសហគមន៍ជនជាតិដើមភាគតិច )worldbank.org) *(បានចូលមើលចុងក្រោយថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២)*។

[60] ដូច៥៩។

### ២.១.២. ការបណ្តេញចេញ និងកាតព្វកិច្ចរបស់រដ្ឋចំពោះការបណ្តេញចេញ

#### ២.១.២.១. ការបណ្តេញចេញ

ការបណ្តេញចេញ គឺជាយន្តការមួយនៃការដោះស្រាយការសង់សំណង់បណ្តោះអាសន្នលើដីរដ្ឋ។ ការបណ្តេញចេញ គឺជាការឱ្យនរណាម្នាក់ចេញពីផ្ទះសម្បែង ឬដីធ្លីរបស់ខ្លួនដោយដំណើរការតាមផ្លូវច្បាប់។[61] ប្រសិនបើការធានាតាមផ្លូវច្បាប់ និងនីតិវិធី មិនត្រូវបានគេគោរពទេនោះ ការបណ្តេញចេញ គឺជាទង្វើមួយខុសច្បាប់ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយត្រូវចាត់ទុកថាជាការបណ្តេញចេញដោយបំពាន។ រូបរាងនៃការបណ្តេញចេញនេះច្រើនតែកើតឡើងពីគម្រោងអភិវឌ្ឍន៍នានាផងដែរ។[62]

ការបណ្តេញចេញក៏រួមមានការបណ្តេញចេញដោយបំពានផងដែរ ដែលមានធាតុផ្សំដូចជា ការធ្វើតាមទំនើងចិត្ត អនីត្យានុកូលភាព ការមិនស្ម័គ្រចិត្ត និងការធ្វើឱ្យមនុស្សទទួលរងការឈឺចាប់ច្រើនហួសហេតុ។[63] ការចាកចេញដោយបង្ខំចិត្ត ពីលំនៅឋានរបស់ជនស៊ីវិល និងការបំផ្លាញកម្មសិទ្ធិឯកជន ដែលការធ្វើបែបនេះជាការអនុវត្តការបណ្តេញចេញដោយបំពាន។[64] ពោះលទ្ធផលនៃការបណ្តេញចេញ មិនត្រូវនាំពួកគេក្លាយជាមនុស្សគ្មានផ្ទះសម្បែង ឬធ្លាក់ក្នុងស្ថានភាពលំបាកធ្ងន់ធ្ងរនោះឡើយ។[65] ក្នុងនោះដែររដ្ឋក៏ត្រូវតែមានកាតព្វកិច្ចមុននឹងធ្វើការបណ្តេញចេញ ក្នុងអំឡុងពេលនៃការបណ្តេញចេញ និងក្រោយការបណ្តេញចេញ ដើម្បីជាការធានាឱ្យការបណ្តេញចេញនោះស្របតាមនិយាមជាតិ និងអន្តរជាតិ។

#### ២.១.២.២. កាតព្វកិច្ចរបស់រដ្ឋចំពោះការបណ្តេញចេញ

##### ក. កាតព្វកិច្ចរបស់រដ្ឋមុនការបណ្តេញចេញ

កម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ច្បាប់អន្តរជាតិទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ[66] ដែលវាបានភ្ជាប់កាតព្វកិច្ចរបស់រដ្ឋជាមួយនឹងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិទាំងនោះ។ ហេតុនេះហើយរដ្ឋត្រូវអនុវត្តកាតព្វកិច្ចមួយចំនួនមុននឹងធ្វើការបណ្តេញចេញ ដែលមានដូចខាងក្រោម៖

---

[61] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា, *សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំ ស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី*, ២០០៩, ១៥-១៦។

[62] មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅឋាន និងការបណ្តេញចេញ អង្គការស្ពានទៅកាន់សន្តិភាពអាស៊ីអាគ្នេយ៍ និងគម្រោងគណនេយ្យភាព, *សៀវភៅណែនាំស្តីពីសិទ្ធិដីធ្លី និងលំនៅឋាននៅកម្ពុជា៖ ភាគទី១*, ២០០៩, ៧។

[63] ដូច៦១, ទំព័រ១៧។

[64] ដូច៦១, ទំព័រ៣១។

[65] ដូច៦១, ទំព័រ១៧។

[66] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៣១។

- ការស្វែងរកជម្រើសសមស្របឱ្យអស់លទ្ធភាព ដោយពិគ្រោះយោបល់ជាមួយប្រជាជន ដែលដែលជាអ្នកទទួលរងផលប៉ះពាល់ពីការបណ្តេញចេញ
- ការផ្តល់ព័ត៌មាន និងមូលហេតុនៃការបណ្តេញចេញ
- ការជូនដំណឹងឱ្យបានសមរម្យ និងគ្រប់គ្រាន់ពីការបណ្តេញចេញ
- ការផ្តល់នូវសំណងសមរម្យចំពោះការខូចខាតទ្រព្យសម្បត្តិ ដែលកើតដោយសារការបណ្តេញចេញ។[67]

នៅពេលរដ្ឋាភិបាលបានគោរពកាតព្វកិច្ចរបស់ខ្លួនមុនការបណ្តេញចេញនោះ ការបណ្តេញចេញអាចនឹងពុំកើតមានឡើយ ឬករណីកើតមានឡើងនូវការបណ្តេញចេញនោះប្រជាពលរដ្ឋដែលរងការបណ្តេញចេញ នឹងធ្វើការចាកចេញយ៉ាងរីករាយជាមួយនឹងសំណងដែលគេផ្តល់ជូនគាត់។[68]

**ខ. កាតព្វកិច្ចរបស់រដ្ឋក្នុងអំឡុងពេលការបណ្តេញចេញ**

កាតព្វកិច្ចរបស់រដ្ឋក្រៅតែកាតព្វកិច្ចមុនការបណ្តេញចេញ រដ្ឋគប្បីអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលនៃការបណ្តេញចេញផងដែរ។ កាតព្វកិច្ចទាំងនោះមានដូចជា៖

- ត្រូវមានវត្តមានមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីសាធារណៈក្នុងអំឡុងពេលធ្វើការបណ្តេញចេញ
- មន្ត្រីរដ្ឋាភិបាលដែលអនុវត្តការបណ្តេញចេញត្រូវមានឯកសណ្ឋាន និងអត្តសញ្ញាណច្បាស់លាស់
- ការបណ្តេញចេញពុំអាចធ្វើឡើងបានឡើយនៅពេលយប់ ឬក្នុងពេលមានអាកាសធាតុមិនល្អ
- អាជ្ញាធរ និងភ្នាក់ងាររបស់ខ្លួនមិនគួរតម្រូវ ឬបង្ខំបុគ្គលដែលត្រូវគេបណ្តេញចេញឱ្យវាយកម្ទេចនូវផ្ទះសម្បែង ឬគ្រោងសំណង់ផ្សេងទៀតរបស់ខ្លួនឡើយ។[69]

ការបង្ហាញពីវត្តមានមន្ត្រីរដ្ឋាភិបាល ឬមន្ត្រីសាធារណៈដែលមានអត្តសញ្ញាណច្បាស់លាស់ និងមានឯកសណ្ឋានត្រឹមត្រូវក្នុងអំឡុងពេលនៃការបណ្តេញចេញ គឺដើម្បីបង្ហាញថាការអនុវត្តការបណ្តេញចេញនោះគឺមានការដឹងឮពីស្ថាប័នរដ្ឋណាមួយដែលជាស្ថាប័នអនុវត្តការបណ្តេញចេញនេះ។

**គ. កាតព្វកិច្ចរបស់រដ្ឋក្រោយការបណ្តេញចេញ**

កាតព្វកិច្ចរបស់រដ្ឋក្នុងការធានាដល់អ្នកដែលរងការបណ្តេញចេញគឺ ត្រូវឱ្យពួកគេរស់នៅក្នុងលំនៅឋានសមរម្យមួយនៅលើទីតាំងថ្មីក្រោយការបណ្តេញចេញ។ បន្ទាប់ពីការបណ្តេញចេញរដ្ឋត្រូវតែធានាឱ្យប្រជាពលរដ្ឋមានលំនៅឋានសមរម្យ ដោយមិនត្រូវទុកឱ្យនរណាម្នាក់រស់នៅដោយគ្មានផ្ទះសម្បែងនោះទេ ក៏មិន

[67] ដូច៦១, ទំព័រ៣១-៣៣។

[68] ដូច៦២, ទំព័រ៥៩។

[69] ដូច៦២, ទំព័រ៥៨-៦០។

ត្រូវបណ្តាលឱ្យងាយនឹងទទួលរងនូវការរំលោភសិទ្ធិផ្សេងៗទៀតផងដែរ។[70] ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការបណ្តេញចេញអំពីជម្រើសទីតាំងថ្មី គឺជាវិធីមួយដ៏ល្អដែលរដ្ឋាភិបាលពិចារណាអនុវត្តដើម្បីធានាឱ្យកន្លែងតាំងទីលំនៅថ្មីមានលក្ខណៈសមរម្យ។[71] ហើយកន្លែងតាំងទីលំនៅថ្មីត្រូវមានលក្ខណៈសមរម្យ មានន័យថាលំនៅឋានថ្មីនោះត្រូវតែបំពេញនូវលក្ខខណ្ឌទាំង៧ នៃលំនៅឋានដែលមានលក្ខណៈសមរម្យ។

**២.១.២.៣. ការបណ្តេញចេញក្នុងអំឡុងពេលជំងឺកូវីដ-១៩**

ជំងឺកូវីដ-១៩ គឺជាជំងឺរាតត្បាតសកលដែលបានរីករាលដាលពាសពេញពិភពលោក។ មុននឹងមានផ្ទុះជំងឺនេះ សេដ្ឋកិច្ចកម្ពុជាមានការផ្លាស់ប្តូររីកចម្រើនគួរឱ្យកត់សម្គាល់។[72] កម្ពុជាចាត់ចូលជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយប្រាថ្នាថានឹងសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០។[73] បើទោះបីជាកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយធនធាននៅមានកម្រិតក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាប្រែក្លាយវិបត្តិនៃជំងឺកូវីដ-១៩ ទៅជាឱកាសក្នុងការកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គមឱ្យកាន់តែរឹងមាំ និងមានភាពធន់ទៅនឹងវិបត្តិនាពេលអនាគត ជាពិសេសឆ្លើយតបឱ្យបានទាន់ពេលទៅនឹងការវិវត្តនៃព្រឹត្តិការណ៍នានាក្នុងតំបន់ និងសកល។[74]

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ និងសហគមន៍ ដោយបានផ្តល់សម្ភារៈបរិក្ខារពេទ្យ ផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ បង្កើតគោលនយោបាយដើម្បីកាត់បន្ថយបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[75] និងបានបង្កើតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីជួយប្រជាពលរដ្ឋក្នុងពេលដែលមានការរីករាលដាលជំងឺមួយនេះ។ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ក៏បានចេញនូវសេចក្តីសម្រេចស្តីពីការអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ដើម្បីគាំពារប្រជាពលរដ្ឋដែលរងគ្រោះ ឬរងផល

---

[70] ដូច៦១, ទំព័រ៣៨។

[71] ដូច៦២, ទំព័រ៦៥។

[72] *ធនាគារពិភពលោកនៅកម្ពុជា៖ ទស្សនៈទូទៅ* https://www.worldbank.org/km/country/cambodia/overview#1 *(បានចូលមើលចុងក្រោយថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២)*

[73] រាជរដ្ឋាភិបាល, *ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០*, ២០១៨, ៨, "សេដ្ឋកិច្ចកម្ពុជាបានសម្រេចកំណើនរឹងមាំក្នុងរយៈពេលពីរទស្សវត្សកន្លងមកនេះ ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំក្នុងចន្លោះពី៧ ទៅ៨% ដែលជាប់ចំណាត់ថ្នាក់ក្នុងចំណោមសេដ្ឋកិច្ចកំពូលទាំង១០ ក្នុងសកលលោក។"

[74] សុន្ទរកថា, អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, *សិក្ខាសាលាការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២២*, ៩-១០។

[75] អង្គការសមាគមធាងត្នោត៖ *របាយការណ៍ស្តីពី ការពិត និងតួលេខ#៤៦ ជំងឺកូវីដ-១៩ និងការផ្តល់ជំនួយ* https://teangtnaut.org/facts-and-figures-46-covid-19-and-the-help-provided/?lang=km *(បានចូលមើលចុងក្រោយថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២)*

ប៉ះពាល់ធ្ងន់ធ្ងរពីជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ និងឱ្យអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព និងគ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ដែលកម្មវិធីជំនួយសង្គមនេះដែរបានជួយប្រជាពលរដ្ឋ និងសហគមន៍ក្រីក្របានមួយចំណែកធំ។ ទោះជាយ៉ាងនេះក្តី ក៏មានសហគមន៍មួយចំនួននៅតែរងការបណ្តេញចេញក្នុងអំឡុងពេលកូវីដ-១៩ នេះផងដែរ។ សហគមន៍ដែលរងការបណ្តេញចេញ បានលើកឡើងថា រាជរដ្ឋាភិបាលមិនបានឆ្លើយតបទៅនឹងសំណើរបស់ពួកគេ ដែលសុំបញ្ឈប់ការបណ្តេញសហគមន៍ចេញពីលំនៅឋាននោះទេ ទោះបីជាក្នុងអំឡុងពេលរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ក៏ដោយ។[76]

ជាក់ស្តែងសហគមន៍បឹងឈូកអេ ដែលស្ថិតនៅបណ្តោយផ្លូវ ៥៩៨ ក្នុងក្រុមទី៣ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលត្រូវបានអាជ្ញាធរខណ្ឌឫស្សីកែវបានបណ្តេញទាំងបង្ខំ ដោយអាជ្ញាធរបានអះអាងថា ដីសហគមន៍នេះទុកសម្រាប់ការអភិវឌ្ឍគម្រោងសាធារណៈ។ គិតត្រឹមខែសីហា ឆ្នាំ២០២១ ផ្ទះប្រជាពលរដ្ឋ ១១ ខ្នង ក្នុងចំណោម ២០ ខ្នងផ្ទះ ត្រូវបានរុះរើចេញដោយពុំបានទទួលសំណង។ អាជ្ញាធរមូលដ្ឋានបានសន្យាថានឹងផ្តល់ថវិកាចំនួន ៥០០,០០០ រៀល (ប្រហែលជា ១២៥ ដុល្លារអាមេរិក) សម្រាប់គ្រួសារទាំងនោះ ប៉ុន្តែពួកគេមិនទាន់ទទួលបាននៅឡើយទេ។[77]

អាជ្ញាធរមិនត្រូវបណ្តេញប្រជាជាពលដ្ឋចេញដោយបង្ខំ ក្នុងអំឡុងពេលរីករាលដាលជម្ងឺកូវីដ-១៩ នេះឡើយ។ ការបណ្តេញចេញពុំអាចកើតមានចំពោះបុគ្គលគ្រប់រូបនៅគ្រប់ទីកន្លែង ដោយហេតុផលណាមួយក៏ដោយរហូតដល់ជំងឺនេះបានបញ្ចប់។[78] ព្រោះវាអាចជាបន្ទុកដ៏ធ្ងន់មួយទៀតសម្រាប់ប្រជាពលរដ្ឋដែលរងការបណ្តេញចេញ។ ម្យ៉ាងទៀតក្នុងករណីដែល មានការបណ្តេញចេញដោយបង្ខំក្នុងអំឡុងពេលកូវីដ-១៩ ពលរដ្ឋរងការបណ្តេញចេញនោះត្រូវតែទទួលបាននូវសំណងសមរម្យបន្ទាប់ពីការបាត់បង់ដីធ្លី ហើយថែមទាំងមានលំនៅឋានសមរម្យដើម្បីការពារខ្លួនពីជំងឺកូវីដ-១៩ នេះ។[79]

### ២.១.៣. ការអភិវឌ្ឍនៅនឹងកន្លែង

ការអភិវឌ្ឍនៅនឹងកន្លែងគឺជាជម្រើសដ៏ប្រសើរដែលរដ្ឋាភិបាលត្រូវអនុវត្ត។ ការអភិវឌ្ឍនៅនឹងកន្លែង គឺបង្ហាញពីការអភិវឌ្ឍដែលមានការចូលរួម និងធានាឱ្យមានការគោរពសិទ្ធិមនុស្ស។[80] កន្លងមករដ្ឋាភិបាលតាម

[76] ដូច៧៥។

[77] អង្គការសមាគមធាងត្នោត៖ *បញ្ឈប់ការបណ្តេញចេញ៖ សហគមន៍បឹងឈូកអេមិនគួរត្រូវបានបណ្តេញចេញក្នុងអំឡុងពេលរាលដាលនៃជំងឺកូវីដ-១៩ឡើយ (បានចូលមើលចុងក្រោយថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២)*

[78] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, *សាលាកប័ត្រព័ត៌មានស្តីពី៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាអំឡុងពេលកូវីដ១៩* (២០២១) ,៣។

[79] ដដែល ,ទំព័រ១១។

[80] ដូច៦២, ទំព័រ៧០។

រយៈអាជ្ញាធរថ្នាក់ក្រោមជាតិក៏បានធ្វើការអភិវឌ្ឍនៅនឹងកន្លែង ចំពោះសហគមន៍ដែលតាំងទីលំនៅខុសច្បាប់លើដីរដ្ឋនេះផងដែរ។ ពាក់ព័ន្ធនឹងការរៀបចំអភិវឌ្ឍន៍សហគមន៍ក្រីក្រនេះ រដ្ឋបាលរាជធានីភ្នំពេញបានធ្វើការអភិវឌ្ឍសហគមន៍ស្ទឹងមានជ័យនៅនឹងកន្លែងដោយប្រជាពលរដ្ឋទទួលបានដីស្របច្បាប់នៅអមប្រឡាយស្ទឹងមានជ័យនេះតែម្តង។[81]

ការអភិវឌ្ឍនៅនឹងកន្លែងរបស់សហគមន៍ស្ទឹងមានជ័យ គឺជាឧទាហរណ៍ដ៏ល្អមួយដែលរដ្ឋាភិបាលត្រូវតែបន្តអនុវត្តទៅសហគមន៍ដទៃទៀត ដែលប្រឈមនឹងការការបណ្តេញចេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាពិសេសតំបន់ទីប្រជុំជនដូចជាទីក្រុងជាដើម។ តែរដ្ឋាភិបាលគប្បីផ្តល់នូវសេវាមូលដ្ឋាននានាដល់សហគមន៍ដែលបានទទួលការអភិវឌ្ឍផងដែរ ដើម្បីធានាថាការអភិវឌ្ឍសហគមន៍ក្រីក្រគឺពិតជាបានជួយឱ្យប្រជាសហគមន៍ទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍនៅនឹងកន្លែងពិតប្រាកដមែន។

### ២.១.៤. ការចោទប្រកាន់តាមផ្លូវតុលាការ

ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ឬការរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដែលជាអចលនទ្រព្យ ត្រូវបានចាត់ទុកជាបទល្មើស ហើយចារីនៃអំពើនឹងត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌផងដែរ។ ទណ្ឌកម្មដែលចារីអាចនឹងទទួល គឺទោសពិន័យជាប្រាក់ និង/ឬទោសពន្ធនាគារ។ អំពើដែលចាត់ទុកជាការរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាអចលនទ្រព្យរួមមាន៖

- រាល់ការចូលកាន់កាប់អចលនទ្រព្យរបស់រដ្ឋ ជាភោគៈក្រោយចូលជាធរមាន ច្បាប់ភូមិបាលឆ្នាំ ២០០១
- រាល់ការកាន់កាប់ជាភោគៈនៅលើអចលនទ្រព្យរបស់រដ្ឋដែលត្រូវបានកំណត់រួចហើយ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទោះជាមុន ឬក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន
- រាល់ការបន្តកាន់កាប់អចលនទ្រព្យរបស់រដ្ឋក្រោយពេលលិខិតអនុញ្ញាតឬកិច្ចសន្យាឱ្យប្រើប្រាស់ដីអស់សុពលភាពហើយអ្នកកាន់កាប់មិនបានសុំបន្តសុពលភាពត្រឹមត្រូវតាមនីតិវិធីជាធរមាន
- រាល់ការកាន់កាប់អចលនទ្រព្យរបស់រដ្ឋលើសទំហំឬខុសទីតាំងដែលកំណត់ក្នុងលិខិតអនុញ្ញាតឬកិច្ចសន្យាឱ្យប្រើប្រាស់
- រាល់ការផ្ទេរសិទ្ធិប្រើប្រាស់អចលនទ្រព្យរបស់រដ្ឋដោយបំពានលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតឬកិច្ចសន្យា

[81] ក្រសួងព័ត៌មាន៖ *ឯកឧត្តម ឃួង ស្រេង៖ ដាច់ខែកក្កដានេះ ប្រជាពលរដ្ឋរស់នៅក្រោមស្ពានអាកាសស្ទឹងមានជ័យ នឹងប្តូរទីលំនៅមករស់នៅលើដីកម្មសិទ្ធិស្របច្បាប់តាមប្រឡាយស្ទឹងមានជ័យវិញ* https://www.information.gov.kh/articles/16214 *(បានចូលមើលចុងក្រោយថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)*

– រាល់ការបំប្លែងការកាន់កាប់អចលនទ្រព្យរបស់រដ្ឋទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់ មានជាអាទិ៍ ការបន្តំធ្វើបណ្ណកម្មសិទ្ធិលើដីសម្បទានដីសេដ្ឋកិច្ច ឬលើដីដែលទទួលបានត្រឹមការអនុញ្ញាតឱ្យប្រើប្រាស់ ឬធ្វើអាជីវកម្ម ឬការបំប្លែងដីដែលត្រូវបានកំណត់ជាដីសាធារណៈរបស់រដ្ឋ។[82]

រាល់អំពើរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាអចលនទ្រព្យដោយខុសច្បាប់ដូចមានបង្ហាញខាងលើ ចារីត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០ រៀល ដល់ ១០,០០០,០០០ រៀល។[83] ចំណែកឯការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសពិន័យច្រើនជាងរំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដោយធ្វើការពិន័យជាប្រាក់ពី ៥,០០០,០០០ រៀល ដល់ ៥០,០០០,០០០ រៀល ឬ / និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ។ អ្នកប្រព្រឹត្តអំពើត្រូវមានកាតព្វកិច្ចចាកចេញពីទ្រព្យសម្បត្តិសាធារណៈនោះជាបន្ទាន់ ហើយគ្មានសិទ្ធិទារកំរៃអំពីពលកម្ម ឬការរៀបចំដែលបានធ្វើលើទ្រព្យនោះឡើយ។ ក្នុងករណី ដែលអ្នកកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ មុនច្បាប់ភូមិបាលនេះចូលជាធរមានហើយមានឯកសារសំអាង និងបញ្ជាក់ជាក់លាក់ថា ខ្លួនបានទិញពីជនណាម្នាក់ អាចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តតាមវិធានច្បាប់ចំពោះបុគ្គល ដែលបានលក់ទ្រព្យសម្បត្តិសាធារណៈនេះដោយខុសច្បាប់ និងដើម្បីជាប្រយោជន៍របស់ខ្លួន ដែលបានរងគ្រោះដោយសារទង្វើនេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះនេះពុំមានសិទ្ធិកាន់កាប់បន្តលើទ្រព្យសម្បត្តិសាធារណៈបានឡើយ។[84] មានតែអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ មានកាតព្វកិច្ចទាមទារយកអចលនទ្រព្យរបស់រដ្ឋមកវិញ ដោយឥតលក្ខខណ្ឌស្របតាមនីតិវិធី និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។[85]

## ២.១.៥. គោលនយោបាយរាជរដ្ឋាភិបាលចំពោះសំណង់បណ្តោះអាសន្នដែលខុសច្បាប់

### ២.១.៥.១. យុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ គឺជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា។[86] ក្នុងឯកសារគោលនយោបាយដ៏សំខាន់មួយនេះ គឺមានបង្ហាញពីចតុកោណយុទ្ធសាស្ត្រទាំង៤ ដែលមានដូចជា ការអភិវឌ្ឍធនធានមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជន និងការងារ និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។

---

[82] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, មាត្រា៧១។
[83] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, មាត្រា៨១។
[84] ច្បាប់ភូមិបាល, មាត្រា២៥៩។
[85] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, មាត្រា៧១។
[86] រាជរដ្ឋាភិបាល, *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នីតិកាលទី៦*, ៥។

ចតុកោណយុទ្ធសាស្ត្រនីមួយៗ គឺនៅមានមុំយុទ្ធសាស្ត្រផ្សេងៗជាច្រើនទៀត។ តាមរយៈចតុកោណទី៤ ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងមុំទី៣ សំដៅដល់ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិស្តីពីលំនៅឋាន និង គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ បានសាងសង់លំនៅឋានតម្លៃសមរម្យ បានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដីសម្បទានសង្គមកិច្ច ដល់គ្រួសារដែលមានជីវភាពក្រីក្រ គ្មានដី និងគ្មានផ្ទះ។[87] ដែលនេះគឺបានបង្ហាញពីឆន្ទៈនយោបាយរបស់រដ្ឋាភិបាលក្នុងការជួយគ្រួសារដែលមានជីវភាពក្រីក្រឱ្យទទួលបាននូវលំនៅឋានសមរម្យ និងមានជីវភាពល្អប្រសើរ។

### ២.១.៥.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី

ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី គឺជាឯកសារបឋមដែលបង្ហាញនូវជំហរទាំងឡាយដែលកំពុងស្ថិតនៅក្នុងដំណើរការអភិវឌ្ឍ។ ឯកសារនេះគឺជាឯកសារក្របខ័ណ្ឌ ព្រោះក្នុងឯកសារនេះមានលើកឡើងតែទិសដៅធំៗនៃគោលនយោបាយ ហើយមិនមានការបកស្រាយលម្អិតដើម្បីធ្វើឱ្យគោលបយោបាយនោះសម្រេចនូវបំណងរបស់ខ្លួនទេ។[88] ក្នុងឯកសារបឋមមួយនេះ ក៏បានបង្ហាញផងដែរពីចក្ខុវិស័យស្តីពីគោលនយោបាយដីធ្លី ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅជាតិដ៏ទូលំទូលាយក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយសមធម៌ អភិបាលកិច្ចល្អនៅក្នុងសង្គមប្រជាធិបតេយ្យ។[89] ក្នុងនោះដែរតាមរយៈគោលនយោបាយរដ្ឋបាលដីធ្លី គឺបង្ហាញពីឆន្ទៈរបស់រដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងកាត់បន្ថយវិវាទដីធ្លីដែលប៉ះពាល់ដល់អ្នកក្រីក្រ និងរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។[90] ក្រៅតែពីគោលនយោបាយខាងលើ ក៏មានគោលនយោបាយមួយដែលលើកឡើងពីការទទួលស្គាល់សិទ្ធិកាន់កាប់បណ្តោះអាសន្ន និងមានកំណត់ពេលចំពោះអ្នកតាំងទីលំនៅបណ្តោះអាសន្នក្នុងខណៈដែលគេកំពុងស្វែងរកដំណោះស្រាយលំនៅឋានអចិន្ត្រៃយ៍។ គោលនយោបាយនោះ គឺជាគោលនយោបាយលំនៅឋានការតាំងទីលំនៅខុសច្បាប់ និងគោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មី។ ករណីទីកន្លែងដែលតាំងទីលំនៅខុសច្បាប់នោះជាដីសាធារណៈរបស់រដ្ឋ ដែលមានផលប្រយោជន៍ច្រើនដល់សង្គម ជម្រើសចាំបាច់នោះគោលនយោបាយស្តីពីការទូទាត់ និងការដូរទីតាំងថ្មីត្រូវយកមកអនុវត្ត។ ប្រសិនបើទីកន្លែងនោះមិនចាំបាច់ដើម្បីយកទៅប្រើប្រាស់ជាសាធារណៈទេ នោះអ្នកតាំងទីលំនៅត្រូវបានទទួលស្គាល់ទាំងសិទ្ធិ

[87] រាជរដ្ឋាភិបាល, *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នីតិកាលទី៦*, ៨១។

[88] រាជរដ្ឋាភិបាល, *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី*, ២០០២, ៥។

[89] រាជរដ្ឋាភិបាល, *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី*, ២០០២, ១៣។

[90] រាជរដ្ឋាភិបាល, *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី*, ២០០២, ១៦។

រយៈពេលវែង ឬត្រូវផ្តល់នូវកម្មសិទ្ធិពេញលេញ ព្រមទាំងសេវាកម្មដែលត្រូវធ្វើឱ្យបានប្រសើរឡើងក្នុងពេលនោះផងដែរ។[91]

### ២.១.៥.៣. គោលនយោបាយដីធ្លី

គោលនយោបាយដីធ្លី គឺជាឯកសារវិភាគអំពីស្ថានភាពនៃការកាន់កាប់ ការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិដែលត្រូវឆ្លើយតបទៅនឹងការអភិវឌ្ឍតាមដំណាក់កាល ដើម្បីគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព ផលិតភាព និងនិរន្តរភាពសម្រាប់មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀត។[92] គោលនយោបាយដីធ្លីនេះក៏ជាលិខិតបទដ្ឋានគតិយុត្ត ដែលអនុលោមទៅតាមគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិមានលំនៅឋានដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កាតិកាសញ្ញា និអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្សដែលបានចែងថា មនុស្សគ្រប់រូបមានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ដើម្បីជានាសិទ្ធិទទួលបានលំនៅឋានសមរម្យសម្រាប់ស្នាក់នៅ។[93]

ដោយមើលឃើញពីផលវិបាកធ្ងន់ធ្ងរ ដោយសារតែឯកសារពាក់ព័ន្ធនឹងដីធ្លីត្រូវបានបំផ្លិចបំផ្លាញចោលទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍[94] បូករួមជាមួយនឹងការកើនឡើងនូវតម្លៃទីផ្សារដីធ្លីមានសន្ទុះខ្លាំងបាតុភាពនៃការរំលោភលើដីរដ្ឋ ការដណ្តើមកាន់កាប់ និងទំនាស់ដីធ្លីកើតមានជាបន្តបន្ទាប់។[95] ក្រៅពីនេះក៏មានបញ្ហាប្រឈមផ្សេងៗ ដែលទាក់ទងនឹងសកម្មភាពអវិជ្ជមាននៃចលនាទន្ទ្រានកាន់កាប់ដីរដ្ឋ ដីទំនេរមិនទាន់ប្រើប្រាស់ ដីព្រៃលិចទឹក ដីព្រៃកោងកាង ដីមានបេតិកភណ្ឌ ដីបម្រុងសម្រាប់ប្រយោជន៍សាធារណៈដែលបង្កឡើងដោយពួកជនឱកាសនិយម និងអ្នកមានឥទ្ធិពល និងភាពមានកម្រិតនៃស្ថាប័នមានសមត្ថកិច្ចមួយចំនួន ទើបរាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវគោលនយោបាយដីធ្លី ឬហៅថា "សៀវភៅស" ដោយទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅក្នុងក្របខណ្ឌគោលនយោបាយដីធ្លី ដែលពាក់ព័ន្ធជុំវិញការសាងសង់សំណង់បណ្តោះអាសន្នលើដីរដ្ឋដោយខុសច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញ

---

[91] រាជរដ្ឋាភិបាល, *ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី*, ២០០២, ៣៦។

[92] រាជរដ្ឋាភិបាល, *គោលនយោបាយដីធ្លី*, ២០១៥, ៤។

[93] រាជរដ្ឋាភិបាល, *គោលនយោបាយដីធ្លី*, ២០១៥, ៥៥។

[94] ហាប់ ផល្លី, " ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា ", (មេរៀនជា PowerPoint សម្រាប់និស្សិត សិក្សានៅសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៩), ៥។

[95] រាជរដ្ឋាភិបាល, *គោលនយោបាយដីធ្លី*, ២០១៥, ២។

សារាចរចំនួនពីរគឺ សារាចរលេខ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ និងសារាចរលេខ០៣.សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ដែលមានគោលដៅដោះស្រាយចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅតាមទីក្រុង និងទីប្រជុំជន។

**ក. សារាចរលេខ០២ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់**

សារាចរលេខ០២នេះ មានគោលដៅក្នុងការដោះស្រាយចំពោះការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅលើទីតាំងដីព្រៃ និងដីនៅតំបន់ជនបទដោយបុគ្គលឯកជន ព្រមទាំងពិនិត្យលើករណីរំលោភជាក់ស្តែងនីមួយៗ និងការដោះស្រាយដោយមានការអនុគ្រោះ ជាពិសេសចំពោះគ្រួសារក្រីក្រ និងចំពោះដីធ្លីដែលបានធ្វើអាជីវកម្មពិតប្រាកដ។ សារាចរនេះ គឺទាក់ទងនឹងការអនុវត្តគោលការណ៍ដែលមានចែងនៅក្នុងមាត្រា១៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ និងគោលនយោបាយដែលផ្អែកលើស្ថានភាពនៃសង្គមជាតិដោយអនុញ្ញាតឱ្យគ្រួសារក្រីក្រ និងអ្នកគ្មានដីបន្តប្រើប្រាស់ដីដែលបានកាន់កាប់បណ្តោះអាសន្ន។ ខ្លឹមសារនៃការដោះស្រាយបញ្ហាប្រឈមនៃសារាចរនេះ គឺផ្តល់អាទិភាពចំពោះគ្រួសារក្រីក្រដែលគ្មានដី ឬខ្វះដី ឬជាជនងាយរងគ្រោះ ហើយបានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ រាជរដ្ឋាភិបាលអាចអនុគ្រោះដោយផ្តល់ដីក្នុងទំហំមួយសមស្របដើម្បីប្រកបរបរចិញ្ចឹមជីវិត និង/ឬស្នាក់នៅតាមករណីជាក់ស្តែង។[96] ចំពោះជនជាតិដើមភាគតិចដែលអាជ្ញាធរប្រពៃណីរបស់គេបានអះអាងថាដីដែលរដ្ឋទាមទារនោះស្ថិតក្រោមការប្រើប្រាស់ជាសមូហភាពរបស់ពួកគេ នោះការទាមទារត្រូវផ្អាកសិនរហូតដល់ដីនោះត្រូវបានចុះបញ្ជីជាដីរដ្ឋ។ ចំណែកឯដីដែលបានដកហូតមកវិញ បើដីនោះជាផ្នែកនៃដីឯកជនរបស់រដ្ឋ រដ្ឋអាចចាត់ចែងទៅតាមនីតិវិធីជាធរមានដូចជាលក់ ជួល ធ្វើប្រទានកម្ម ផ្តល់សិទ្ធិផលុបភោគ ផ្តល់ជាសម្បទានដី សង្គមកិច្ច ឬសេដ្ឋកិច្ចជាដើម។ រីឯការដកហូតមកវិញជាផ្នែកនៃដីសាធារណៈរបស់រដ្ឋ រដ្ឋអាចប្រើដីនោះទៅតាមរបបគតិយុត្ត ដូចជាជួលរយៈពេលខ្លី ផ្តល់សិទ្ធិផលុបភោគ អនុញ្ញាតឱ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នតាមរយៈការចុះកិច្ចព្រមព្រៀងផ្សេងៗ។

**ខ. សារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន**

សារាចរលេខ០៣ បង្កើតឡើងដើម្បីដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន។ ផ្អែកតាមសារាចរលេខ០៣នេះ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ តំណាងសហគមន៍ក្នុងមូលដ្ឋាន និងសង្គមស៊ីវិលជាសមាជិកចំពោះកិច្ច ត្រូវពិភាក្សា និងស្វែងរកដំណោះស្រាយចំពោះករណីជាក់ស្តែងរបស់ទីតាំងសំណង់បណ្តោះអាសន្ននីមួយៗ ដោយត្រូវចាត់

[96] រាជរដ្ឋាភិបាល, *គោលនយោបាយដីធ្លី*, ២០១៥, ៥៣។

ទុកជាប្រយោជន៍សាធារណៈជាអាទិភាព និងផ្អែកលើផលប្រយោជន៍របស់ប្រជាពលរដ្ឋភាគច្រើនក្នុងសហគមន៍ព្រមទាំងភាពចាំបាច់នៃការអភិវឌ្ឍរបស់មូលដ្ឋាន។[97] មួយវិញទៀតការដោះស្រាយចំពោះសំណង់បណ្ដោះអាសន្នលើដីរដ្ឋនេះ ក៏ជាយន្តការនៃដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរតាមរយៈការសម្របសម្រួល។ ការសម្របសម្រួលគឺត្រូវផ្អែកលើដំណោះស្រាយដែលបានឯកភាពគ្នារួច។ ចំពោះទីតាំងដែលមិនអាចអភិវឌ្ឍន៍នៅនឹងកន្លែងបាន ហើយត្រូវរុះរើទៅទីតាំងថ្មី និងត្រូវរៀបចំផែនការច្បាស់លាស់មុននឹងអនុវត្តដំណោះស្រាយដើម្បីសម្រួលដល់ការតាំងទីលំនៅថ្មីរបស់ប្រជាជន។ ក្នុងករណីណាក៏ដោយ ក៏អ្នកទទួលផលពីដំណោះស្រាយនៃការកាន់កាប់ដីរដ្ឋដោយខុសច្បាប់នៅតាមទីក្រុង ទីប្រជុំជន អាចទទួលបានសិទ្ធិផលុបភោគតាមការព្រមព្រៀង ឬសិទ្ធិកម្មសិទ្ធិបន្ទាប់ពីបានកាន់កាប់ផ្ទាល់ និងរស់នៅលើទីតាំងនោះយ៉ាងតិច ១០ឆ្នាំជាប់គ្នា ឬសិទ្ធិជួលរយៈពេលកំណត់ដោយប្រាក់ឈ្នួលអនុគ្រោះ។[98] មានតែករណីប្រទានកម្មជាពិសេសពីរាជរដ្ឋាភិបាលទេទើបសិទ្ធិកម្មសិទ្ធិអាចទទួលបានដោយគ្មានលក្ខខណ្ឌ។ ជារួមគោលនយោបាយលំនៅឋានផ្ដោតសំខាន់ទៅលើគ្រួសារដែលមានប្រាក់ចំណូលទាប មធ្យម និងក្រុមជនងាយរងគ្រោះ ក្នុងការទទួលបានលំនៅឋានសមរម្យ និងការដោះស្រាយជូនប្រជាពលរដ្ឋដែលរស់នៅបណ្ដោះអាសន្នលើទីតាំងមិនរៀបរយ ឱ្យទទួលបានលំនៅឋានសមស្របមានសុវត្ថិភាព និងផាសុកភាព និងជាយុទ្ធសាស្ត្រគាំទ្រដល់គ្រួសារសហគមន៍ក្នុងការស្វែងរកហិរញ្ញប្បទានសម្រាប់សាងសង់ ឬជួសជុលកែលម្អលំនៅឋាន។[99]

### គ. សារាចរ០៦ ស្ដីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ

បញ្ហានៃភាពក្រីក្រដោយសារពុំមានលំនៅឋានច្បាស់លាស់ គឺជាមូលហេតុនៃការបង្កើតសារាចរ០៦ នេះឡើង។ "សារាចរ០៦ នេះដែរគឺបានបង្ហាញពីគោលបំណងរបស់រដ្ឋាភិបាលក្នុងការដោះស្រាយនូវបញ្ហាភាពក្រីក្រ ដោយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការសាធារណៈ ដែលមានភាពលំបាកដោយសារពុំមានលំនៅឋានច្បាស់លាស់សម្រាប់រស់នៅ និងសម្រាប់ជីវភាព ព្រមទាំងដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋប្រកបដោយប្រសិទ្ធភាព។ តាមរយៈសារាចរនេះ ការផ្ដល់ជូននេះត្រូវគោរពនូវលក្ខខណ្ឌចំនួនពីរដូចខាងក្រោម៖ ទី១. ប្រជាពលរដ្ឋ ឬមន្ត្រីរាជការ ដែលមានប្រវត្តិ និងអត្តសញ្ញាណតាំងទីលំនៅ និង/ឬអាស្រ័យផលលើដីនោះយ៉ាងតិច១០ឆ្នាំ និងកំណត់ឆ្នាំចុងក្រោយគិតត្រឹមឆ្នាំ២០១៥ និងដោយមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច។ ទី២. ជាប្រជាពលរដ្ឋ ឬ មន្ត្រីរាជការក្រីក្រ មានជីវភាពខ្វះខាតពិតប្រាកដ និងមិន

---

[97] សារាចរលេខ០៣។

[98] រាជរដ្ឋាភិបាល, *គោលនយោបាយដីធ្លី*, ២០១៥, ៥៣។

[99] រាជរដ្ឋាភិបាល, *គោលនយោបាយដីធ្លី*, ២០១៥, ៥៦។

មានដី ឬផ្ទះជាកម្មសិទ្ធិផ្សេងទៀត។ ការកំណត់ពីទំហំដី ឬលំនៅឋាន សម្រាប់ប្រទានកម្ម គឺត្រូវធ្វើឡើងដោយអាជ្ញាធររបស់រដ្ឋ និងដោយតម្លាភាព ព្រមទាំងឈរលើគោលការណ៍សមធម៌។ ក្រោយការកាន់កាប់លើដីដែលរដ្ឋបានផ្តល់ជូនរយៈពេល ៥ ឆ្នាំ ទើបអាចស្នើសុំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន ដោយអនុលោមទៅតាមគោលការណ៍ផ្តល់សម្បទានដីសង្គមកិច្ច។"[100]

**ឃ. គោលនយោបាយជាតិស្តីពីលំនៅឋាន**

លំនៅឋានគឺជាជំរក និងជាទ្រព្យសម្បត្តិដ៏មានតម្លៃខាងសេដ្ឋកិច្ច និងសង្គមដ៏សំខាន់សម្រាប់គ្រួសារនីមួយៗ ដែលសង់ឡើងសម្រាប់រស់នៅ។ ស្របជាមួយនឹងអត្រាកំណើនប្រជាជនកម្ពុជា លំនៅឋានពិតជាមានលក្ខណៈចាំបាច់ សម្រាប់ប្រជាជនជាពិសេស អ្នកមានប្រាក់ចំណូលមធ្យម និងអ្នកមានប្រាក់ចំណូលទាប។ លំនៅឋានក៏ជាផ្នែកមួយដ៏សំខាន់នៃជីវិតរបស់មនុស្សដូចជាការធ្វើអាជីវកម្មពេញលេញក្នុងលំនៅឋាន និងជាប្រភពមួយក្នុងការរកប្រាក់ចំណូលសម្រាប់គ្រួសារ ឬរកចំណូលបន្ទាប់បន្សំ។ ដោយមើលឃើញពីអត្ថប្រយោជន៍ដ៏សំខាន់នៃលំនៅឋាន ទើបរាជរដ្ឋាភិបាលក្រោមការដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានដាក់ចេញនូវគោលនយោបាយផ្សេងៗ រួមមានគោលនយោបាយជាតិស្តីពីលំនៅឋានជាអាទិ៍ ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤។ គោលគំនិតដែលបានកំណត់នៅក្នុងគោលនយោបាយនេះ គឺចង់ឱ្យប្រជាជនគ្រប់រូបមានសិទ្ធិមានលំនៅឋានសមរម្យ ដែលស្របទៅនឹងសិទ្ធិមានជីវភាពគ្រប់គ្រាន់។ គោលនយោបាយជាតិស្តីពីលំនៅឋាននេះ ជាផ្នែកមួយនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាពដែលចែងថា "...កសាងគោលនយោបាយជាតិស្តីពីលំនៅឋាន ដើម្បីដោះស្រាយលំនៅឋានជូនប្រជាជនក្រីក្រសម្រាប់ការរស់នៅ ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងសេចក្តីថ្លៃថ្នូរ។"[101] គោលនយោបាយជាតិស្តីពីលំនៅឋានបានកំណត់អំពីផែនការយុទ្ធសាស្ត្រចំពោះការដោះស្រាយរាល់ការតាំងទីលំនៅបណ្តោះអាសន្នជាអាទិ៍រួមមាន៖

- ដោះស្រាយតម្រូវការលំនៅឋាននាពេលអនាគតតាមតម្រូវការ របស់ក្រុមគ្រួសារដែលមានប្រាក់ចំណូលទាប និងក្រុមជនរងគ្រោះ
- អនុញ្ញាតឱ្យអ្នកតាំងទីលំនៅមិនស្របច្បាប់ និងសហគមន៍ក្រីក្ររស់នៅជាបណ្តោះអាសន្នមានរយៈពេលកំណត់ ដើម្បីស្វែងរកដំណោះស្រាយតាមករណីនៃទីតាំងនីមួយៗ

[100] សារាចរស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ, លេខ០៦សរ, ២៣ កក្កដា ២០១៩ (ចាប់ពីពេលនេះទៅហៅថាសារាចរលេខ០៦)។

[101] រាជរដ្ឋាភិបាល, *គោលនយោបាយជាតិស្តីពីលំនៅឋាន*, ២០១៤, ២។

- ធានាចំពោះការផ្លាស់ប្តូរទីលំនៅជាជម្រើសចុងក្រោយ ស្របតាមនីតិវិធី គោលការណ៍ស្ម័គ្រចិត្ត គោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព និងគណនេយ្យភាព រួមទាំងមានការចូលរួមពីអ្នករងផលប៉ះពាល់
- ធ្វើសមាហរណកម្មការតាំងទីលំនៅជាថ្មីទៅក្នុងផែនការប្រើប្រាស់ដីនៅឃុំ សង្កាត់ ទីក្រុង ទីប្រជុំជន
- ធានា និងរក្សានិរន្តរភាពសង្គមរចនាសម្ព័ន្ធ និងតួនាទីនៃលំនៅឋានចាស់ និងលំនៅឋានថ្មីដោយមានការចូលរួមពីសហគមន៍ផ្ទាល់
- សិក្សាលទ្ធភាព និងនីតិវិធីនៃការរៀបចំរចនាសម្ព័ន្ធមូលនិធិសម្រាប់លំនៅឋាន និងការបង្កើតធនាគារសម្រាប់លំនៅឋាន
- ជួយគាំទ្រ និងផ្តល់សិទ្ធិចូលរួមសម្រេចរបស់ប្រជាជន និងសហគមន៍មូលដ្ឋាន។[102]

គោលនយោបាយនេះអាចសម្រេចទៅបាន លុះត្រាតែមានការចូលរួមសម្រេចរបស់សហគមន៍មូលដ្ឋាន ការផ្តល់ហិរញ្ញប្បទានសម្រាប់ជួសជុល ឬសាងសង់លំនៅឋានថ្មីដើម្បីដោះស្រាយតម្រូវការចំពោះមុខ បូករួមជាមួយនឹងការកំណត់មូលដ្ឋានសម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីនៅទីក្រុង ទីប្រជុំជន និងជនបទ ការរៀបចំប្រភេទផ្សេងៗនៃលំនៅឋានស្របតាមតម្រូវការផ្សេងៗគ្នារបស់ប្រជាជន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ និងការកំណត់តម្លៃសេវានៃការអនុញ្ញាតសាងសង់។[103]

### ២.២. លក្ខខណ្ឌនៃលំនៅឋានសមរម្យ

លំនៅឋានសមរម្យ គឺមានអត្ថន័យច្រើនបន្ថែមពីលំនៅឋាន ហើយដែលភាពខុសគ្នានោះគឺជាគុណផ្សំនៃលំនៅឋានសមរម្យ។ លំនៅឋាន គឺមានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងគោលនយោបាយដែលរដ្ឋាភិបាលបានបង្កើតឡើង និងរបាយការណ៍នានារបស់អង្គការក្រៅរដ្ឋាភិបាល រីឯសញ្ញាណនៃលំនៅឋានសមរម្យត្រូវបានបង្ហាញតាមរយៈឯកសារនានារបស់អង្គការសហប្រជាជាតិ តួយ៉ាងដូចជាប័ណ្ណព័ត៌មានលេខ២១ ដែលបានលើកឡើងពីសិទ្ធិមានលំនៅឋានសមរម្យ ជាដើម។ ដោយឡែកសិទ្ធិមានលំនៅឋានសមរម្យវិញ គឺមានកំណត់ឡើងតាមរយៈច្បាប់ជាតិ និងច្បាប់អន្តរជាតិ និងបង្ហាញក្នុងឯកសារនានារបស់អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាផងដែរ។

[102] រាជរដ្ឋាភិបាល, *គោលនយោបាយជាតិស្តីពីលំនៅឋាន*, ២០១៤, ៥។
[103] រាជរដ្ឋាភិបាល, *គោលនយោបាយជាតិស្តីពីលំនៅឋាន*, ២០១៤, ៥។

### ២.២.១. សញ្ញាណនៃលំនៅឋាន

លំនៅឋាន សំដៅទៅលើសំណង់សម្រាប់រស់នៅដែលមិនអាចផ្លាស់ទីបាន។ វាមិនមែនគ្រាន់តែជាជម្រក[104] និងជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅជាអចិន្ត្រៃយ៍របស់បុគ្គលម្នាក់ៗ[105]។ វាជាទ្រព្យសម្បត្តិមានតម្លៃសេដ្ឋកិច្ច និងសង្គមដ៏សំខាន់សម្រាប់គ្រួសារនីមួយៗ។[106] លំនៅឋានផ្តល់ និងការពារនូវតម្រូវការជាមូលដ្ឋានបំផុតមួយចំនួនរបស់យើង និងជាទីដែលប្រមូលផ្តុំនូវឯកជនភាពរបស់បុគ្គលគ្រប់រូប។ មិនតែប៉ុណ្ណោះ លំនៅឋានបានដើរតួនាទីជាច្រើន ដោយបានផ្តល់សុវត្ថិភាពគ្រប់គ្រាន់ការពារយើងពីការគំរាមកំហែងរាងកាយខាងក្រៅ និងការពារយើងពីលក្ខខណ្ឌផ្សេងៗទៀត ព្រមទាំងមានសារៈសំខាន់ក្នុងការបង្កើត និងការការពារអត្តសញ្ញាណសហគមន៍ និងទីកន្លែងនានានៅក្នុងពិភពលោកផងដែរ។[107]

### ២.២.២. សញ្ញាណនៃលំនៅឋានសមរម្យ

លំនៅឋានសមរម្យ គឺជាការផ្តល់លំនៅឋានដែលសមស្របនឹងគោលការណ៍សំខាន់នៃលំនៅឋានសមរម្យរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស។[108] លំនៅឋានសមរម្យនេះដែរត្រូវបានគេទទួលស្គាល់ថា ជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពសមរម្យ ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ។[109] ក្រៅតែពីច្បាប់អន្តរជាតិ ច្បាប់ជាតិតួយ៉ាងរដ្ឋធម្មនុញ្ញក៏បានលើកឡើងដោយប្រយោលពីសិទ្ធិមានលំនៅឋានសមរម្យនេះផងដែរ។ សិទ្ធិមានលំនៅឋានសមរម្យអាចឱ្យនិយមន័យថា សិទ្ធិស្ត្រី បុរស យុវជន និងកុមារគ្រប់រូបក្នុងការទទួលបាន និងរក្សាផ្ទះសម្បែងមួយគត់មត់ ហើយសហគមន៍ដែលពួកគេរស់នៅមានភាពសុខដុមរម្យនានិងសេចក្តីថ្លៃថ្នូរ។[110]

---

[104] អង្គការសមាគមធាងត្នោត, *ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី៖ ការសិក្សាស្រាវជ្រាវពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីក្នុងរាជធានីភ្នំពេញ*, ២០២០, III។

[105] សារព័ត៌មានថ្មីៗ៖ *«លំនៅឋាន» «លំនៅដ្ឋាន» និង «លំនៅស្ថាន» ប្រើមួយណាត្រឹមត្រូវ?* https://thmeythmey.com/?page=detail&id=92704 *(បានចូលមើលចុងក្រោយថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២)*។

[106] រាជរដ្ឋាភិបាល, *គោលនយោបាយជាតិស្តីពីលំនៅឋាន*, ២០១៤, ១។

[107] Jessie Hohmann, "The Elements of Adequate Housing: Grenfell as Violation", [ធាតុផ្សំនៃលំនៅឋានសមរម្យ៖ ការរំលោភបំពានដោយហ្គ្រេនហ្វែល], Queen Mary Human Rights Law Review 5(2) (២៧ សីហា ២០១៩),២។

[108] ដូច១០៤, ទំព័រIV។

[109] អង្គការសហប្រជាជាតិ, *សិទ្ធិមានលំនៅឋានសមរម្យ*, ប័ណ្ណព័ត៌មានលេខ២១ (Rev.១), បកប្រែ និងបោះពុម្ពឡើងវិញដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា, ២០១៨, ១។

[110] ដូច៦១, ទំព័រ៨-៩។

### ២.២.២.១. អត្ថិភាពនៃសិទ្ធិមានលំនៅឋានសមរម្យក្នុងច្បាប់ជាតិ

#### ក. សិទ្ធិមានលំនៅឋានសមរម្យក្នុងច្បាប់ជាតិ

##### ក.១. រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ពុំបានចែងពីសិទ្ធិមានលំនៅឋានសមរម្យនេះនៅក្នុងបទបញ្ញត្តិជាក់លាក់ណាមួយរបស់ខ្លួនឡើយ។ ខណៈដែលមានរដ្ឋធម្មនុញ្ញជាតិជាង៥០ នៅទូទាំងពិភពលោកបានចែងយ៉ាងច្បាស់ពីសិទ្ធិមានលំនៅឋានសមរម្យនេះ។[111] ក៏ប៉ុន្តែច្បាប់កំពូលមួយនេះបានកំណត់ពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរនៅក្នុងជំពូកទី៣ នៃច្បាប់កំពូលនេះ។ យោងតាមរដ្ឋធម្មនុញ្ញបានចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។"[112] តាមរយៈខ្លឹមសារនៃបញ្ញត្តិខាងលើ អាចស្តែងឱ្យឃើញថាកម្ពុជាទទួលស្គាល់ច្បាប់អន្តរជាតិ តួយ៉ាងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ដូចជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រោយពីការផ្តល់សច្ចាប័នទទួលយក ហើយបានភ្ជាប់កាតព្វកិច្ចជាមួយច្បាប់អន្តរជាតិទាំងនេះ។ សញ្ញាណនៃសិទ្ធិមានលំនៅឋានសមរម្យនេះ គឺមានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដ៏សំខាន់ និងជាមូលដ្ឋាននៃសិទ្ធិមនុស្សផ្សេងៗទៀត។

##### ក.២. ច្បាប់ភូមិបាល

##### ក.២.១. គោលបំណងនៃច្បាប់ភូមិបាល

ច្បាប់ភូមិបាល គឺបង្កើតឡើងដោយមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងប្រទេសកម្ពុជាក្នុងគោលបំណងធានាការពារសិទ្ធិ នៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣។[113] ក្នុងនោះដែរ សិទ្ធិនៃកម្មសិទ្ធិ ដែលចែងក្នុងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ អនុវត្តទៅលើអចលនវត្ថុទាំងអស់ នៃព្រះរាជាណាចក្រកម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ។[114]

---

[111] Christoph U. Schmid, "The Right to Housing as a Right to Adequate Housing Options" [សិទ្ធិទទួលបានលំនៅឋាន គឺជាសិទ្ធិដែលទទួលបានជម្រើសលំនៅឋានគ្រប់គ្រាន់], European Property Law Journal 9(2-3) (២០២០):១៦១។

[112] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៣១ កថាខណ្ឌទី១។

[113] ច្បាប់ភូមិបាល, មាត្រា១។

[114] ច្បាប់ភូមិបាល, មាត្រា៤។

#### ក.២.២. សិទ្ធិជាម្ចាស់អចលនវត្ថុនៅកម្ពុជា

ច្បាប់ភូមិបាល បានលើកឡើងពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលបានកំណត់ថា ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិនៅក្នុងមាត្រា៤ នៃច្បាប់នេះ។ មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី[115] ដែលនេះមានខ្លឹមសារដូចទៅនឹង មាត្រា៨ កថាខណ្ឌទី១ នៃច្បាប់ភូមិបាលដែរ។ ជាការពិតណាស់ច្បាប់ភូមិបាល បានផ្តល់ឱ្យប្រជាពលរដ្ឋខ្មែរនូវ ភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើអចលនវត្ថុដែលមានដីធ្លី និងផ្ទះជាដើម ដែលនេះជារូបភាពនៃការទទួល ស្គាល់សិទ្ធិមានលំនៅឋានតាមរយៈច្បាប់កម្ពុជា។ គួរកត់សម្គាល់ថា គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្ម សិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាម ទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ញា បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌[116] ដូចដែលមានកំណត់នៅក្នុងច្បាប់អស្សាមិករណ៍។

### ក.៣. ច្បាប់អស្សាមិករណ៍

#### ក.៣.១. គោលបំណងនៃច្បាប់អស្សាមិករណ៍

ច្បាប់អស្សាមិករណ៍ មានគោលដៅកំណត់ពីអស្សាមិករណ៍ ដែលជាការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន ដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើ ប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ចំពោះការដកហូតនេះគឺផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និងសំណងឱ្យបានសមរម្យ និង យុត្តិធម៌ ដែលនេះជាខ្លឹមសារដែលមានកំណត់នៅក្នុងច្បាប់អស្សាមិករណ៍។[117]

តាមរយៈបទបញ្ញត្តិខាងលើនេះ ផលប្រយោជន៍សាធារណៈដែលបានកំណត់ឡើង សំដៅដល់ការធ្វើ អ្វីមួយសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយអាចជួយកែលម្អការរស់នៅរបស់សមាជិកជាច្រើននៅក្នុង សង្គម តាមរយៈការផ្តល់នូវសេវាសាធារណៈសំខាន់ៗ ឬអ្វីមួយដែលជួយឱ្យប្រជាពលរដ្ឋមានសុវត្ថិភាព។[118] ទោះបីជា តែប្រជាពលរដ្ឋជាកម្មសិទ្ធិករលើអចលនទ្រព្យរបស់ខ្លួនដោយស្របច្បាប់ក៏ដោយ ក៏ប្រជាពលរដ្ឋត្រូវតែចាក ចេញពីលំនៅឋាន ឬដីរបស់ខ្លួន នៅពេលណាមួយដែលរដ្ឋាភិបាលមានហេតុផលសមរម្យត្រូវការប្រើប្រាស់ដី នោះដើម្បីធ្វើអ្វីមួយ ដែលជាប្រយោជន៍ជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឬជួយឱ្យប្រជា

---

[115] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤៤ កថាខណ្ឌទី១។

[116] ច្បាប់ភូមិបាល, មាត្រា៥។

[117] ច្បាប់អស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា១ (ពីពេលនេះតទៅហៅថាច្បាប់អស្សាមិករណ៍)។

[118] ដូច៦២, ទំព័រ៤៨។

ពលរដ្ឋមានសុវត្ថិភាព។[119] ក្នុងនោះដែរផលប្រយោជន៍សាធារណៈ ការពារមិនឱ្យមានឆ្លៀតឱកាសដកហូតយកដីមកជាប្រយោជន៍ផ្ទាល់ខ្លួន ឬដើម្បីទុកប្រើប្រាស់នាពេលក្រោយ ដូចជាការលក់ដីជាដើមឡើយ។[120]

### ក.៣.២. កិច្ចដំណើរការអស្សាមិករណ៍

ដំណើរការអស្សាមិករណ៍កើតឡើងពីការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ។ ការដកហូតនេះដែរ អាចធ្វើទៅបានលុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និងយុត្តិធម៌ តាមគោលការណ៍ និងនីតិវិធីនៃការទូទាត់សំណងដូចមានចែងនៅក្នុងផ្នែកទី៣ ជំពូកទី៤ នៃច្បាប់មួយនេះ។ ករណីមានទំនាស់ ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី នេះបើតាមខ្លឹមសារនៃច្បាប់អស្សាមិករណ៍។[121] ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុដ៏ទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍។ សេចក្តីសម្រេចអស្សាមិករណ៍ត្រូវសម្រេចជាអាទិ៍៖

- កម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវដកហូត
- សំណងដែលត្រូវទូទាត់
- កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិធ្វើការរុះរើចាកចេញពីទីតាំង និងធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍។[122]

### ក.៣.៣. ការទូទាត់សំណងនៃអស្សាមិករណ៍

លក្ខខណ្ឌនៃការផ្តល់សំណងជាមុន គឺមានកំណត់ក្នុងច្បាប់អស្សាមិករណ៍។ សំណង គឺជាចំនួននៃថវិកា ឬរបស់អ្វីមួយមានតម្លៃ ដែលត្រូវទូទាត់ជាថ្នូរនឹងអ្វីដែលខូចខាត។ សំណងអាចជាថវិកា ដី ផ្ទះថ្មី ឬរួមញ្ចូលគ្នាទាំងបីនេះ។[123] ការទូទាត់សំណងនៃអស្សាមិករណ៍នៅក្នុងច្បាប់ គឺប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍។[124] ចំពោះសំណងនេះដែរ គឺត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬជាសិទ្ធិជំនួសទៅតាមភាពជាក់ស្តែងដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ និងពី

---

[119] ដូច៤០, ទំព័រ២៥៩។
[120] ដូច៦២, ទំព័រ៤៨។
[121] ច្បាប់អស្សាមិករណ៍, មាត្រា១៩។
[122] ច្បាប់អស្សាមិករណ៍, មាត្រា២០។
[123] ដូច៦២, ទំព័រ១២៩។
[124] ច្បាប់អស្សាមិករណ៍, មាត្រា២២។

គណៈកម្មាធិការអស្សាមិករណ៍។ បែបបទ និងនីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[125]

### ២.២.២.២. អត្ថិភាពនៃសិទ្ធិមានលំនៅឋានសមរម្យក្នុងច្បាប់អន្តរជាតិ និងតំបន់

ច្បាប់អន្តរជាតិសំខាន់ៗមួយចំនួនដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាប្រភពមូលដ្ឋានដ៏សំខាន់នៃសិទ្ធិមនុស្ស។ សិទ្ធិទទួលបានលំនៅឋាន ដែលជាផ្នែកមួយនៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានចាក់គ្រឹះយ៉ាងមាំស្ថិតនៅនៅក្នុងច្បាប់អន្តរជាតិ ច្បាប់អឺរ៉ុប ច្បាប់ជាតិ និងពេលខ្លះនៅក្នុងច្បាប់ក្នុងតំបន់។[126] ចំពោះការទទួលស្គាល់សិទ្ធិលំនៅឋាននៅក្នុងច្បាប់អន្តរជាតិ គឺផ្អែកលើសារៈសំខាន់នៃលំនៅឋានចំពោះឯកជនភាព ស្វ័យភាព និងសេរីភាព។[127]

#### ក. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តក្នុងថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ហើយក្រោយមកគេត្រូវចំណាយរយៈពេល ២០ឆ្នាំ ដើម្បីព្រមព្រៀងគ្នាលើអត្ថបទនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។[128] ចំពោះសេចក្តីប្រកាសនេះដែរលោក Sergio Vieira de Mello អតីតឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានលើកឡើងថា៖

> "សេចក្តីប្រកាស គឺជាឯកសារដែលគ្មានកាលកំណត់ និងដ៏មានឥទ្ធិពល ដែលទាក់ទាញឱ្យមានសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅពីមនុស្សជាតិ ដើម្បីរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ សមភាព និងសន្តិសុខ។ សេចក្តីប្រកាសនេះ ផ្តល់ជូននូវស្តង់ដាអប្បបរមាផ្សេងៗ និងបានជួយកែប្រែបញ្ហាសីលធម៌ ទាំងឡាយឱ្យក្លាយទៅជាក្របខណ្ឌដែលមានប្រសិទ្ធភាពផ្លូវច្បាប់...។"[129]

នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានលើកឡើងពីសិទ្ធិមានលំនៅឋាន នៅក្នុងបទបញ្ញត្តិរបស់ខ្លួនថា "មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព

---

[125] ច្បាប់អស្សាមិករណ៍, មាត្រា២៤។

[126] ដូច១១, ទំព័រ១៦០។

[127] ដូច១០៧, ទំព័រ២។

[128] Mr. Manfred Nowak, Ludwig Boltzmann, Mr. Jeroen Klok និងMs. Ingeborg Schwarz, *សិទ្ធិមនុស្ស៖ កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ*, ២០០៥, ៣២។

[129] Sergio Vieira de Mello អតីតឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, *សារដែលបានថ្លែងនៅក្នុងឱកាសទិវាសិទ្ធិមនុស្ស ១០ ធ្នូ ២០០២*។

និងសុខមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចផ្សេងៗទៀត។"[130] ដែលនេះបង្ហាញពីអត្ថិភាពនៃសិទ្ធិមានលំនៅឋាន នៅក្នុងលិខិតុបករណ៍អន្តរជាតិមួយនេះ។

**ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាច្បាប់អន្តរជាតិដែលកំណត់ពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ មានរដ្ឋជាច្រើនបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិមួយនេះ ក្នុងនោះក៏មានរដ្ឋដែលនៅអាស៊ីអាគ្នេយ៍ផងដែរ។ នៅអាស៊ីអាគ្នេយ៍ រដ្ឋភាគីនៃសន្ធិសញ្ញានេះរួមមាន កម្ពុជា ឡាវ ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ ទីម័រខាងកើត និងវៀតណាម។ ដែលប្រ៊ុយណេ មីយ៉ាន់ម៉ា ម៉ាឡេស៊ី និងសឹង្ហបុរីមិនទាន់ បានផ្តល់សច្ចាប័ននៅឡើយទេ។[131]

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានបង្ហាញពីវត្តមាននៃសិទ្ធិមានលំនៅឋានសមរម្យដែលបានបញ្ញត្តិក្នុងកតិកាសញ្ញាមួយនេះថា "រដ្ឋភាគី នៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ប្រជាជនគ្រប់រូប ក្នុងការទទួលកម្រិតជីវភាពគ្រប់គ្រាន់ សម្រាប់ខ្លួនផ្ទាល់និងសម្រាប់គ្រួសារ ខ្លួន រួមមានចំណីអាហារ សំលៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំង ការរីកចម្រើន ជាលំដាប់នៃលក្ខណរស់នៅរបស់គេ។"[132] បទបញ្ញត្តិមួយនេះ គឺបានធានាសិទ្ធិមួយនេះដល់ជនគ្រប់រូប ដោយមិនមានការបែងចែក ព្រមទាំងធានាដល់សិទ្ធិក្នុងការទទួលបានការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅ និងតម្រូវឱ្យរដ្ឋត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យបានសម្រេចនូវសិទ្ធិមានលំនៅឋានសមរម្យនេះ។[133]

**គ. ធម្មនុញ្ញសង្គមរបស់អឺរ៉ុប**

ធម្មនុញ្ញនេះធានានូវសិទ្ធិសង្គម និងសិទ្ធិសេដ្ឋកិច្ច។ សិទ្ធិសេដ្ឋកិច្ច និងសង្គម ដែលបានបញ្ចូលក្នុងធម្មនុញ្ញជួយដោះស្រាយបញ្ហានៃអតុល្យភាពនៃសិទ្ធិដែលត្រូវបានការពារក្នុងទ្វីបអឺរ៉ុប។ ធម្មនុញ្ញនេះគឺពាក់ព័ន្ធយ៉ាងសំខាន់ជាមួយនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ យ៉ាងណាមិញ ការប្រើប្រាស់លិខិតុបករណ៍ផ្សេងៗគ្នា រួមចំណែកតិចតួចក្នុងការបញ្ជាក់ពីភាពមិនអាចបែងចែកដាច់ពីគ្នាបាននៃសិទ្ធិ។ ធម្មនុញ្ញសង្គមរបស់អឺរ៉ុបដើមត្រូវបានអនុម័តក្នុងឆ្នាំ១៩៦១។ ក្នុងឆ្នាំ១៩៩៦ ធម្មនុញ្ញសង្គមដែលបានកែសម្រួលមួយ បាន

---

[130] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, អនុម័តថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, មាត្រា២៥។

[131] Matthew Mullen និងMike Hayes, *AN INTRODUCTION TO Human Rights in Southeast Asia Volume 1* (Creative Commons: 2015) បកប្រែដោយ វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក *សេចក្តីផ្តើមពីសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍៖ វគ្គទី១*, ២០១៥, ៣២។

[132] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មាត្រា១១។

[133] អង្គការសហប្រជាជាតិ, *ស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ*, បោះពុម្ពឡើងវិញ (ភ្នំពេញ៖២០១៤), ១៣។

ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៩ ។ ជាការរំពឹងទុកដែលថាធម្មនុញ្ញដែលបានកែសម្រួលនេះនឹងជំនួសជាបណ្តើរៗនូវធម្មនុញ្ញទី១ ដែលត្រូវបានលម្អិតនៅក្នុងធម្មនុញ្ញថ្មី។[134]

ធម្មនុញ្ញសង្គមរបស់អឺរ៉ុបនេះដែរ ក៏បានលើកឡើងពីសិទ្ធិទទួលបានលំនៅឋាន ដោយមានបំណងធានាពីការអនុវត្តសិទ្ធិទទួលបានលំនៅឋានប្រកបដោយប្រសិទ្ធភាព រដ្ឋាភិបាលយល់ព្រមចាត់វិធានការដែលសំដៅ៖

- លើកកម្ពស់ការទទួលបានលំនៅឋានដែលមានស្តង់ត្រឹមត្រូវ
- ទប់ស្កាត់ និងកាត់បន្ថយភាពគ្មានទីជម្រកដើម្បីកាត់បន្ថយជាបណ្តើរៗ
- ធ្វើឱ្យតម្លៃលំនៅឋានអាចទទួលយកបានចំពោះអ្នកដែលគ្មានធនធានគ្រប់គ្រាន់។[135]

### ឃ. អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

សិទ្ធិទាំងឡាយដែលមាននៅក្នុងអនុសញ្ញាមួយនេះ គឺបានដកស្រង់ចេញពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ សិទ្ធិទាំងនោះមានដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព និងសន្តិសុខ សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ សិទ្ធិគោរពជីវិតបុគ្គល និងជីវិតគ្រួសារ ផ្ទះ សម្បែង សិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា សេរីភាពក្នុងការសម្តែងមតិ សេរីភាពក្នុងការប្រមូលផ្តុំ និងសមាគម សិទ្ធិក្នុងការរៀបការ និងបង្កើតគ្រួសារ សិទ្ធិក្នុងការទទួលបានសំណងសមស្របចំពោះការរំលោភលើសិទ្ធិ និងសេរីភាពក្នុងការរួចផុតពីការរើសអើងពាក់ព័ន្ធជាមួយសិទ្ធិ និងសេរីភាពជាក់លាក់។ សិទ្ធិមានលំនៅឋានដែលបានកំណត់ក្នុងអនុញ្ញានេះគឺ៖

- ជនគ្រប់រូបមានសិទ្ធិគោរពជីវិតបុគ្គល និងគ្រួសារ លំនៅឋាន និងការឆ្លើយឆ្លងរបស់ខ្លួន។
- គ្មានការធ្វើអន្តរាគមន៍ពីសំណាក់អាជ្ញាធរសាធារណៈក្នុងការអនុវត្តសិទ្ធិនេះទេ លើកលែងតែមានការអនុលោមទៅតាមច្បាប់ និងចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យដើម្បីជាប្រយោជន៍នៃសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ ឬសុខមាលភាពសេដ្ឋកិច្ចរបស់ប្រទេស សម្រាប់ទប់ស្កាត់ភាពឥតសណ្តាប់ធ្នាប់ ឬឧក្រិដ្ឋកម្ម ការពារសុខភាព ឬសីលធម៌ ឬការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។[136]

[134] Rhona K.M. Smith, *Textbook on International Human Rights* (United Kingdom: Oxford, 2014) បកប្រែដោយ វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក*សៀវភៅសិក្សាអំពីសិទ្ធិមនុស្ស*, ២០១៤, ១២៧-១២៨។

[135] ធម្មនុញ្ញសង្គមរបស់អឺរ៉ុប (កែសម្រួល), ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៩, មាត្រា៣១។

[136] អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, ចុះហត្ថលេខាដោយរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប នៅទីក្រុងរ៉ូម នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០, មាត្រា៨។

**ង. ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ**

នៅក្នុងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋនេះ ពុំបានបញ្ញត្តច្បាស់លាស់ពីសិទ្ធិមានលំនៅសមរម្យនោះទេ។[137] ក៏ប៉ុន្តែ ធម្មនុញ្ញនេះបានបញ្ញត្តិពីសិទ្ធិជាម្ចាស់កម្មសិទ្ធិដែលត្រូវបានធានា។ សិទ្ធិនេះអាចត្រូវបានបំពានក្នុងករណីជាតម្រូវការសាធារណៈ ឬផលប្រយោជន៍ទូទៅរបស់សហគមន៍ និងដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់ត្រឹមត្រូវ។[138] ក្នុងនោះដែរគណៈកម្មាធិការទ្វីបអាហ្វ្រិក បានយល់ថាធម្មនុញ្ញនេះត្រូវការពារសិទ្ធិមានលំនៅឋាន តាមរយៈសិទ្ធិផ្សេងៗទៀត តួយ៉ាងសិទ្ធិជាម្ចាស់កម្មសិទ្ធិនេះជាដើម។[139]

**ច. អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស"កតិកាសញ្ញាទីក្រុងសង់ចូហ្សេ ប្រទេសកូស្តារីកា"**

អនុសញ្ញាមួយនេះគឺមានអត្ថន័យស្រដៀងគ្នាទៅនឹងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋដែរ។ សញ្ញាណនៃសិទ្ធិមានលំនៅឋានពុំបានបញ្ញត្តិក្នុងអនុសញ្ញាមួយនេះឡើយ។ តែសិទ្ធិជាម្ចាស់កម្មសិទ្ធិគឺមានបង្ហាញក្នុងអនុសញ្ញាមួយនេះ។ អនុសញ្ញានេះបានចែងថា "សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើទ្រព្យសម្បត្តិរបស់ខ្លួនដែលជនគ្រប់រូបមាន។ ច្បាប់អាចទុកឱ្យសិទ្ធិប្រើប្រាស់ និងអាស្រ័យផលនោះជាបន្ទាប់បន្សំដើម្បីជាប្រយោជន៍ដល់សង្គម។ ហើយគ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិ លើកលែងតែមានការបង់សំណងជំងឺចិត្តត្រឹមត្រូវ ដោយមូលហេតុសម្រាប់ការប្រើប្រាស់សាធារណៈ ឬប្រយោជន៍សង្គម និងក្នុងករណីនិងអនុលោមតាមទម្រង់ដែលបង្កើតឡើងដោយច្បាប់។"[140]

ស្តែងតាមរយៈបទបញ្ញត្តិនៃច្បាប់អន្តរជាតិទាំងឡាយខាងលើនេះ អាចឱ្យយើងកំណត់បានថាសិទ្ធិមានលំនៅឋានសមរម្យ គឺជាសិទ្ធិដ៏សំខាន់សម្រាប់មនុស្សគ្រប់រូបក្នុងការទទួលបានលំនៅឋានមួយដែលអាចរស់នៅបានហើយដែលមានធាតុផ្សំនៃលំនៅឋានសមរម្យគ្រប់គ្រាន់។ លំនៅឋានសមរម្យ ត្រូវតែមានច្រើនជាង ការគ្រាន់តែមានដំបូល ១ និងជញ្ជាំង ៤ ផ្ទាំង។[141] តាមរយៈការកំណត់សិទ្ធិមានលំនៅឋាននេះនៅក្នុងច្បាប់ជាតិ អន្តរជាតិ និងក្នុងតំបន់ដើម្បីឱ្យលំនៅឋានមួយជាលំនៅឋានសមរម្យ គឺត្រូវបានរួមផ្សំដោយផ្សំទាំង៧ ដែលនឹងបង្ហាញនៅខាងក្រោមនេះ។

---

[137] ដូច១៣៣, ទំព័រ៣២។

[138] ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ, អនុម័តដោយសន្និបាតនៃថ្នាក់ដឹកនាំរដ្ឋ និងរដ្ឋាភិបាលនៃអង្គការឯកភាពអាហ្វ្រិក ធ្វើនៅទីក្រុងណារ៉ូប៊ី ប្រទេសកេនយ៉ា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១, មាត្រា១៤។

[139] ដូច១៣៣, ទំព័រ៣២។

[140] អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស "កតិកាសញ្ញាទីក្រុងសង់ចូហ្សេ ប្រទេសកូស្តារីកា", ចុះហត្ថលេខាដោយរដ្ឋសមាជិកនៃអង្គការរដ្ឋក្នុងទ្វីបអាមេរិក ធ្វើនៅទីក្រុងសង់ចូហ្សេ ប្រទេសកូស្តារីកា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩, មាត្រា២១។

[141] ដូច១០៩, ទំព័រ៤។

## ២.២.៣. ធាតុផ្សំនៃលំនៅឋានសមរម្យ

### ២.២.៣.១. សុវត្ថិភាពក្នុងការកាន់កាប់

លំនៅឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើអ្នកកាន់កាប់មិនមានសុវត្ថិភាពក្នុងការកាន់កាប់។[142] សុវត្ថិភាពក្នុងការកាន់កាប់ សំដៅដល់ការធានាតាមផ្លូវច្បាប់ប្រឆាំងនឹងការបណ្តេញចេញ ដោយបំពាន ការរំខាន និងការគម្រាមកំហែងដទៃទៀត។[143] វាត្រូវអនុវត្តដោយសមភាពចំពោះមនុស្សគ្រប់គ្នា ដែលជាកម្មសិទ្ធិករ ភោគី អ្នកជួល និងអ្នកកាន់កាប់ផងដែរ។[144] សុវត្ថិភាពក្នុងការកាន់កាប់ ក៏សំដៅផងដែរទៅដល់កម្មសិទ្ធិឯកជនដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងតាមរយៈច្បាប់ភូមិបាលឆ្នាំ ២០០១។ ចំពោះការកាន់កាប់នេះដែរកម្មសិទ្ធិករនៃដី ឬភោគី ត្រូវតែទទួលបាននូវសិទ្ធិផ្សេងៗលើអចលនវត្ថុរបស់ខ្លួន តួយ៉ាងសិទ្ធិប្រើប្រាស់ សិទ្ធិចាត់ចែង និងសិទ្ធិអាស្រ័យផលជាដើម ដែលមានកំណត់នៅក្នុងច្បាប់។

#### ក. ភាពខុសគ្នារវាងកម្មសិទ្ធិករ និងភោគី

##### ក.១. កម្មសិទ្ធិករ

កម្មសិទ្ធិករ ឬអ្នកកាន់កាប់កម្មសិទ្ធិ គឺជាម្ចាស់កម្មសិទ្ធិលើទ្រព្យ[145] និងមានសិទ្ធិកម្មសិទ្ធិ[146]។ សិទ្ធិកម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត។[147] ត្បិតតែកម្មសិទ្ធិករមានកម្មសិទ្ធិ ដែលជាបូរណសិទ្ធិមានន័យថាជាសិទ្ធិដ៏ពេញលេញ ឬបរិបូរណ៍ជាងគេបង្អស់[148] ក៏ដោយ ក៏កម្មសិទ្ធិករនៃដីមិនអាចប្រើប្រាស់ដីរបស់ខ្លួនក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬរំខានដល់ជីវភាពរបស់អ្នកដទៃបានឡើយ[149]។ ដើម្បីឱ្យការកាន់កាប់មានសុវត្ថិភាព កម្មសិទ្ធិករនៃដីត្រូវមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ដែលជា

[142] ដូច១៤១។

[143] ដូច១៣៣, ទំព័រ៤។

[144] ដូច៦២, ទំព័រ៣២។

[145] សទ្ទានុក្រមច្បាប់ភូមិបាលឆ្នាំ ២០០១។

[146] ដូច៤០, ទំព័រ៦៥។

[147] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា១៣៨ (ពីពេលនេះតទៅហៅថាក្រមរដ្ឋប្បវេណី)។

[148] ហ៊ែល ចំរើន, *សេចក្តីផ្តើមសិក្សាអំពីនីតិភូមិបាល*, (អង្គការខុនរ៉ាដ អាដេណៅអ៊ែរ), ៧។

[149] ក្រមរដ្ឋប្បវេណី, មាត្រា១៣៩។

ទូទៅគេហៅថាប្លង់រឹង។ ប្លង់រឹង វាជាប័ណ្ណដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច គឺរដ្ឋបាលសុរិយោដី[150] ហើយដែលចេញជូនចំពោះតែកម្មសិទ្ធិករប៉ុណ្ណោះ[151]។

**ក.២. ភោគី**

ភោគី គឺជាអ្នកទទួលភោគៈ។[152] ដែលភោគៈ សំដៅដល់សិទ្ធិ ដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្តោះអាសន្ន មិនទាន់ស៊ប់ជារបស់ខ្លួនមែនទែន។ ភោគៈ នេះដែរគឺជាពាក្យផ្ទុយនឹងកម្មសិទ្ធិ ដែលជាសិទ្ធិពេញបរិបូរណ៍របស់ជនម្នាក់ៗលើទ្រព្យណាមួយ។[153] សិទ្ធិរបស់ភោគី គឺភោគៈមានតិចជាងកម្មសិទ្ធិ ដែលជាសិទ្ធិរបស់កម្មសិទ្ធិករ។ ព្រោះតែមានតែភោគីស្របច្បាប់តែប៉ុណ្ណោះ ដែលអាចបំពេញលក្ខខណ្ឌនានាដើម្បីក្លាយទៅជាកម្មសិទ្ធិករ និងអាចទទួលបានប័ណ្ណកម្មសិទ្ធិ។[154] ដើម្បីក្លាយជាភោគៈស្របច្បាប់ មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិជាស្ថាពរ ភោគីត្រូវបំពេញលក្ខខណ្ឌតម្រូវតាមច្បាប់ជាច្រើនមានដូចជា បានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទ នៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល។[155] នេះមានន័យថាការកាន់កាប់ដីត្រូវតែចាប់ផ្តើមរយៈពេល ៥ ឆ្នាំ មុនការចូលជាធរមាននៃច្បាប់ភូមិបាល នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ ម្យ៉ាងទៀត ដើម្បីក្លាយទៅជាកម្មសិទ្ធិករលើអចលនវត្ថុបានលុះត្រាតែភោគីនោះបានកាន់កាប់ដោយពិតប្រាកដ គ្មានហឹង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។[156]

**ខ. ប្រភេទនៃការកាន់កាប់ដីធ្លី**

ប្រភេទនៃការកាន់កាប់ដីធ្លី គឺមានច្រើនប្រភេទ។ ហើយក្នុងនោះមានដូចជា ការកាន់កាប់ដីធ្លីលើដីរបស់រដ្ឋ ការកាន់កាប់ដីធ្លីដែលមិនស្ថិតលើដីរបស់រដ្ឋ និងការកាន់កាប់ដីធ្លីដែលស្ថិតនៅលើដីសាធារណៈរបស់រដ្ឋផងនិងលើដីឯកជនផង។ ប្រភេទនៃការកាន់កាប់ដីធ្លីមានដូចខាងក្រោម៖[157]

---

[150] ច្បាប់ភូមិបាល, មាត្រា២៤១, *"រដ្ឋបាលសុរិយោដីអាចចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ វិញ្ញាបនប័ត្របញ្ជាក់ហ៊ីប៉ូតែក សលាកប័ត្រពត៌មាន និង លិខិតបញ្ជាក់សុរិយោដីអំពីប្រភេទ ស្ថានភាពគតិយុត្ត លក្ខណៈរូប និង បន្ទុក នៃក្បាលដី ដោយផ្អែកលើឯកសារ និង សៀវភៅគោលបញ្ជីដី។"*

[151] ច្បាប់ភូមិបាល, មាត្រា២៤២។

[152] សទ្ទានុក្រមច្បាប់ភូមិបាលឆ្នាំ ២០០១។

[153] សទ្ទានុក្រមច្បាប់ភូមិបាលឆ្នាំ ២០០១។

[154] ដូច៤០, ទំព័រ១១៣-១១៤។

[155] ច្បាប់ភូមិបាល, មាត្រា៣០។

[156] ច្បាប់ភូមិបាល, មាត្រា៣៨។

[157] People in Need, *គោលការណ៍ណែនាំស្តីពីការរៀបចំដីធ្លីផ្អែកលើសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា*, ២០១៥, ៣០ (តារាង២)។

| ប្រភេទការកាន់កាប់ដីធ្លី | | ការពន្យល់ | លទ្ធភាពនៃការដាក់បណ្ដឹងទាមទារកម្មសិទ្ធិ |
|---|---|---|---|
| ក | មិនមែននៅលើដីសាធារណៈរបស់រដ្ឋការកាន់កាប់ចាប់ផ្ដើមមុនឆ្នាំ២០០១ មានឯកសារកាន់កាប់មុនឆ្នាំ ២០០១។ | អចលនទ្រព្យនេះ មិនស្ថិតនៅលើដីសារធារណៈរបស់រដ្ឋ។ គ្រួសារទាំងនោះចាប់ផ្ដើមការកាន់កាប់មុនឆ្នាំ ២០០១ និងមានឯកសារកាន់កាប់ដែលបង្ហាញពីការចាប់ផ្ដើមកាន់កាប់មុនឆ្នាំ២០០១។ | មានភាពខ្លាំងក្នុងការអះអាងការកាន់កាប់ស្របច្បាប់។ |
| ខ | មិនមែននៅលើដីសាធារណៈរបស់រដ្ឋការកាន់កាប់ចាប់ផ្ដើមមុនឆ្នាំ២០០១ មានឯកសារកាន់កាប់ប៉ុន្តែចេញក្រោយឆ្នាំ២០០១។ | អចលនទ្រព្យនេះមិនស្ថិតនៅលើដីដែលចាត់ថ្នាក់ជាដីសារធារណៈរបស់រដ្ឋ។ គ្រួសារទាំងនោះបានចាប់ផ្ដើមការកាន់កាប់មុនឆ្នាំ២០០១ និងមានឯកសារកាន់កាប់ ប៉ុន្តែឯកសារនេះមិនបានបង្ហាញថាការកាន់កាប់នេះចាប់ផ្ដើមមុនឆ្នាំ២០០១។ | អាចមានលទ្ធភាពអះអាងការកាន់កាប់ស្របច្បាប់បាន ប៉ុន្តែនឹងត្រូវពឹងផ្អែកលើទម្រង់ឯកសារផ្សេងៗទៀត (ដូចជាសៀវភៅគ្រួសារជាដើម) ដើម្បីបង្ហាញថាការកាន់កាប់នោះបានចាប់ផ្ដើមមុនឆ្នាំ២០០១។ |
| គ | មិនមែននៅលើដីសាធារណៈរបស់រដ្ឋការកាន់កាប់ចាប់ផ្ដើមមុនឆ្នាំ២០០១ ពុំមានឯកសារកាន់កាប់ណាមួយឡើយ។ | អចលនទ្រព្យនេះមិនស្ថិតនៅលើដីដែលចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ គ្រួសារទាំងនោះ ចាប់ផ្ដើមកាន់កាប់មុនឆ្នាំ២០០១ ប៉ុន្តែពុំមានឯកសារកាន់កាប់ណាមួយឡើយ។ | អាចមានលទ្ធភាពអះអាងការកាន់កាប់ស្របច្បាប់បាន ប៉ុន្តែនឹងត្រូវពឹងផ្អែកលើទម្រង់ឯកសារផ្សេងៗទៀត (ដូចជាសៀវភៅគ្រួសារជាដើម) ដើម្បីបបង្ហាញថាការកាន់កាប់នោះ បានចាប់ផ្ដើមមុនឆ្នាំ២០០១។ |
| ឃ | មិនមែននៅលើដីសាធារណៈរបស់រដ្ឋការកាន់កាប់ចាប់ផ្ដើមក្រោយឆ្នាំ២០០១។ | អចលនទ្រព្យនេះមិនស្ថិតនៅលើដីដែលចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ គ្រួសារទាំងនោះ ចាប់ផ្ដើមការកាន់កាប់បន្ទាប់ពីឆ្នាំ២០០១។ | អាចមានលទ្ធភាពអះអាងការកាន់កាប់ស្របច្បាប់បាន ក៏ប៉ុន្តែត្រូវប្រមូលឯកសារ ដែលបង្ហាញពីសង្វាក់ នៃការកាន់កាប់តាំងពីមុនឆ្នាំ២០០១។ |

| | | | |
|---|---|---|---|
| ង | ដីនោះទំនងជាជាន់គ្នាជាមួយដីសាធារណៈរបស់រដ្ឋ | ផ្នែកមួយចំនួននៃដីនេះទំនងជាស្ថិតនៅលើដីដែលត្រូវបានចាត់ថ្នាក់ជាដីសារណៈរបស់រដ្ឋ និងផ្នែកមួយចំនួនទៀតនៃដីនេះមិនត្រូវបានចាត់ថ្នាក់ជាដីសារណៈរបស់រដ្ឋ។ | អាចមានលទ្ធភាពអះអាងការកាន់កាប់ស្របច្បាប់បានសម្រាប់ដី ដែលមិនត្រូវបានចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ប្រសិនបើបានចាប់ផ្ដើមកាន់កាប់តាំងពីមុនឆ្នាំ២០០១។ គ្រួសារនោះមិនអាចទាមទារការកាន់កាប់ចំណែកដីណាមួយដែលត្រូវបានចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋឡើយ។ |
| ច | ផ្ទៃដីទាំងមូល (ឬភាគច្រើន) គឺស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ។ | ក្បាលដីទាំងមូល (ភាគច្រើននៃដីនេះ) របស់គ្រួសារនោះ ស្ថិតនៅលើដីសាធារណៈរបស់រដ្ឋ។ | គ្រួសារនោះទំនងជាមិនអាចទាមទារអះអាងការកាន់កាប់ស្របច្បាប់បានឡើយ ដោយសារដីនោះ ទំនងជាស្ថិតនៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ |

ជារួមមក វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ គឺការពារអ្នកកាន់កាប់ពីការបណ្ដេញដោយបង្ខំ ហើយវាបង្កើតឱ្យមានសុវត្ថិភាពក្នុងការកាន់កាប់អចលនវត្ថុដល់កម្មសិទ្ធិករ ឬភោគី។ ចំពោះសុវត្ថិភាពក្នុងការកាន់កាប់ ក្នុងនោះមានការប្ដេជ្ញាចិត្តជាសាធារណៈដែលអនុញ្ញាតឱ្យសហគមន៍ដែលមានស្រាប់បន្តនៅនឹងកន្លែង និងពង្រីកប្រព័ន្ធចុះបញ្ជីដីធ្លី និងលំនៅឋានថ្នាក់ជាតិ ដើម្បីអនុញ្ញាតឱ្យមានការដាក់បញ្ចូលសិទ្ធិកាន់កាប់ថ្មីរបស់ជនក្រីក្រ។[158] រដ្ឋភាគី គួរផ្ដល់សិទ្ធិកាន់កាប់ស្របច្បាប់ដល់បុគ្គល ឬគ្រួសារដែលខ្វះខាតការការពារបែបនេះនាពេលបច្ចុប្បន្ន ដោយមានការពិគ្រោះយោបល់ពិតប្រាកដមួយជាមួយបុគ្គល និងក្រុមទាំងឡាយដែលរងផលប៉ះពាល់។[159] ដែលនេះជារូបភាពនៃការធានាការកាន់កាប់ដោយសុវត្ថិភាព។

**២.២.៣.២. ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អគារ ឬកន្លែងផ្ដល់សេវា និងហេដ្ឋារចនាសម្ព័ន្ធ**

លំនៅឋានមានលក្ខណៈសមរម្យ ពេលណាដែលមានសេវានានាដូចជាទឹកស្អាត ថាមពលគ្រប់គ្រាន់សម្រាប់ចម្អិនអាហារ ប្រព័ន្ធកំដៅឧបករណ៍សម្រាប់បំភ្លឺ មធ្យោបាយរក្សាទុកម្ហូបអាហារ ឬកន្លែងចាក់កាក

---

[158] Scott Leckie, Legal and Protection Policy Research Series៖ Housing, Land and Property Rights in Post-Conflict Societies [ស៊េរីស្រាវជ្រាវច្បាប់ និងគោលនយោបាយការការពារ៖ លំនៅឋាន ដីធ្លី និងសិទ្ធិលើអចលនទ្រព្យ ក្នុងសង្គមក្រោយជម្លោះ] (UNHCR, 2005), 42។

[159] ដូច១៣៣, ទំព័រ១៩-២០។

សំណល់ ដែលអាចឱ្យពលរដ្ឋអាចទទួលសេវាទាំងនោះបាន។[160] តាមរបាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា បានបង្ហាញថា គ្រួសារភាគច្រើនបានប្រើប្រាស់ទឹក បឹង ស្រះ ទន្លេ អូរ ឬទឹកដែលទិញពីម្ចាស់ប្រភព ឬប្រើប្រាស់ប្រព័ន្ធទឹកសាធារណៈ ក្នុងនោះគ្រួសារដែលរស់នៅទីក្រុងគឺបានប្រើប្រាស់ប្រព័ន្ធទឹកសាធារណៈ។[161] របាយការណ៍ដដែលបានបង្ហាញថា "ប្រទេសកម្ពុជាមិនទាន់មានបញ្ជាក់ពីទំហំស្តង់ដារសម្រាប់លំនៅឋាននៅឡើយទេ ក៏ប៉ុន្តែបើតាមចម្លើយដែលបានទទួលពីការសម្ភាសន៍គឺចាប់ពី ៣,៥ ម៉ែត្រការ៉េ សម្រាប់មនុស្សម្នាក់ ឬ២១-២៧ ម៉ែត្រការ៉េ សម្រាប់គ្រួសារដែលមានសមាជិក ៦ នាក់។"[162] ក្រៅពីសេវានានាខាងលើនៅមានសេវាសំខាន់ៗមួយចំនួនទៀតតួយ៉ាងសេវាសុខភាព សេវាអប់រំ ជាសេវាសាធារណៈដែលចាំបាច់ដែលមនុស្សគ្រប់រូបត្រូវតែទទួលបានដោយខ្វះពុំបាន។ ភាពសំខាន់នៃការទទួលបានសេវាទាំងនេះគឺជួយឱ្យមនុស្សគ្រប់រូបរស់នៅដោយមានអនាម័យ មានសុខភាពល្អប្រសើរ និងរស់នៅដោយមានភាពសុខសាន្ត។

**២.២.៣.៣. ភាពអាចលៃលកបាន**

ចំពោះការចំណាយនានាសម្រាប់បុគ្គល ឬសម្រាប់គ្រួសារដែលទាក់ទងនឹងលំនៅឋាន គឺត្រូវមានតុល្យភាពរវាងការចំណាយ និងប្រាក់ចំណូល។[163] ការឧបត្ថម្ភក្នុងការទិញផ្ទះ គួរត្រូវតែបង្កើតឱ្យមានសម្រាប់ជនដែលមិនមានលទ្ធភាពទិញផ្ទះក្នុងតម្លៃសមរម្យ ម្យ៉ាងទៀតអ្នកជួលផ្ទះគេនៅក៏គួរតែត្រូវបានការការពារនូវការឡើងថ្លៃឈ្នួលផ្ទះដោយមិនសមហេតុផលផងដែរ។[164] ការបង្កើតការឧបត្ថម្ភធនចំពោះអ្នកដែលគ្មានលទ្ធភាពទទួលបានលំនៅឋានដែលពួកគេអាចលៃលកបាន គឺជាអ្វីដែររដ្ឋាភិបាលត្រូវយកចិត្តទុកដាក់។[165] ចំពោះបណ្តាប្រទេសដែលសម្បូរដោយធនធានធានធម្មជាតិ ហើយវាជាប្រភពចម្បងសម្រាប់យកមកធ្វើជាសម្ភារៈលំនៅឋាន រដ្ឋគប្បីធានាថាធនធានទាំងនោះពិតជាយកមកសម្រាប់សង់លំនៅឋានពិតប្រាកដមែន។[166]

---

[160] ដូច១០៩, ទំព័រ៥។

[161] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា, *ការសិក្សាពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅកន្លែងតាំងទីលំនៅថ្មីក្នុងប្រទេសកម្ពុជា និងសេចក្តីព្រាងគោលការណ៍ណែនាំអំពីការតាំងទីលំនៅថ្មី*, ២០២២, ២៨។

[162] ដដែល, ទំព័រ២៧។

[163] ដូច១៣៣, ទំព័រ២០-២១។

[164] ដូច១២៨, ទំព័រ២៧៧។

[165] ដូច១៥៤។

[166] អនុសាសន៍រួមលេខ៤ ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ អនុម័តនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១ ដោយគណកម្មាធិការទទួលបន្ទុកផ្នែកសិទ្ធិសេដ្ឋកិច្ច និងវប្បធម៌។

### ២.២.៣.៤. ភាពអាចរស់នៅបាន

ភាពអាចរស់នៅបាន វាជាធាតុផ្សំនៃលំនៅឋានសមរម្យ ដែលធានាសុវត្ថិភាពរូបកាយ ឬមានទីធ្លាធំទូលាយគ្រប់គ្រាន់ ដែលអាចការពារទប់ទល់នឹងអាកាសធាតុត្រជាក់ ក្តៅ ភ្លៀង ខ្យល់ និងការគំរាមកំហែងដល់សុខភាព ហានិភ័យនៃសំណង់ និងសត្វល្អិតចម្លងមេរោគ។[167] ក្នុងនោះដែរសុវត្ថិភាពផ្នែករូបរាងកាយរបស់អ្នករស់នៅគឺត្រូវបានធានា។[168]

### ២.២.៣.៥. ភាពអាចប្រើប្រាស់បាន

ភាពអាចប្រើប្រាស់បាន គឺមានទំនាក់ទំនងគ្នានឹងការរើសអើងដែលវាជាឧបសគ្គដែលនាំឱ្យលំនៅឋានគ្មានសមរម្យឡើយ បើសិនជាមានការរើសអើងកើតឡើង។ ភាពអាចប្រើប្រាស់បាន គឺត្រូវធានាថាក្រុមដែលមានការលំបាកមិនត្រូវបានគេរើសអើងហើយមានលទ្ធភាពទទួលបានលំនៅឋានគ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាព។[169] នេះមានន័យថាតម្រូវការជាក់លាក់របស់ក្រុមដែលងាយរងគ្រោះ និងទីទ័លក្របំផុតនឹងត្រូវបានគេគិតគូដល់។[170] វាជាការប្រសើរនៅពេលដែលរដ្ឋបានពិចារណាបង្កើតគោលនយោបាយ និងច្បាប់ដែលបានគិតគូដល់តម្រូវការរបស់ពួកគេ ជាពិសេសគឺតម្រូវការលំនៅឋាន។[171]

### ២.២.៣.៦. ទីតាំង

លំនៅឋានត្រូវស្ថិតនៅក្នុងទីតាំងមួយ ដែលអនុញ្ញាតឱ្យមានជម្រើសការងារ មានមន្ទីរពេទ្យ ឬមណ្ឌលសុខភាព មានសាលារៀន មានមណ្ឌលថែទាំកុមារ និងមាននូវការផ្តល់សេវាសង្គមផ្សេងៗទៀត។ ក្នុងនោះដែរលំនៅឋានគឺត្រូវស្ថិតនៅក្នុងបរិស្ថានមួយដ៏ល្អ។ គេមិនគប្បីសង់លំនៅឋាននៅទីណាដែលមានបរិស្ថានកខ្វក់ ឬសង់លំនៅឋាននៅជិតប្រភពបរិស្ថានកខ្វក់នោះឡើយ។[172]

### ២.២.៣.៧. ភាពសមរម្យផ្នែកវប្បធម៌ និងប្រពៃណី

ការគិតពីអត្តសញ្ញាណវប្បធម៌នៃលំនៅឋាន គឺជារឿងដ៏សំខាន់។ ព្រោះមនុស្សយើងមានអត្តសញ្ញាណវប្បធម៌ផ្សេងៗគ្នា។ អត្តសញ្ញាណវប្បធម៌នៃលំនៅឋាន គឺមានការខុសគ្នាពីតំបន់មួយទៅតំបន់មួយ ពីប្រទេសមួយទៅប្រទេសមួយ។ លក្ខណៈសមរម្យនៃលំនៅឋានមិនមានឡើយប្រសិនបើលំនៅឋាននោះមិនគោរព និងគិត

---

[167] ដូច១៥៨។

[168] ដូច១២៨, ទំព័រ២៧៨។

[169] ដូច១០៧, ទំព័រ៩។

[170] ដូច១០៩, ទំព័រ៥។

[171] ដូច១៣៣, ទំព័រ២៣។

[172] ដូច១៦៦។

គួពីអត្តសញ្ញាណវប្បធម៌នេះ។[173] រាល់ការអភិវឌ្ឍ និងនគរូបនីយកម្មតំបន់លំនៅឋាន គប្បីត្រូវធានាថាវប្បធម៌មិនត្រូវបានគេបំភ្លេចនោះឡើយ ហើយក្នុងនោះដែរអាគារបច្ចេកវិទ្យាទំនើប បើសិនជាអាចធ្វើបាននោះក៏គួរតែធានាឱ្យមានលក្ខណៈវប្បធម៌ដែរ។

[173] ដូច១០៩, ទំព័រ៥។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការមិនដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋ នឹងបណ្តាលឱ្យមានបញ្ហាសង្គម ដែលប៉ះពាល់ដល់ការអនុវត្តគោលនយោបាយដីធ្លីរបស់រដ្ឋាភិបាល។ បញ្ហានៃការតាំងទីលំនៅលើដីរដ្ឋដោយខុសច្បាប់នៅតែបន្តកើតមាន។ ចំពោះបញ្ហានេះគឺទាមទារឱ្យមានការដោះស្រាយតាមរយៈគោលនយោបាយនានាដែលបានដាក់ចេញដោយរដ្ឋាភិបាល រួមផ្សំជាមួយការតាំងចិត្តរបស់អាជ្ញាធរក្នុងការដោះស្រាយបញ្ហានេះ។ ជាឧទាហរណ៍ជាក់ស្តែងចំពោះសហគមន៍បុរីកីឡា ដែលមានទំនាស់ដីធ្លីជាយូរមកហើយនោះ "មានប្រជាពលរដ្ឋខ្លះបានមករស់នៅលើដីសហគមន៍នេះដោយខុសច្បាប់ ដោយពុំមានឯកសារពាក់ព័ន្ធដើម្បីទទួលបានដីសម្បទាននោះឡើយ ក៏ប៉ុន្តែរដ្ឋាភិបាលបានចង្អុលបង្ហាញឱ្យរដ្ឋបាលរាជធានីភ្នំពេញធ្វើការដោះស្រាយជូនពួកគាត់ទាំងអស់។"[174] ដែលនេះបង្ហាញពីការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋ។ ត្បិតតែរដ្ឋាភិបាលបានបង្កើតនូវគោលនយោបាយ និងបានបង្កើតនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដើម្បីដោះស្រាយបញ្ហានេះក៏ដោយក៏ជម្លោះដីធ្លីនេះនៅតែជាជំងឺមហារីករបស់កម្ពុជា ដែលនៅបន្តកើតមានរហូតមកដល់បច្ចុប្បន្ន។ ចំពោះការដោះស្រាយបញ្ហាទំនាស់ដីធ្លីនេះដែរគឺត្រូវ "ឈរនៅលើគោលការណ៍ច្បាប់ និងគោលការណ៍សិទ្ធិលំនៅឋាន។"[175] ក្រៅតែពីអ្នកដែលរស់នៅលើសំណង់បណ្តោះអាសន្នលើដីរដ្ឋ ក៏មានប្រជាពលរដ្ឋផ្សេងទៀត ដែលបានរស់នៅដោយគ្មានលំនៅឋានសមរម្យនេះផងដែរ។ តាមការសម្ភាសន៍ជាមួយអ្នកប្រកបរបរធាក់ស៊ីក្លូ និងរត់ម៉ូតូឌុប ចំនួន៥០នាក់ ក្នុងនោះគឺមានចំនួន២៥នាក់ ដែលស្មើរនឹង ៥០% ដែលពួកគាត់រស់នៅដោយគ្មានលំនៅឋាន។[176] ដោយពួកគាត់ទាំងនោះរស់នៅតាមសំយ៉ាបផ្ទះរបស់អ្នកដទៃ ក៏ដូចជាស្នាក់នៅលើស៊ីក្លូរបស់ពួកគាត់ ដែលធ្វើឱ្យជួបប្រទះបញ្ហា ជាច្រើនជាពិសេសគឺបញ្ហាដែលទាក់ទងនឹងសុវត្ថិភាពរបស់ពួកគាត់។ ជាការពិតណាស់សិទ្ធិមានលំនៅឋានសមរម្យគឺជាសិទ្ធិមនុស្សមួយដែលគ្រប់គ្នាគួរទទួលបានដោយមានលំនៅឋានសមរម្យ និងមិនមានការរើសអើង។

---

[174] ឃួង ស្រេង, សន្និសីទសារព័ត៌មានស្តីពីវឌ្ឍនភាព និងទិសដៅបន្តរបស់រដ្ឋបាលរាជធានីភ្នំពេញ, *Fresh News*, ១៦ មិថុនា ២០២០។

[175] ដូច១៧៤។

[176] ទិន្នន័យសម្ភាសផ្ទាល់ជាមួយអ្នកប្រកបរបរធាក់ស៊ីក្លូ និងអ្នករត់ម៉ូតូឌុប តាមរយៈគម្រោងការផ្សព្វផ្សាយ និងអប់រំពីបញ្ហាកូវីដដល់អ្នករត់ម៉ូតូឌុប និងអ្នកធាក់ស៊ីក្លូនៅរាជធានីភ្នំពេញ ក្នុងឆ្នាំ២០២១ ដែលគាំទ្រគម្រោងដោយThe Pollination Project។

# អនុសាសន៍

# អនុសាសន៍

ដើម្បីដោះស្រាយបញ្ហានៃការតាំងទីលំនៅខុសច្បាប់នៅលើដីរដ្ឋ រដ្ឋាភិបាលគួរតែពង្រឹងអនុវត្តនូវគោលនយោបាយដីធ្លីនានាឱ្យកាន់តែប្រសើរ ជាពិសេសតាមរយៈអ្នកអនុវត្តដែលជាអាជ្ញាធរពាក់ព័ន្ធ។ ជាឧទាហរណ៍ កម្មវិធីសម្បទានដីសង្គមកិច្ច រដ្ឋអនុវត្តឱ្យបានកាន់តែទូលំទូលាយបន្ថែមទៀត ជាពិសេសចំពោះពលរដ្ឋក្រីក្រដែលបានសំណង់បណ្តោះអាសន្នលើដីរដ្ឋ។ ក្នុងនោះដែរអាជ្ញាធរគួរតែអនុវត្តន៍តាមសារាចរលេខ០៣ ឱ្យបានល្អប្រសើរ ព្រោះវាអាចជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋដែលមកតាំងលំនៅខុសច្បាប់ បើទោះបីជាសារាចរមួយនេះគ្រាន់តែមានទម្រង់ជាសេចក្តីណែនាំពុំមានអានុភាពចាប់បង្ខំឱ្យអាជ្ញាធរអនុវត្តក្តី។ ជាក់ស្តែងអាជ្ញាធរពុំសូវបានប្រើប្រាស់សារាចរមួយនេះ ដើម្បីដោះស្រាយបញ្ហាចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋនោះទេ។ ក៏ប៉ុន្តែអាជ្ញាធរបែរជាព្យាយាមប្រើយន្តការបណ្តេញចេញ ចំពោះអ្នកដែលតាំងទីលំនៅលើដីរដ្ឋដោយខុសច្បាប់ទៅវិញដែល យន្តការនេះបង្កើតទៅជាវិវាទដីធ្លីដែលដោះស្រាយពុំចេញ ឬប្រើរយៈពេលយូរក្នុងការដោះស្រាយដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តគោលនយោបាយដីធ្លីដែលបានដាក់ចេញរបស់រដ្ឋាភិបាល។ ចំពោះករណីដែលចាំបាច់ត្រូវធ្វើការបណ្តេញចេញ អាជ្ញាធរគួរតែផ្តល់ដំណឹងជាក់លាក់ពីពេលវេលានៃការបណ្តេញចេញ និងប្រាប់ពីមូលហេតុច្បាស់លាស់នៃការបណ្តេញចេញទៅកាន់អ្នកដែលរងការបណ្តេញចេញ ដើម្បីឱ្យពួកគាត់មានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំខ្លួនដើម្បីផ្លាស់ទៅកាន់ទីតាំងថ្មី។ ហើយចំពោះការតាំងទីលំនៅថ្មីរបស់អ្នកដែលរងការបណ្តេញចេញគួរតែគិតពីលំនៅឋានសមរម្យដែលមានធាតុផ្សំទាំង៧ ដែលអ្នកដែលរងការបណ្តេញចេញត្រូវតែទទួលបាន។ ការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនអ្នកដែលបានរស់នៅលើដីរដ្ឋ ក៏ជាវិធីសាស្ត្រមួយក្នុងការកាត់បន្ថយការរស់នៅដោយគ្មានលំនៅឋាន ដែលជាមូលហេតុនាំឱ្យមាននូវភាពក្រីក្រ។ ដូចនេះរដ្ឋាភិបាល តាមរយៈអាជ្ញាធរពាក់ព័ន្ធគួរតែបង្កើនការធ្វើប្រទានកម្មនេះឱ្យបានកាន់តែប្រសើរថែមទៀត ជាពិសេសចំពោះប្រជាពលរដ្ឋដែលបានមកតាំងទីលំនៅលើដីរដ្ឋជាយូរយារណាស់មកហើយនោះ។ ចំណុចមួយទៀតដែលសំខាន់ដែរនោះគឺការកំណត់ចំណាត់ថ្នាក់នៃដីឱ្យបានត្រឹមត្រូវ ព្រោះមានអ្នករស់នៅលើដីរដ្ឋខ្លះដែលបានរស់នៅលើដីឯកជនរបស់រដ្ឋ ដែលជាមូលហេតុនាំឱ្យគាត់អាចដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិបាន នៅពេលណាដែលពួកគាត់ជាភោគីស្របច្បាប់ដោយបានបំពេញលក្ខខណ្ឌដូចដែលមានកំណត់នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១។

ក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិនឹងទទួលបានព័ត៌មានផ្សេងៗដែលខ្លួនចង់ដឹង ចង់ឮចង់ទទួលបាន ជាពិសេសគឺព័ត៌មានទាក់ទងនឹងការអនុម័តនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងព័ត៌មានទាក់ទងនឹងគម្រោងអភិវឌ្ឍនានា។ ដូចនេះហើយរដ្ឋាភិបាលត្រូវតែធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការកំណត់ចំណាត់ថ្នាក់នៃដីនេះដើម្បីឱ្យប្រជាពលរដ្ឋ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវបានយល់ និងបានដឹងពីប្រភេទនៃដីធ្លីដែលរដ្ឋាភិបាលបានកំណត់។ រដ្ឋក៏មិនត្រូវបំភ្លេចចោលឡើយនូវការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

ចំណេះដឹងផ្នែកច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងភូមិបាល។ វាពិតជាមានសារៈសំខាន់ណាស់ដែលរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធគួរតែបន្តបង្កើនការអនុវត្តជាបន្តទៀត ជាពិសេសចំពោះប្រជាពលរដ្ឋក្រីក្រដែលតាំងលំនៅបណ្តោះអាសន្នលើដីរដ្ឋ ដើម្បីឱ្យពួកគាត់បានយល់ដឹងពីសិទ្ធិនានាដែលគាត់អាចទទួលបាន បើទោះបីជាគាត់រស់នៅលើដីរដ្ឋដោយខុសច្បាប់ក៏ដោយ។ ក្រឡេកមើលច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ពាក់ព័ន្ធផ្សេងៗពុំមានមាត្រាណាមួយចែងឱ្យ ច្បាស់លាស់ពីយន្តការដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋនេះនៅឡើយទេ ដូចនេះរដ្ឋាភិបាលគួរធ្វើការស្នើរច្បាប់ ឬរដ្ឋសភាអនុម័តច្បាប់ដែលមានការចែងច្បាស់ពីយន្តការដោះស្រាយចំពោះសំណង់បណ្តោះអាសន្នលើដីរដ្ឋនេះ ហើយដែលវានឹងបង្កើតប្រសិទ្ធភាពនៃការដោះស្រាយនូវបញ្ហាមួយនេះ។ ចំពោះច្បាប់ភូមិបាលឆ្នាំ២០០១ ដដែលនេះ រដ្ឋាភិបាល តាមរយៈរដ្ឋសភាត្រូវតែធ្វើការបង្កើតនូវច្បាប់ភូមិបាលថ្មី ព្រោះដោយសារតែច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបាននិរាករណ៍នូវមាត្រាជាច្រើនដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ហើយនៅមានតែមាត្រាមួយចំនួនប៉ុណ្ណោះដែលនៅបន្តអនុវត្តដល់បច្ចុប្បន្ន។ ដែលការណ៍នេះបាននាំឱ្យការអនុវត្តពុំមានភាពច្បាស់លាស់ ដោយសារវាអាចនាំឱ្យមានការយល់ឃើញច្រឡំគ្នា ជាមួយនូវបទបញ្ញត្តិមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណី ដូចជាចំណុចទាក់ទងនឹងលទ្ធកម្មនៃកម្មសិទ្ធិ និងភោគៈជាដើម។

គម្រោងអភិវឌ្ឍគឺពិតជាបានចូលរួមចំណែក ក្នុងការកសាងសេដ្ឋកិច្ចប្រទេសឱ្យមានការរីកចម្រើនយ៉ាងពិតប្រាកដ។ ប៉ុន្តែ នៅពេលមានគម្រោងអភិវឌ្ឍន៍នានា ដែលនាំឱ្យមានការបណ្តេញពលរដ្ឋចេញ អាជ្ញាធរគួរតែបង្កើតឱ្យមានការពិភាក្សារវាងក្រុមហ៊ុនអភិវឌ្ឍន៍ និងពលរដ្ឋដែលរងការបណ្តេញចេញ។ ជាការល្អប្រសិនបើក្នុងការពិភាក្សានោះអនុញ្ញាតឱ្យភាគីពាក់ព័ន្ធដោយប្រយោលផ្សេងទៀតដូចជាអង្គការសង្គមស៊ីវិល ឬសមាគមណាមួយបានចូលរួម ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីតម្លាភាពនៃការអភិវឌ្ឍ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន។

ជាចុងក្រោយ ចំពោះការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋ ទៅឱ្យបុគ្គលឯកជនដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ រដ្ឋាភិបាលគួរតែធ្វើការសិក្សាឱ្យបានច្បាស់លាស់ពីផលប៉ះពាល់ដែលប្រជាពលរដ្ឋនឹងត្រូវទទួលរងដោយសារតែការធ្វើអនុប្បយោគដីនោះ។ ព្រោះកន្លងមកការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋនេះគឺបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សហគមន៍ ក៏ដូចជាប្រជាពលរដ្ឋក្រីក្រដែលរស់នៅលើដីរដ្ឋនោះ ហើយដែលបណ្តាលឱ្យកើតជាបញ្ហាវិវាទដីធ្លីដែលដោះស្រាយមិនងាយចេញ។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៨១។

រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៧៥។

ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, លេខ នស/រកម/១១២០/០៣០, ១៤ វិច្ឆិកា ២០២០។

ច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ២ វិច្ឆិកា ២០១៩។

ច្បាប់អស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២។

អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, លេខ២៩១អនក្រ/បក, ២៧ ធ្នូ ២០១១។

អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ/បក, ៧ តុលា ២០០៥។

អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ/បក, ១៩ មីនា ២០០៣។

ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ, លេខ៤៩៣សហវ/ប្រក, ១៨ កក្កដា ២០១០។

ប្រកាសស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៤២ដនស/ប្រក, ១០ មីនា ២០០៦។

សារាចរស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ, លេខ០៦សរ, ២៣ កក្កដា ២០១៩។

សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន, លេខ០៣សរ, ៣១ ឧសភា ២០១០។

សារាចរស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់, លេខ០២សរ, ២៦ កុម្ភៈ ២០០៧។

## ច្បាប់អន្តរជាតិសកល និងក្នុងតំបន់

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, អនុម័តថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌, អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

ធម្មនុញ្ញសង្គមរបស់អឺរ៉ុប (កែសម្រួល), ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៩។

ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ, អនុម័តដោយសន្និបាតនៃថ្នាក់ដឹកនាំរដ្ឋ និងរដ្ឋាភិបាលនៃអង្គការឯកភាពអាហ្វ្រិក ធ្វើនៅទីក្រុងណារ៉ូប៊ី ប្រទេសកេនយ៉ា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១។

អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស"កតិកាសញ្ញាទីក្រុងសង់ចូហ្សេ ប្រទេសកូស្តារីកា", ចុះហត្ថលេខាដោយរដ្ឋសមាជិកនៃអង្គការរដ្ឋក្នុងទ្វីបអាមេរិក ធ្វើនៅទីក្រុងសង់ចូហ្សេ ប្រទេសកូស្តារីកា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩។

អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, ចុះហត្ថលេខាដោយរដ្ឋសមាជិកនៃក្រុមប្រឹក្សាអឺរ៉ុប នៅទីក្រុងរ៉ូម នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០។

**គោលនយោបាយរដ្ឋាភិបាល**

ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ របស់រដ្ឋាភិបាល, ១៩ វិច្ឆិកា ២០១៨។

យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤ នីតិកាលទី៦ របស់រាជរដ្ឋាភិបាល, កញ្ញា ២០១៨។

គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" របស់រាជរដ្ឋាភិបាល, ២៨ សីហា ២០១៥។

គោលនយោបាយជាតិស្តីពីលំនៅឋាន របស់រាជរដ្ឋាភិបាល, ៩ ឧសភា ២០១៤។

ក្របខ័ណ្ឌយុទ្ធសាស្រ្តនៃគោលនយោបាយដីធ្លី របស់រាជរដ្ឋាភិបាល, ៦ កញ្ញា ២០០២។

**សៀវភៅ និងទិនានុប្បវត្តិ** ( Journal )

East-West Management Institute. *ច្បាប់ភូមិបាលកម្ពុជា៖ សៀវភៅសិក្សា និងស្រាវជ្រាវ.* ភ្នំពេញ, ២០០៥។

Hor, Peng, Kong Phallack និងJörg Menzel (Eds.). *Introduction to Cambodian Law* [សេចក្តីផ្តើមនីតិកម្ពុជា]. Phnom Penh: Konrad-Adenauer-Stiftung, 2012។

Jessie Hohmann."The Elements of Adequate Housing: Grenfell as Violation". [ធាតុផ្សំនៃលំនៅឋានសមរម្យ៖ ការរំលោភបំពានដោយហ្គ្រេនហ្វែល], Queen Mary Human Rights Law Review 5(2) (សីហា 2019)។

Matthew Mullen និងMike Hayes. *AN INTRODUCTION TO Human Rights in Southeast Asia Volume 1* [សេចក្តីផ្តើមពីសិទ្ធិមនុស្សនៅអាស៊ីអាគ្នេយ៍៖ វគ្គទី១] បកប្រែដោយ វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក. Creative Commons, 2015។

Manfred Nowak, Ludwig Boltzmann, Jeroen Klok និង Ingeborg Schwarz. *សិទ្ធិមនុស្ស៖ កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ.* ២០០៥។

People in Need. *គោលការណ៍ណែនាំស្តីពីការរៀបចំដីធ្លីផ្អែកលើសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា*, ២០១៥។

Rhona K.M. Smith. *Textbook on International Human Rights* [សៀវភៅសិក្សាអំពីសិទ្ធិមនុស្ស]. បកប្រែដោយ វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក. United Kingdom: Oxford, 2014។

Schmid, Christoph U.˝The Right to Housing as a Right to Adequate Housing Options˝[សិទ្ធិទទួលបានលំនៅឋាន គឺជាសិទ្ធិដែលទទួលបានជម្រើសលំនៅឋានគ្រប់គ្រាន់], European Property Law Journal 9(2-3) (2020):157-178។

Scott Leckie. Legal and Protection Policy Research Series៖ Housing, Land and Property Rights in Post-Conflict Societies [ស៊េរីស្រាវជ្រាវច្បាប់ និងគោលនយោបាយការការពារ៖ លំនៅឋាន ដីធ្លី និងសិទ្ធិលើអចលនទ្រព្យ ក្នុងសង្គមក្រោយជម្លោះ] (UNHCR, 2005)។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា. *សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំ ស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី*, ២០០៩។

មជ្ឈមណ្ឌលស្តីពីសិទ្ធិលំនៅឋាន និងការបណ្តេញចេញ អង្គការស្ពានទៅកាន់សន្តិភាពអាស៊ីអាគ្នេយ៍ និងគម្រោងគណនេយ្យភាព. *សៀវភៅណែនាំស្តីពីសិទ្ធិដីធ្លី និងលំនៅឋាននៅកម្ពុជា៖ ភាគទី១*, ២០០៩។

ហ៊ែល ចំរើន. *សេចក្តីផ្តើមសិក្សាអំពីនីតិភូមិបាល.* (អង្គការខុនរ៉ាដ អាដេណៅអ៊ែរ)។

អង្គការសហប្រជាជាតិ. *សិទ្ធិមានលំនៅឋានសមរម្យ*. ប័ណ្ណព័ត៌មានលេខ២១ (Rev.១). បកប្រែ និងបោះពុម្ពឡើងវិញដោយ ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា, ២០១៨។

អង្គការសហប្រជាជាតិ. *ស្ត្រី និងសិទ្ធិមានលំនៅឋានសមរម្យ*, បោះពុម្ពឡើងវិញ. ភ្នំពេញ, ២០១៤។

អនុសាសន៍រួមលេខ៤ ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ អនុម័តនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១ ដោយគណកម្មាធិការទទួលបន្ទុកផ្នែកសិទ្ធិសេដ្ឋកិច្ច និងវប្បធម៌។

ហាប់ ផល្វី. *វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា*, បោះពុម្ពលើកទី៣. ភ្នំពេញ ៖ Premium Advertising, ២០២១។

## ឯកសារបង្រៀន

ហាប់ ផល្វី. "នីតិទ្រព្យសម្បត្តិសាធារណៈ. " មេរៀនជា PowerPoint សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន សិក្សានៅសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០២០។

ហាប់ ផល្វី. "ការវិវត្តនៃប្រព័ន្ធគ្រប់គ្រងដីធ្លីនៅកម្ពុជា.˝ មេរៀនជា PowerPoint សម្រាប់និស្សិត សិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៩។

## និក្ខេបបទ

ទ្រី ហ៊ាង. *វិវាទដីធ្លីនៅកម្ពុជា ២០០១-២០០៩*. និក្ខេបបទបណ្ឌិតនីតិសាស្ត្រ. ឯកទេសនីតិឯកជន, រាជបណ្ឌិត្យសភាកម្ពុជា, ២០១២។

**របាយការណ៍ និងសលាកប័ត្រព័ត៌មាន**

អង្គការលីកាដូ. *សេចក្តីពន្យល់ពីករណីដីធ្លីសហគមន៍ដីក្រហម*. ភ្នំពេញ, ២០០៨។

អង្គការសមាគមធាងត្នោត. *ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី៖ ការសិក្សាស្រាវជ្រាវពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីក្នុងរាជធានីភ្នំពេញ*, ២០២០។

អង្គការសមាគមធាងត្នោត. *ការស្ទង់មតិក្នុងរាជធានីភ្នំពេញ៖ ការសិក្សាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងរាជធានីភ្នំពេញ*. ភ្នំពេញ, ២០១៨។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា. *សាលាកប័ត្រព័ត៌មានស្តីពី៖ ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាអំឡុងពេលកូវីដ១៩*, ២០២១។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា. *ការសិក្សាពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅកន្លែងតាំងទីលំនៅថ្មីក្នុងប្រទេសកម្ពុជា និង សេចក្តីព្រាងគោលការណ៍ណែនាំអំពីការតាំងទីលំនៅថ្មី*, ២០២២។

**ឯកសារផ្សេងៗ**

ក្រសួងផែនការ. សេចក្តីប្រកាសព័ត៌មានស្តីពីខ្សែបន្ទាត់ភាពក្រីក្រ និងអត្រាភាពក្រីក្រនៅកម្ពុជា ២០១៩-២០២០, លេខ០៩០៩ផក។

ក្រសួងផែនការ. *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩*. ២០១៩។

**គេហទំព័រ**

ឃួង ស្រេង. សន្និសីទសារព័ត៌មានស្តីពីវឌ្ឍនភាព និងទិសដៅបន្តរបស់រដ្ឋបាលរាជធានីភ្នំពេញ. *Fresh News*, ១៦ មិថុនា ២០២០។

ធនាគារពិភពលោក *គម្រោង ៩៣ លានដុល្លារ ជួយបង្កើនសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីរបស់កសិករក្រីក្រ និងសហគមន៍ជនជាតិដើមភាគតិច*.២០២០. ដកស្រង់ចេញពី www.worldbank.org ថ្ងៃទី២៦ មិថុនា ២០២០។

ធនាគារពិភពលោក *ទស្សនៈទូទៅ* .២០២២. ដកស្រង់ចេញពី www.worldbank.org ថ្ងៃទី២៩ មីនា ២០២២។

សារព័ត៌មានថ្មីៗ *«លំនៅឋាន» «លំនៅដ្ឋាន» និង «លំនៅស្ថាន» ប្រើមួយណាត្រឹមត្រូវ?* .២០២១. ដកស្រង់ចេញពី https://thmeythmey.com/?page=detail&id=92704 ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ *សម្បទានដីសង្គមកិច្ច*. ២០១៧. *ដកស្រង់ចេញពី* Open Development Cambodia (ODC) ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥។

អង្គការសមាគមធាងត្នោត *បញ្ឈប់ការបណ្តេញចេញ៖ សហគមន៍បឹងឈូកអមិនគួរត្រូវបានបណ្តេញចេញក្នុងអំឡុងពេលរាលដាលនៃជំងឺកូវីដ-១៩ឡើយ*. ២០២១. ដកស្រង់ចេញពី https://teangtnaut.org/?lang=km ថ្ងៃទី៥ សីហា ឆ្នាំ២០២១។

អង្គការសមាគមធាងត្នោត *របាយការណ៍ស្តីពី ការពិត និងតួលេខ#៤៦ ជំងឺកូវីដ-១៩ និងការផ្តល់ជំនួយ.* ២០២២.ដកស្រង់ចេញពី https://teangtnaut.org/?lang=km ថ្ងៃទី១៤ មីនា ២០២២។

ក្រសួងព័ត៌មាន. *ឯកឧត្តម ឃួង ស្រេង៖ ដាច់ខែកក្កដានេះ ប្រជាពលរដ្ឋរស់នៅក្រោមស្ពានអាកាសស្ទឹងមានជ័យនឹងប្តូរទីលំនៅមករស់នៅលើដីកម្មសិទ្ធិស្របច្បាប់តាមប្រឡាយស្ទឹងមានជ័យវិញ.* ២០២០. ដកស្រង់ចេញពី https://www.information.gov.kh/articles/16214 ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០២០។